MAXIMA
Microfinance

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី

MAXIMA MICROFINANCE PLC.




# របាយការណ៍ប្រចាំឆ្នាំ
# ២០២០



ធ្វើឱ្យជីវភាពកាន់តែប្រសើរឡើង

# មាតិកា

ទំព័រ


## ព័ត៌មានសង្ខេប

| | |
|---|---|
| ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃស្នូល | ១ |
| សង្ខេបសមិទ្ធផលសំខាន់ៗ | ២ |
| សូចនករគាំពារសង្គម | ៣ |
| សូចនករសេដ្ឋកិច្ចសំខាន់ៗសម្រាប់ឆ្នាំ២០២០ | ៤ |
| សារពីប្រធានក្រុមប្រឹក្សាភិបាល | ៥ |
| សារពីអគ្គនាយក | ៧ |
| ប្រវត្តិសំខាន់ៗរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី | ៩ |
| ដៃគូរបស់ម៉ាក់ស៊ីម៉ា | ១០ |
| **អំពីអាជីវកម្ម** | ១១ |
| ការគ្របដណ្តប់នៃសេវាកម្ម | ១១ |
| លទ្ធផលឥណទាន | ១២ |
| **អភិបាលកិច្ច** | ១៥ |
| រចនាសម្ព័ន្ធគ្រប់គ្រង | ១៥ |
| ភាគទុនិក | ១៥ |
| ព័ត៌មានអំពីភាគទុនិក | ១៦ |
| ក្រុមប្រឹក្សាភិបាល | ១៨ |
| គណៈកម្មការរបស់ក្រុមប្រឹក្សាភិបាល | ២២ |
| គណៈគ្រប់គ្រង | ២៥ |
| **ការគ្រប់គងកិច្ចការគាំពារសង្គម** | ៣០ |
| គោលដៅសង្គម | ៣០ |
| ការទទួលខុសត្រូវចំពោះអតិថិជន | ៣១ |
| ប្រវត្តិជោគជ័យរបស់អតិថិជន | ៣៣ |
| ការទទួលខុសត្រូវចំពោះបរិស្ថាន និងសហគមន៍ | ៣៩ |
| **របាយការណ៍ហិរញ្ញវត្ថុ និង របាយការណ៍របស់សវនករឯករាជ្យ** | ៤២ |
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | ៤២ |
| របាយការណ៍របស់សវនករឯករាជ្យ | ៤៥ |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ៤៨ |
| របាយការណ៍ចំណូលលម្អិត | ៤៩ |
| របាយការណ៍បម្រែបម្រួលមូលធន | ៥០ |
| របាយការណ៍លំហូរសាច់ប្រាក់ | ៥១ |
| **សកម្មភាពសំខាន់ៗប្រចាំឆ្នាំ** | ៥៣ |
| **ការការពារជម្ងឺកូវីដ១៩** | ៥៤ |
| **តំបន់ប្រតិបត្តិការ** | ៥៦ |
| អាសយដ្ឋានការិយាល័យម៉ាក់ស៊ីម៉ា | ៥៦ |
| ផែនទីបង្ហាញទីតាំង | ៥៧ |

# ព័ត៌មានសង្ខេប

## ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃស្នូល

### ចក្ខុវិស័យ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី មានចក្ខុវិស័យ ផ្តល់សេវាមីក្រូហិរញ្ញវត្ថុឈានមុខគេលើការបម្រើអតិថិជនប្រកបដោយគុណភាពល្អបំផុត។

### បេសកកម្ម

ផ្តល់ដំណោះស្រាយបរិយាប័ន្នហិរញ្ញវត្ថុ ជូនដល់អតិថិជន ដែលមានប្រាក់ចំណូលទាប និងសហគ្រាសខ្នាតតូច និងមធ្យម ដើម្បីកែលម្អស្តង់ដារសេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តរភាព។

### និយមន័យនៃពាក្យគន្លឹះនៃបេសកកម្មរបស់ម៉ាក់ស៊ីម៉ា

១)**ដំណោះស្រាយបរិយាប័ន្នហិរញ្ញវត្ថុ:** វិភាគលើការផ្តល់ និងប្រើប្រាស់ឥណទាន ធានារ៉ាប់រង ភតិសន្យាហិរញ្ញវត្ថុប្រាក់បញ្ញើ និងសេវាផ្សេងៗទៀត ព្រមទាំងសេវាមិនមែនហិរញ្ញវត្ថុ ដូចជា ការប្រឹក្សាយោបល់ អំពីអាជីវកម្ម និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ។

២) **គ្រួសារដែលមានចំណូលទាប:** សំដៅលើគ្រួសារដែលមានប្រាក់ចំណូលប្រចាំឆ្នាំ ទាបជាង $2,000 រួមបញ្ចូលទាំង គ្រួសារដែលងាយនឹងរងគ្រោះ និងមិនមានលទ្ធភាពទទួលសេវាហិរញ្ញវត្ថុពីធនាគារ។

៣)**សហគ្រាសខ្នាតតូច និងមធ្យម:** សំដៅលើសហគ្រាសខ្នាតតូច និងមធ្យមដែលមានសកម្មភាពបង្កើតប្រាក់ចំណូល ប្រចាំឆ្នាំរហូតដល់ $60,000។

៤)**ស្តង់ដារសេដ្ឋកិច្ចសង្គម:** កែលម្អជីវភាពរស់នៅ សុខភាព និងសុវត្ថិភាព

៥) **ប្រ កបដោយនិរន្តរភាព:** រក្សាបាននូវស្ថេរភាពហិរញ្ញវត្ថុរបស់ម៉ាក់ស៊ីម៉ា និងបង្កើតគុណតម្លៃដល់អ្នកដែលពាក់ព័ន្ធ ទាំងផ្នែកសេដ្ឋកិច្ច និងសង្គម។

### គុណតម្លៃស្នូល

- ឈរលើស្មារតីយកចិត្តទុកដាក់ និងគោរពគ្នាទៅវិញទៅមក
- ប្រកាន់យកសេចក្តីសុចរិត និងកសាងទំនុកចិត្ត
- មានតម្លាភាព និងការទទួលខុសត្រូវ
- កសាងបាននូវអភិបាលកិច្ចល្អ
- មានគំនិតផ្តួចផ្តើម និងគំនិតច្នៃប្រឌិតខ្ពស់

# សង្ខេបសមិទ្ធផលសំខាន់ៗ

| សមិទ្ធផលប្រតិបត្តិការ | ២០២១ | ២០២០ |
|---|---|---|
| ចំនួនសាខា | ១៤ | ១៣ |
| ចំនួនខេត្តដែលប្រតិបត្តិការ | ៨ | ៨ |
| ចំនួនស្រុកដែលប្រតិបត្តិការ | ៤៥ | ៣៨ |
| ចំនួនឃុំដែលប្រតិបត្តិការ | ២៥២ | ២០៣ |
| ចំនួនភូមិដែលប្រតិបត្តិការ | ១.៣០០ | ៩៥៧ |
| ផលប័ត្រឥណទានសរុប (គិតជាដុល្លារអាមេរិក) | ២១.៤២៤.៥៩៧ | ២០.៩៩៧.៦៤៩ |
| អតិថិជនសកម្ម | ៥.៨៧៤ | ៥.៦០៥ |
| ចំនួនអតិថិជនសម្រាប់មន្ត្រីឥណទានម្នាក់ | ៨៦ | ៧២ |
| ផលប័ត្រឥណទានមធ្យមសម្រាប់មន្ត្រីឥណទានម្នាក់ (គិតជាដុល្លារអាមេរិក) | ៣១៥.០៦៨ | ២៦៩.២០០ |
| ទំហំឥណទានជាមធ្យម (គិតជាដុល្លារអាមេរិក) | ២.៩៤៤ | ៣.០៩៨ |
| ចំនួនឥណទានដែលបានបញ្ចេញ (គិតជាដុល្លារអាមេរិក) | ១៨.២១៥.១១៧ | ១៣.៨០៣.១១៨ |
| ចំនួនអតិថិជនដែលបានផ្ដល់ឥណទាន | ៥.០៩៦ | ៤.២២៥ |
| ទំហំឥណទានដែលបានបញ្ចេញជាមធ្យម (គិតជាដុល្លារអាមេរិក) | ៣.៥៧៤ | ៣.២៦៧ |
| ផលប័ត្រឥណទានស្ថិតក្នុងហានិភ័យ | ០.៥៧% | ១.០២% |
| ចំនួនបុគ្គលិកសរុប | ១៧១ | ១៩០ |
| **សមិទ្ធផលហិរញ្ញវត្ថុ (CIFRS for SME)** | | |
| ចំណូលសរុប (គិតជាដុល្លារអាមេរិក) | ៣.៩៩៣.៣៩៨ | ៤.០៨៤.៣៩៩ |
| ចំណាយសរុប (គិតជាដុល្លារអាមេរិក) | ៣.៤៧៨.២៤៩ | ៣.៥៦៧.៥៤៤ |
| ប្រាក់ចំណេញសុទ្ធ (គិតជាដុល្លារអាមេរិក) | ៥១៥.១៤៩ | ៥១៦.៨៥៥ |
| ប្រាក់ឥណទានសរុប (គិតជាដុល្លារអាមេរិក) | ១៤.៧១៥.៣៩២ | ១៥.០២៧.៥៧២ |
| ទ្រព្យសកម្មសរុប (គិតជាដុល្លារអាមេរិក) | ២៤.១១៨.៦០៣ | ២៤.៧៧៩.០៧០ |
| មូលធនសរុប (គិតជាដុល្លារអាមេរិក) | ៨.៦៥៥.៤៣៧ | ៩.១៧២.២៩២ |
| ដើមទុន | ៥.០៩៥.២៩០ | ៥.០៩៥.២៩០ |
| ចំណូលធៀបនឹងមូលធន | ៦.១០% | ៥.៨% |
| ចំណូលធៀបនឹងទ្រព្យសកម្ម | ២.៣០% | ២.១% |
| អនុបាតការចំណាយលើប្រតិបត្តិការ | ៩.៨០% | ៨.៨% |

សំគាល់៖ តំបន់ប្រតិបត្តិការធ្លាក់ចុះដោយសារមានការផ្លាស់ប្តូរពីការកំណត់និយមន័យនៃតំបន់ប្រតិបត្តិការ

# សូចនករគាំពារសង្គម

| សូចនករគាំពារសង្គម | ២០២៩ | ២០២០ |
|---|---|---|
| **អភិបាលកិច្ច** | | |
| ចំនួនអ្នកគ្រប់គ្រង | ១០ | ១៣ |
| ចំនួនអ្នកគ្រប់គ្រងជាស្ត្រី | ៥ | ៥ |
| **ផលិតផលឥណទាន** | | |
| ផលិតភាពផលប័ត្រឥណទានក្នុងមន្ត្រីឥណទានម្នាក់ | ៣១៥.០៦៨ | ២៦៩.២០០ |
| **ការឆ្ពោះទៅរកអតិថិជន** | | |
| ចំនួនអតិថិជននៅជនបទ | ៤.៨៤៦ | ៤.៦៧៧ |
| ចំនួនអតិថិជននៅជាយក្រុង | ១.០២៨ | ៩២៨ |
| ចំនួនអតិថិជនជាស្ត្រី | ៥.៣៥៧ | ៥.០២១ |
| ចំនួនឥណទានជាក្រុម | ៨៤៥ | ៨៣៥ |
| ចំនួនឥណទានជាឯកត្តជន | ២.៧៤៣ | ៣.២៩០ |
| ចំនួនឥណទានជាសហគ្រាសខ្នាតតូច | ២.២៨៦ | ២.៦៥៤ |
| ចំនួនអតិថិជនថ្មី | ១.៥៣២ | ១.៤២៦ |
| **ការពង្រីកសេវាកម្មទៅរកអតិថិជនតាមរយៈវិធីសាស្ត្រឥណទាន** | | |
| ភាគរយនៃឥណទានក្រុម | ២% | ១២% |
| ភាគរយនៃឥណទានឯកត្តបុគ្គល | ២៧% | ៤៩% |
| ភាគរយនៃឥណទានសហគ្រាសខ្នាតតូច | ៧១% | ៣៩% |
| **ធនធានមនុស្ស** | | |
| ចំនួនបុគ្គលិកសរុប | ១៧១ | ១៩០ |
| ចំនួនបុគ្គលិកជាស្ត្រី | ៣៩ | ៤១ |
| ចំនួនមន្ត្រីឥណទាន | ៦៨ | ៧៨ |
| | | |
| **ការពេញចិត្តរបស់អតិថិជន** | | |
| អត្រាភក្ដីភាពអតិថិជន | ៨៣% | ៩៧% |

# សូចនាករសេដ្ឋកិច្ចសំខាន់ៗសម្រាប់ឆ្នាំ២០២០

| សូចនាករសេដ្ឋកិច្ចសំខាន់ៗ | ២០១៨ | ២០១៩p | ២០២០f | ២០២១f | ២០២២f |
|---|---|---|---|---|---|
| ទិន្នផល តម្រូវការក្នុងស្រុក និងតម្លៃ | | | | | |
| ផសស ពិត (%ប្រែប្រួលធៀបឆ្នាំ) | ៨ | ៧ | -២ | ៤ | ៥ |
| ផសស សម្រាប់មនុស្សម្នាក់(US$, ណូមីណល) | ១៥០១ | ១៦៣៣ | ១៦១៧ | ១៧១២ | ១៨២៣ |
| | | | | | |
| គណនីខាងក្រៅ | | | | | |
| កំណើនការនាំចេញ ទំនិញដឹកត្រឹមផែ (ណូមីណល គិតជាដុល្លារ ភាគរយប្រចាំឆ្នាំ) | ១២ | ១០ | -១៩ | ៨ | ៩ |
| កំណើនការនាំចូល ទំនិញដឹកដល់អ្នកទិញ (ណូមីណល គិតជាដុល្លារ ភាគរយប្រចាំឆ្នាំ) | ៩ | ៩ | -១៨ | ៧ | ៨ |
| ការវិនិយោគទុនផ្ទាល់ពីបរទេស (សុទ្ធ គិតជាលានដុល្លារបច្ចុប្បន្ន ) | ៣០៨៩ | ៣៥៦១ | ២០៩២ | ៣០៤១ | ២៩៨១ |
| | | | | | |
| សារពើពន្ធ | | | | | |
| ចំណូល (% ផសស) | ២៤ | ២៦ | ១៩ | ១៩ | ២១ |
| ការចំណាយ(% ផសស) | ២៣ | ២៦ | ២៤ | ២៥ | ២៤ |
| | | | | | |
| រូបិយវត្ថុ និងតម្លៃ | | | | | |
| ឥណទានក្នុងស្រុកទៅវិស័យឯកជន (% ផសស) | ៩៩ | ១១៤ | ១២៣ | ១៣២ | ១៤០ |
| អត្រាការប្រាក់រយៈពេលខ្លី (%ក្នុងមួយឆ្នាំ) | ១០ | ១០ | ៩ | ៩ | ៩ |
| អត្រាប្តូរប្រាក់ ណូមីណល (រូបិយវត្ថុក្នុងស្រុកធៀប នឹងដុល្លារអាមេរិក) | ៤០៦៧ | ៤០៧០ | ៤១០០ | ៤០៩០ | ៤០៨០ |
| អតិផរណា តម្លៃសម្រាប់អ្នកប្រើប្រាស់ ( % ប្រចាំឆ្នាំ រយៈពេលមធ្យម) | ៣ | ៣ | ៣ | ៣ | ៣ |

p = ព្យាករណ៍ (projection)
f = ព្យាករណ៍ (forecast)
ប្រភព៖ របាយការណ៍របស់ ធនាគារពិភពលោក៖ "ប្រទេសកម្ពុជា ឆ្ពោះទៅរកខ្សែសង្វាក់ផលិតកម្ម" ខែវិច្ឆិកា ឆ្នាំ ២០២០

# សារ
# ពី
# ប្រធានក្រុមប្រឹក្សាភិបាល

## លោកបណ្ឌិត អន ប៊ុនហាក់



## សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២០

ការរាតត្បាតនៃជំងឺកូវីដ-១៩ បានឱ្យធ្វើសេដ្ឋកិច្ច នៅជុំវិញពិភពលោក មានការធ្លាក់ចុះ និងបានរំខានដល់ ការលូតលាស់ នៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។ ប្រទេសកម្ពុជាមានអត្រាកំណើនជាមធ្យម ៧.៧ ភាគរយក្នុងអំឡុងពេលពីរទសវត្សចុងក្រោយនេះ។ នៅក្នុងឆ្នាំ២០២០ សេដ្ឋកិច្ចកម្ពុជា ធ្លាក់ចុះប្រហែល២ភាគរយ។ កត្តាជំរុញកំណើនសេដ្ឋកិច្ចសំខាន់ គឺវិស័យសំណង់ ទេសចរណ៍ និងការនាំចេញទំនិញ ដែលមានចំនួន ច្រើនជាង ៧០ភាគរយ នៃកំណើន និង ៣៩ ភាគរយ នៃការងារដែលបានចំណាយសរុប។ កំណើនសេដ្ឋកិច្ចត្រូវបានថយចុះ ដោយសារតែ វិបត្តិសេដ្ឋកិច្ចពិភពលោក និងការថយចុះនៃតម្រូវការសកលក៏ដូចជាហានិភ័យដែលកំពុងកើតឡើងគឺបណ្តាលមកពីការធ្លាក់ចុះសេដ្ឋកិច្ចរបស់ប្រទេសចិន និងការបាត់បង់មួយផ្នែក នៃការអនុគ្រោះពន្ធ របស់សហភាពអឺរ៉ុប EBA ( Everything-but- Arms )។

វិស័យមីក្រូហិរញ្ញវត្ថុមានការរីកចម្រើនបន្តិចនៅឆ្នាំ២០២០ ដោយសារ ផលប៉ះពាល់ នៃជំងឺកូវីដ១៩ ជាមួយនឹងតម្រូវការប្រាក់កម្ចីថ្មីធ្លាក់ចុះយ៉ាងខ្លាំងក្នុង អំឡុងខែដែលរងគ្រោះខ្លាំងបំផុតគឺ នៅក្នុងខែមេសា និងឧសភា ។ ផ្អែកលើរបាយការណ៍ របស់សមាគមន៍មីក្រូហិរញ្ញវត្ថុកម្ពុជា មានអតិថិជនចំនួនជិត ២ លាននាក់ដែលមានប្រាក់កម្ចីរហូតដល់ ៦.៩ ពាន់លានដុល្លារ។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានផ្តល់ឥណទានរៀបចំឡើងវិញ ដល់អតិថិជនជាង ២៧០.០០០ នាក់ដែលមានទំហំប្រាក់កម្ចីជាង ១.៤ពាន់លានដុល្លារ។ ការផ្តល់ឥណទាន រៀបចំឡើងវិញនឹង មានរហូតដល់ ពាក់កណ្តាលឆ្នាំ២០២១ដល់អតិថិជន ដែលរងផលប៉ះពាល់ ដោយសារ ជំងឺកូវីដ១៩ ។ ស្ថានភាពគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានចាប់ផ្តើមមានភាពប្រសើរឡើងវិញ ដូចជាការថយចុះ ឥណទានមិនដំណើរការ និងការកើនឡើងនូវប្រាក់កម្ចីនិងប្រាក់បញ្ញើថ្មី។អាជីវកម្មនិងសកម្មភាពសេដ្ឋកិច្ចភាគច្រើនបាន វិលត្រឡប់មករកសភាពដើមវិញ ហើយវាកំពុងជួយអតិថិជន របស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្នុងការសងប្រាក់កម្ចី របស់ពួកគេ។ ជាមួយនឹងការប្រកាស អំពីការចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ យើងមាន សុទិដ្ឋិនិយមថាផលប៉ះពាល់អវិជ្ជមានពីជំងឺរាតត្បាតនឹងថយចុះនៅ ឆ្នាំ២០២១ ហើយសេដ្ឋកិច្ចនឹងងើបឡើងវិញ។ ដូច្នេះវាជាឱកាសល្អសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុង ការកែសំរួលផលិតផល និងសេវាកម្ម ឱ្យសមស្របទៅនឹង តំរូវការរបស់ អតិថិជន និងពង្រីកប្រតិបត្តិការដើម្បីផ្តល់ សេវាកម្មហិរញ្ញវត្ថុដល់ ប្រជាជនកម្ពុជារាប់ពាន់នាក់ ជាពិសេសប្រជាជនទីក្រុង និងជនបទ។

# សង្ខេបសមិទ្ធផលក្នុងឆ្នាំ២០២០

គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០ ផលប័ត្រកម្ចីសរុប មានចំនួន ២០.៩៩៧.៦៤៩ ដុល្លារអាមេរិក ដែលមានការថយចុះ ២% ពី ២១.៤២៤.៥៩៧ ដុល្លារអាមេរិក ក្នុងឆ្នាំ ២០១៩ ហើយ អតិថិជន សកម្មសរុបមានចំនួន ៥.៦០៥ នាក់។ ហានិភ័យសំពៀតឥណទាន (PAR) បច្ចុប្បន្នចំនួន ១.០២% គឺទាបជាងមធ្យមភាគ នៃវិស័យទាំងមូលដែលបង្ហាញពី ការថែរក្សាគុណភាពប្រាក់កម្ចីបានល្អប្រសើរ។ ទោះបីជាកំណើន នៃផលប័ត្រឥណទាននេះនៅតែទាបជាងកំណើន ក្នុងស្តង់ដារវិស័យហិរញ្ញវត្ថុក៏ដោយ ម៉ាក់ស៊ីម៉ា ក៏ត្រូវបានគេចាត់ទុកថា ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មួយដែលមានប្រសិទ្ធភាពនៅក្នុងទីផ្សារ និងក្នុងវិស័យទាំងមូល។

ថ្នាក់ដឹកនាំ និងបុគ្គលិករបស់យើង បានបង្ហាញ នូវសមត្ថភាពក្នុងការកែតម្រូវ ទៅតាមការផ្លាស់ប្តូរ ម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជាឱ្យស្របតាមច្បាប់និងបទប្បញ្ញត្តិនានា។យើងបានអនុវត្តតាមបទប្បញ្ញត្តិ ដែលចេញដោយធនាគារជាតិនៃកម្ពុជា ជាពិសេសការកំណត់ចំណាត់ថ្នាក់ហានិភ័យឥណទាន និង សំវិធានធនលើអ៊ឹមកែរមែន។ នៅដើមឆ្នាំ២០២០ យើងបានអនុម័តស្តង់ដារគណនេយ្យ IFRS ដើម្បីបំពេញតាមតម្រូវការរបស់ក្រុមប្រឹក្សាជាតិគណនេយ្យ។

# ស្ថិរភាព និងដំណើរឆ្ពោះទៅមុខ

ស្ថានភាពទីផ្សារនាពេលបច្ចុប្បន្ន ជំរុញឱ្យគូប្រកួតប្រជែង ពង្រឹងសមត្ថភាព ក៏ដូចជាសម្របខ្លួនទៅតាម បច្ចេកវិទ្យាឌីជីថល ដើម្បីកាត់បន្ថយថ្លៃដើមប្រតិបត្តិការ ឱ្យមានប្រសិទ្ធភាព ជាពិសេស ផ្តល់បទពិសោធន៍ថ្មីដល់អតិថិជន។ ឆ្នាំនេះជាឆ្នាំ ដែលមានផលិតភាពយ៉ាងខ្លាំងជាមួយនឹងការអភិវឌ្ឍន៍ និងការកែលម្អផលិតផលថ្មីៗ ឆ្ពោះទៅរកការបម្រើអតិថិជនរបស់យើងឱ្យកាន់តែប្រសើរឡើង។

នៅក្នុងឆ្នាំ២០២១ ម៉ាក់ស៊ីម៉ា នឹងបន្តប្រតិបត្តិការក្រោម ការផ្លាស់ប្តូរឌីជីថល (Digital Transformation) បច្ចុប្បន្នរបស់ខ្លួន ដែលបង្ហាញពីយុទ្ធសាស្ត្រ និងទិសដៅអាជីវកម្មដើម្បី ប្រែក្លាយទៅជាស្តង់ដារប្រតិបត្តិការ ឆ្លើយតបតម្រូវការរបស់ អតិថិជនស្របតាមបច្ចេកវិទ្យាថ្មី និងបង្កើនសមត្ថភាពប្រកួតប្រជែង។

ម៉ាក់ស៊ីម៉ា មានប្រតិបត្តិការដ៏រឹងមាំ ដោយផ្តល់នូវគុណតម្លៃដល់ភាគទុនិករយៈពេលយូរអង្វែង។ យើងប្តេជ្ញាចិត្តផ្តល់អត្ថប្រយោជន៍ដ៏ល្អបំផុតដល់ភាគទុនិក តាមរយៈការយកចិត្តទុកដាក់ខ្ពស់ លើអភិបាលកិច្ចល្អ និងការរីកចម្រើនប្រកបដោយចីរភាព។ ដើម្បីបន្តពង្រឹងអភិបាលកិច្ចដ៏រឹងមាំ យើងជឿជាក់លើសមត្ថភាពគ្រប់គ្រងដឹកនាំរបស់លោកអគ្គនាយក និងថ្នាក់គ្រប់គ្រងគ្រប់លំដាប់ថ្នាក់ ដើម្បីឱ្យមានការពិភាក្សាលើបញ្ហាយុទ្ធសាស្ត្រ ដែលប៉ះពាល់ដល់គុណតម្លៃរយៈពេលវែងនៃប្រតិបត្តិការរបស់ ម៉ាក់ស៊ីម៉ា។ យើងបានរៀនសូត្រច្រើនពីបញ្ហាប្រឈមជាច្រើនឆ្នាំកន្លងមកហើយ ដែលបានធ្វើឱ្យយើង ក្លាយជាស្ថាប័នដ៏រឹងមាំ និងមានស្ថេរភាព រយៈពេល២០ឆ្នាំប្រកបដោយចីរភាព។

ជាចុងក្រោយតាំងនាមក្រុមប្រឹក្សាភិបាល ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះក្រុមប្រឹក្សាភិបាល ដែលបានប្រឹក្សាយោបល់ដល់គណៈគ្រប់គ្រងម៉ាក់ស៊ីម៉ា ដែលមានការប្តេជ្ញាចិត្តខ្ពស់ និងប្រកបដោយសមត្ថភាព។ ជាពិសេស ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោក ប៉ា ប៉ុណ្ណរិទ្ធី ជាអគ្គនាយក ដែលបានគ្រប់គ្រងដឹកនាំគ្រឹះស្ថានម៉ាក់ស៊ីម៉ា ប្រកបដោយប្រសិទ្ធភាព។ លើសពីនេះទៅទៀតខ្ញុំក៏សូមថ្លែងអំណរគុណដល់គ្រឹះស្ថានដែលបានខិតខំប្រឹងប្រែង ដើម្បីកសាងទំនុកចិត្តបន្ថែមទៀតដល់អតិថិជន ដោយបានបង្កើនផលប័ត្រឥណទាន តាមរយៈការអភិវឌ្ឍផលិតផល និងសេវាកម្ម ព្រមទាំងការធ្វើទំនើបកម្មបច្ចេកវិទ្យាឌីជីថល។ ក្នុងនាមខ្ញុំជាប្រធានក្រុមប្រឹក្សាភិបាលខ្ញុំមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការដឹកនាំ និងគាំទ្រវាល់ប្រតិបត្តិការរបស់ ម៉ាក់ស៊ីម៉ា ប្រកបដោយប្រសិទ្ធភាព និងចីរភាព ដើម្បីប្រែក្លាយម៉ាក់ស៊ីម៉ា ទៅជាស្ថាប័នហិរញ្ញវត្ថុឈានមុខគេនៅកម្ពុជានាពេលអនាគត។

**អន ម៉ុនហាក់**
**ប្រធានក្រុមប្រឹក្សាភិបាល**

# សារ ពី អគ្គនាយក

## លោក ប៉ា ប៉ុណ្ណរិទ្ធី



ជំងឺកូវីដ១៩ បានរីករាលដាលជាសកលធ្វើឱ្យសកម្មភាពសេដ្ឋកិច្ច មានធ្លាក់ចុះ ដែលជាហេតុធ្វើឱ្យ ប្រទេសនៅជុំវិញពិភពលោកបានរឹតបន្តឹងលើការបំលាស់ទី ដើម្បីបញ្ឈប់ការរីករាលដាលនៃជំងឺនេះ។ ប្រទេស ជាច្រើននៅជុំវិញពិភពលោកបានធ្វើការបិទខ្ទប់ទីក្រុង បិទស្ថានីយ៍យន្តហោះ និងបិទសាលារៀន ជាដើម។ ទន្ទឹមនឹងនេះដែរ ប្រទេសកម្ពុជាដែលមានអភិបាលកិច្ចដ៏រឹងមាំ បានចាត់វិធានការដើម្បីគ្រប់គ្រងជំងឺកូវីដ១៩ប្រកបដោយប្រសិទ្ធភាព។

ទោះបីវិស័យមីក្រូហិរញ្ញវត្ថុ ត្រូវបានរងផលប៉ះពាល់ ពីការរីករាលដាល នៃជំងឺកូវីដ១៩ ក៏ដោយ ក៏វិស័យនេះ នៅតែបន្តការរីកចម្រើន ដោយសារ ធនាគារជាតិនៃកម្ពុជា បានអនុញ្ញាតឱ្យគ្រឹះស្ថានមីក្រហិរញ្ញវត្ថុ ផ្តល់ឥណទានរៀបចំឡើងវិញ ដល់អតិថិជនដែលប្រឈមនឹង ស្ថានភាពលំបាក។ វិស័យមីក្រូហិរញ្ញវត្ថុ មានកំណើនប្រកបដោយចីរភាពក្នុងឆ្នាំ២០២០នេះ ជាមួយនឹង ផលប័ត្រឥណ-សរុប៦.៩ ពាន់លានដុល្លារអាមេរិក កើនឡើង ៦ ភាគរយ។ ខណៈពេលដែល ហានិភ័យសំពៀតឥណទាន មានត្រឹមតែ ១.៥ ភាគរយដែល មាន ការ ប្រសើរឡើងជាងឆ្នាំមុន។ចំនួនអ្នកខ្ចីសរុប មានដល់ជិត ២ លាននាក់។ សមតុល្យប្រាក់បញ្ញើឈានដល់៣.៦ ពាន់លានដុល្លារអាមេរិក ដោយចំនួនអ្នកដាក់ប្រាក់បញ្ញើ សរុប មានប្រមាណ ២.៧ លាននាក់ (ទិន្នន័យត្រូវបានគណនា ពី ៦៨ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានទទួលប្រាក់បញ្ញើរ ពី គ្រឹះស្ថានភតិសន្យាចំនួន ៧និង ប្រតិបត្តិករឥណទានជនបទចំនួន៧) ។

ខណៈពេល ដែលវិស័យហិរញ្ញវត្ថុ ត្រូវបានរងផល ប៉ះពាល់ដោយគ្រោះមហន្តរាយនៃជំងឺកូវីដ១ ៩ និងទឹកជំនន់ ការជ្រៀតចូលទីផ្សារ និង ការបង្កើនការប្រកួតប្រជែង យើងប្តេជ្ញាធ្វើឱ្យផលិតផលនិងសេវាកម្ម កាន់តែប្រសើរឡើង តាមរយៈការពង្រឹងវប្បធម៌ និងបុគ្គលិករបស់យើងដើម្បីជំរុញឱ្យមានកំណើននៅក្នុងទីផ្សារ។ យើងមានការជឿជាក់ថា យើងបានជ្រើសរើសយុទ្ធសាស្រ្តដ៏ត្រឹមត្រូវ ដើម្បីដោះស្រាយបញ្ហាប្រឈមនាពេលខាងមុខ។ យើងនឹង ខិតខំប្រឹងប្រែងនាំអតិថិជន និងភាគទុនិករបស់យើង ឆ្ពោះទៅរក អនាគតដ៏ភ្លឺស្វាងក្នុងគ្រាលំបាកនេះ។

គិតត្រឹម ឆ្នាំ ២០២០ គ្រឹស្ថាន មីក្រូហិរញ្ញវត្ថុ ម៉ាក់សុីម៉ាភីអិលសុី មានបទពិសោធន៍២០ឆ្នាំ ក្នុងការផ្តល់សេវាកម្ម ហិរញ្ញវត្ថុដល់អតិថិជនរបស់ខ្លួន។ ពេញមួយឆ្នាំ២០២០ ម៉ាក់សុីម៉ា បានរួបរួមគ្នាខិតខំប្រឹងប្រែងរបស់បុគ្គលិក និងគណៈគ្រប់គ្រង ដោយមានការគាំទ្រ ពីម្ចាស់ភាគហ៊ុន របស់យើង គឺក្រុមហ៊ុន Gojo & Company ,Inc. ដែ លជាក្រុមហ៊ុនឈានមុខគេមួយក្នុងប្រទេសជប៉ុន ដើម្បីត្រៀមខ្លួន សម្រាប់ការប្រកួតប្រជែង ដ៏តឹងតែង ដោយប្រកាន់ខ្ជាប់នូវការច្នៃប្រឌិតខ្ពស់ ដោយរាប់បញ្ចូលទាំងធនធានមនុស្សនិង បច្ចេកវិទ្យាព័ត៌មាន ដើម្បីបម្រើ សេវាកម្មហិរញ្ញវត្ថុ ប្រកបដោយវិជ្ជាជីវៈភាពស្មោះត្រង់ ភាពជឿជាក់ ជាមួយចក្ខុវិស័យឌីជីថល។ យើងផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុ ដែលមានគោលបំណងដើម្បី សម្រេចបាននូវវឌ្ឍនភាពសេដ្ឋកិច្ច និងសង្គមដោយផ្តល់ហិរញ្ញវត្ថុដែលមាន

តំលៃសមរម្យ ដល់ប្រជាជនក្រីក្រ និងអ្នកមានចំណូលទាបនៅតំបន់ជនបទ ដើម្បីលើកកម្ពស់ ជីវភាពរស់នៅ និងការសម្រេចគោលដៅអាជីវកម្ម របស់ពួកគេ។

ម៉ាក់ស៊ីម៉ា មានសាខាចំនួន១៣ ប្រតិបត្តិការចំនួន ៨ខេត្ត/ក្រុង គឺនៅខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ភ្នំពេញខេត្តកំពត ខេត្តព្រៃវែង ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម និងខេត្តតាកែវ។ បុគ្គលិកប្រកបដោយវិជ្ជាជីវៈរបស់យើងកំពុងផ្តល់ សេវាកម្មហិរញ្ញវត្ថុដ៏ល្អបំផុតតាមរយៈបណ្តាញសាខារបស់យើង។ នៅឆ្នាំ២០២១ យើង គ្រោងនឹងពង្រីកតំបន់ប្រតិបត្តិការ របស់ខ្លួន ដោយបន្ថែមសាខាថ្មី នៅក្នុងខេត្តមួយទៀតដើម្បីធ្វើឱ្យផលិតផល និងសេវាកម្មរបស់ខ្លួនចូលទៅក្នុងទីផ្សារថ្មី។ ទន្ទឹមនឹងនេះដែរ យើងក៏កំពុងប្រែក្លាយសេវាកម្មហិរញ្ញវត្ថុដែលមានស្រាប់ ឱ្យទៅជាសេវាហិរញ្ញវត្ថុតាម បែបឌីជីថល ដើម្បីបម្រើអតិថិជននៅក្នុងយុគសម័យឌីជីថលនេះ។ ម៉ាក់ស៊ីម៉ា បានបន្តផ្តល់នូវសេវាកម្មហិរញ្ញវត្ថុប្រកបដោយការទទួលខុសត្រូវ ដល់ប្រជាជនកម្ពុជានៅតាមតំបន់ជនបទ ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ និងប្រកាន់ភ្ជាប់នូវគោលការណ៍ ការពារអតិថិជន។ គិតត្រឹមខែធ្នូ ឆ្នាំ២០២០ យើងមានអតិថិជនជាង ៨៣ ភាគរយ រស់នៅតំបន់ជនបទ ៩០ភាគរយនៃអ្នកខ្ចីជាស្ត្រី និង២៣ភាគរយអ្នកខ្ចី នៅក្នុងវិស័យកសិកម្មដែលមិនមានហានិភ័យដល់បរិស្ថាន។ ក្នុងចំណោមអតិថិជនទាំងអស់មានអតិថិជនជាង ៦០០ នាក់ បានទទួលប្រាក់កម្ចី ពីទឹកស្អាត និងអនាម័យ។

យុទ្ធសាស្ត្ររបស់ម៉ាក់ស៊ីម៉ា គឺការរួមបញ្ចូល ស្តង់ដារនៃការគ្រប់គ្រងការងារសង្គម ទៅក្នុងគោលនយោបាយ និងនីតិវិធីរបស់ស្ថាប័ន ការបណ្តុះបណ្តាល ការផ្តល់ផលិតផល និងសេវាកម្ម និងឧបករណ៍ ត្រួតពិនិត្យ សកម្មភាពសង្គម។ ដោយ គណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាល យល់ឃើញថា ស្ថាប័នទទួលបានជោគជ័យលុះត្រាតែអតិថិជនជោគជ័យ ដូចនេះយើងនៅតែបន្តផ្តោតលើសកម្មភាពសង្គម ដើម្បីឆ្លើយតប ទៅនឹងគុណតម្លៃស្នូល របស់ម៉ាក់ស៊ីម៉ា។ ម៉ាក់ស៊ីម៉ាមានចក្ខុវិស័យ ផ្តល់គុណតម្លៃ ទាំងផ្នែកសង្គម និងផ្នែកហិរញ្ញវត្ថុ។យើងនឹងបន្តផ្តល់ជូននូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុប្រកបដោយ ការទទួលខុសត្រូវ ដើម្បីលើកកម្ពស់ ជីវភាពរបស់អតិថិជន។ លើសពីនេះទៀតយើងនឹងត្រួតពិនិត្យតាមដានសកម្មភាពសង្គម ដោយ ប្រើ SPI4 និងគោលការណ៍ការពារអតិថិជន។ យើងជឿជាក់យ៉ាងមុតថាម៉ាក់ស៊ីម៉ាមានជំហរដ៏រឹងមាំក្នុងការនាំមកនូវគុណតម្លៃបន្ថែមទៀតដល់អតិថិជន វិនិយោគិន និងម្ចាស់ភាគភាគហ៊ុន។

ជាចុងក្រោយតាំងនាមឱ្យគណៈគ្រប់គ្រង ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះម្ចាស់ភាគហ៊ុន ប្រធានក្រុមប្រឹក្សាភិបាល ចំពោះភាពជាអ្នកដឹកនាំ ការគាំទ្រនិងការណែនាំ និងអ្នកពាក់ព័ន្ធទាំងអស់ រួមទាំងអតិថិជន អ្នកនិយតករ វិនិយោគិន ដៃគូធនាគារ និងហិរញ្ញវត្ថុ ទាំងក្នុងស្រុក និងក្រៅស្រុក ចំពោះការជឿទុកចិត្ត និងទំនុកចិត្តមកលើគ្រឹះស្ថាន ដោយគាំទ្រដល់ការរីកចម្រើន របស់យើងក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ សមិទ្ធិផលទាំងអស់នេះ បានមកពីការយកចិត្តទុកដាក់ខ្ពស់ ក្នុងការបំពេញការងារ របស់បុគ្គលិកគ្រប់ជាន់ថ្នាក់ ជាពិសេសអតិថិជន ដៃគូ ព្រមទាំងអាជ្ញាធរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ដែលបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ក្នុងការគាំទ្រដល់ប្រតិបត្តិការរបស់ ម៉ាក់ស៊ីម៉ា។




**ប៉ា ប៊ុណ្ណារិទ្ធី**
**អគ្គនាយក**

# ប្រវត្តិសំខាន់ៗរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី

២០០០ ប ង្កើតឡើងនៅ ខែមីនាឆ្នាំ ២០០០ ដោយការចូលរួមពីមិត្តភក្តិមួយក្រុម ដែលមានជំនាញ និងបទពិសោធន៍ក្នុងសេវាកម្មហិរញ្ញវត្ថុ។ ម៉ាក់ស៊ីម៉ា ផ្តល់ឥណទានដំបូងនៅថ្ងៃទី ០១ មិថុនា ឆ្នាំ ២០០០ នៅឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល។

២០០១ ម៉ាក់ស៊ីម៉ា ចុះបញ្ជីនៅក្រសួងមហាផ្ទៃជាអង្គការក្រៅរដ្ឋាភិបាលដែលមានឈ្មោះថា អង្គការម៉ាក់ស៊ីម៉ាដើម្បីអភិវឌ្ឍគ្រួសារ។

២០០២ ម៉ាក់ស៊ីម៉ាបានចុះបញ្ជីនៅ ធនាគារជាតិនៃកម្ពុជា និងទទួលបានអាជ្ញាប័ណ្ណជាប្រតិបត្តិករឥណទា ជនបទ។ ក្នុងនាមជាស្ថាប័នមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា បានទាក់ទាញនូវដៃគូវិនិយោគជាច្រើន។

២០០៥ ម៉ាក់ស៊ីម៉ា បានចុះបញ្ជីនិងទទួលបានអាជ្ញាប័ណ្ណប្រកបអាជីវកម្មគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពី ធនាគារជាតិ នៃកម្ពុជា ដែលមានឈ្មោះជាផ្លូវការថា គ្រឹះស្ថាន ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ។ ក្នុងរយៈពេលនេះ ម៉ាក់ស៊ីម៉ា បានកសាងភាពជាដៃគូជាមួយអង្គការនិងស្ថាប័នមួយចំនួនដូចជា ធនាគារអភិវឌ្ឍន៍ជនបទ (Rural Development Bank), Appui au Développement Autonome (ADA) នៅប្រទេសលុចហ្សំបួរ Consorzio ETIMOS នៅប្រទេសអ៊ីតាលី និងស្ថាប័នផ្សេងទៀត។

២០០៦ ម៉ាក់ស៊ីម៉ាបានបង្កើតអត្ថប្រយោជន៍បន្ថែមសម្រាប់បុគ្គលិករួមមាន មូលនិធិសោធននិវត្តន៍ បុគ្គលិក និងការធានារ៉ាប់រងលើសុខភាព និងគ្រោះថ្នាក់។

២០០៧ ម៉ាក់ស៊ីម៉ា ក្លាយជាដៃគូរបស់ អង្គការ Kiva Microfund មានមូលដ្ឋាននៅសហរដ្ឋអាមេរិក

២០០៨ នៅក្នុងខែមិថុនា ឆ្នាំ២០០៨ ម៉ាក់ស៊ីម៉ា ទទួលបានអាជ្ញាប័ណ្ណប្រកបអាជីវកម្ម គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អចិន្ត្រៃយ៍ពីធនាគារជាតិនៃកម្ពុជា។ ក្នុងខែសីហា ម៉ាក់ស៊ីម៉ា បានបើកសាខាប្រតិបត្តិការទី២ នៅស្រុកកៀនស្វាយ ខេត្តកណ្តាល។

២០០៩ ម៉ាក់ស៊ីម៉ា ទទួលបានវិញ្ញាបនបត្រតម្លាភាពលើការគណនាអត្រាការប្រាក់ចំពោះអតិថិជនពី អង្គការ Microfinance Transparency Organization និងទទួលបានរង្វាន់ ស្តីពីសន្ទស្សន៍សង្គម ពីអង្គការ CGAP។

២០១២ ម៉ាក់ស៊ីម៉ាបានបម្លែងខ្លួនពីក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតដែលមានឈ្មោះថា ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី។

២០១៤ ក្រុមហ៊ុន Gojo & Company, Inc. បានចូលរួមជាភាគទុនិក

២០១៥ ម៉ាក់ស៊ីម៉ា បានកែប្រែឈ្មោះ ជាផ្លូវការថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី

២០១៦ នាឆ្នាំ២០១៦ ម៉ាក់ស៊ីម៉ា បានបង្កើនឱ្យមានការចងចាំលើម៉ាកសញ្ញាតាមរយៈការផ្លាស់ប្តូរការរចនាលើរូបសញ្ញាថ្មី។ នាឆ្នាំនេះផងដែរ ក្រុមហ៊ុន Gojo & Company, Inc. បានសម្រេចធ្វើការផ្លាស់ប្តូរ ពីឥណទានទៅជាដើមទុនរបស់ ម៉ាក់ស៊ីម៉ា ដែលសំណើនេះទទួលបានការអនុម័តពីធនាគារជាតិនៃកម្ពុជា ក្នុងខែធ្នូ ឆ្នាំ២០១៦។

២០១៧ ទទួលបានមូលនិធិពី Chailease Finance Co., Ltd. ។ ឆ្នាំ ២០១៧ ជាឆ្នាំដែលសំខាន់ ដោយសារតែគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី បានទទួលការគាំទ្រពីអ្នកផ្តល់ហិរញ្ញប្បទាន ដែលធ្វើស្ថាប័នមានលទ្ធភាពក្នុងការពង្រីកអាជីវកម្មទៅជិតអ តិថិជន។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី ត្រូវបានជ្រើសរើសឱ្យចូលរួមក្នុង គម្រោងសម្លេងអតិថិជន របស់ស្ថាប័ន MIX ។

២០១៨ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា បានធ្វើការវិនិយោគលើប្រព័ន្ធថ្មី "Morakot VB" អនុវត្តតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីលើកកម្ពស់ប្រាក់រៀលខ្មែរ

២០១៩ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា បានទទួលវិញ្ញាបនបត្រការពារអតិថិជន នៅ ខែកក្កដា ឆ្នាំ២០១៩ ពី Smart Campaign។



# ដៃគូរបស់ម៉ាក់ស៊ីម៉ា

Chailease Finance Co., Ltd.

ធនាគារ វត្តនៈ Vattanac Bank 安達銀行

PPCBank YOUR TRUSTED BANK

WATEREQUITY℠ REALIZE UNTAPPED OPPORTUNITY

miX Market

lendahand™ mesofinance

Luxembourg Microfinance and Development Fund

IIX

ada

OIKO CREDIT investing in people

ធនាគារ អេស៊ីលីដា ភីអិលស៊ី អេស៊ីលីដា ACLEDA ACLEDA Bank Plc.

Cambodia Microfinance Association

Wing

KIVA

# អំពីអាជីវកម្ម

ម៉ាក់ស៊ីម៉ា ផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុ ប្រកបដោយគុណភាព ខ្ពស់ផ្តោតទៅលើ ការផ្តល់ជូនប្រជាពលរដ្ឋ រស់នៅតំបន់ជនបទជា ឯកត្តជន ក្រុមជានា សហគ្រាសខ្នាតតូច ជូនអ្នកមានប្រាក់ចំណូលទាប ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាព និងសម្រេចគោលដៅអាជីវកម្ម របស់ពួកគេ។ ផលិតផលឥណទាន នាពេលបច្ចុប្បន្ន រួមមាន ឥណទានឯកត្តជន ឥណទានក្រុម និងឥណទានសហគ្រាសខ្នាតតូច។

# ការគ្របដណ្តប់នៃសេវាកម្ម

ក្នុងឆ្នាំ ២០២០ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា កំពុងបន្តប្រតិបត្តិការនៅសាខាចំនួន ១៣ ស្ថិតក្នុង ៨ ខេត្ត ៣៨ ស្រុក ២០៣ ឃុំ និង ៩៥៧ ភូមិ។ តារាងខាងក្រោមបញ្ជាក់ពីចំនួន សាខា ខេត្ត ស្រុក ឃុំ និងភូមិ ដែលស្ថិតក្នុងតំបន់ប្រតិបត្តិការរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី។

| ចំនួន | ២០១៩ | ២០២០ | កំណើន | % នៃការផ្លាស់ប្តូរ |
|---|---|---|---|---|
| សាខា | ១៤ | ១៣ | -១ | -៧% |
| ខេត្តប្រតិបត្តិការ | ៨ | ៨ | ០ | ០% |
| ខេត្តប្រតិបត្តិការ | ៨ | ៨ | ០ | ០% |
| ស្រុកប្រតិបត្តិការ | ៤៥ | ៣៨ | -៧ | -១៦% |
| ឃុំប្រតិបត្តិការ | ២៥២ | ២០៣ | -៤៩ | -១៩% |
| ភូមិប្រតិបត្តិការ | ១.៣០០ | ៩៥៧ | -៣៤៣ | -២៦% |

# លទ្ធផលឥណទាន

នាឆ្នាំ ២០២០ ផលប័ត្រឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី មាន ២០.៩៩៧.៦៤៩ ដុល្លារអាមេរិក ស្មើនិងធ្លាក់ចុះ ២% ធៀបនឹងផលប័ត្រឥណទានកាលពីឆ្នាំ ២០១៩។ ចំនួនឥណទានធ្លាក់ចុះ ៧% ដោយចុះពី ៧.២៧៧ ក្នុងឆ្នាំ២០១៩ មកត្រឹម ៦.៧៧៩ ក្នុងឆ្នាំ២០២០។




ម៉ាក់ស៊ីម៉ា បានបញ្ចេញឥណទានចំនួន ១៣.៨០៣.១១៨ ដុល្លារអាមេរិក នាឆ្នាំ ២០២០ និងមានចំនួនឥណទាន ៤.២២៥ ។ ទំហំឥណទានបញ្ចេញជាមធ្យមមានចំនួន ៣.២៦៧ ដុល្លារអាមេរិក។



## ផលប័ត្រឥណទានប្រចាំត្រីមាស និងហានិភ័យសំពៀតឥណទាន




ហានិភ័យសំពៀតឥណទានក្នុងឆ្នាំ២០២០ គឺ ១.០២% មានការកើនឡើងចំនួន ០.៤៥% ធៀបនឹងឆ្នាំ២០១៩

## ហានិភ័យសំពៀតឥណទាន និងការលុបបំណុលចេញពីបញ្ជី



# ការបែងចែកឥណទានតាមប្រភេទ

ឥណទានរបស់ ម៉ាក់ស៊ីម៉ា ត្រូវបានប្រើប្រាស់ សម្រាប់វិស័យផ្សេងៗគ្នាជាច្រើន។ វិស័យដែលទទួល បានឥណទានយកទៅប្រើប្រាស់ច្រើនជាងគេ គឺ សំណង់ ៣៦,៣% កសិកម្ម ១៨,៥% វិស័យពាណិជ្ជកម្ម ១៦,៧% វិស័យដឹកជញ្ជូន ៨,៦% សេវាកម្ម ៧,១% អាជីវកម្មគ្រួសារ ១,៩% និង សកម្មភាពផ្សេងៗ ១០,៩%។



# អភិបាលកិច្ច

## រចនាសម្ព័ន្ធគ្រប់គ្រង




## ភាគទុនិក

គិតត្រឹមខែធ្នូ ឆ្នាំ២០២០ ភាគទុនិករបស់គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី រួមមាន

| ភាគទុនិក | ចំនួនភាគហ៊ុន | តម្លៃ (គិតជាដុល្លារ) | ភាគរយ |
|---|---|---|---|
| ភាគរយ | 314,029 | 3,140,290 | 61.63% |
| Gojo & Company, Inc. | ៣១៤.០២៩ | ៣.១៤០.២៩០ | ៦១,៦៣% |
| លោក អន ប៊ុនហាក់ | ១០០.០០០ | ១.០០០.០០០ | ១៩,៦៣% |
| លោកស្រី ស្រេង ស៊ីវឆេង | ៤៣.០០០ | ៤៣០.០០០ | ៨,៤៤% |
| លោកស្រី សារុន រិទ្ធរ័ត្ន | ៤២.០០០ | ៤២០.០០០ | ៨,២៤% |
| លោកជេត ច័ន្ទប្រសើរ | ៥.៥០០ | ៥៥.០០០ | ១,០៨% |
| លោក ប៉ា ប៉ុណ្ណរិទ្ធី | ៤.៣៨៥ | ៤៣.៨៥០ | ០,៨៦% |
| លោក ប៉ា ប៉ុណ្ណរិទ្ធី តំណាងបុគ្គលិក | ៦១៥ | ៦.១៥០ | ០,១២% |
| **សរុប** | ៥០៩.៥២៩ | ៥.០៩៥.២៩០ | ១០០% |
| | | | |

# ព័ត៌មានអំពីភាគទុនិក

## Gojo & Company, Inc.

### Gojo & Company, Inc.

ក្រុមហ៊ុន Gojo គឺជាអ្នកជំរុញឲ្យមានបរិយាប័ន្នហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការសហគមន៍ តាមរយៈការវិនិយោគ និងធ្វើជាដៃគូជាមួយអ្នកផ្តល់សេវាហិរញ្ញវត្ថុនៅជុំវិញពិភពលោក។ ក្រុមហ៊ុននេះមានទីស្នាក់ការកណ្តាលនៅទីក្រុងតូក្យូ ហើយមានក្រុមហ៊ុនដៃគូនៅប្រទេសកម្ពុជា ស្រីលង្កា មីយ៉ាន់ម៉ា និងឥណ្ឌា។ ក្រុមហ៊ុន Gojo ចង់បង្កើតពិភពលោកមួយដែលមនុស្សគ្រប់គ្នាអាចកែប្រែ និងកំណត់ជោគវាសនារបស់ពួកគេ។ បេសកកម្មរបស់ក្រុមហ៊ុន Gojo គឺដើម្បីពង្រីកវិសាលភាពសេវាហិរញ្ញវត្ថុដល់ប្រជាជននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ហើយមានគោលបំណងដើម្បីឈានទៅបម្រើដល់ប្រជាជនជាង ១០០លាននាក់ នៅក្នុងប្រទេសចំនួន ៥០ ឬច្រើនជាងនេះនៅចុងឆ្នាំ២០៣០។



Dr. An Bunhak

**លោកបណ្ឌិត អន ប៊ុនហាក់** បានចូលរួមជាភាគទុនិកជាមួយ ម៉ាក់ស៊ីម៉ា ចាប់តាំងពីឆ្នាំ ២០០០។ លោកបណ្ឌិត អន ប៊ុនហាក់ ទទួលបានសញ្ញាបត្របណ្ឌិតគ្រប់គ្រងធុរកិច្ច (DBA) ពីសាកលវិទ្យាល័យ Preston University នៅសហរដ្ឋអាមេរិក ក្នុងឆ្នាំ២០០៩។ លោក បណ្ឌិត អន ប៊ុនហាក់ បានទទួលបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកធនាគារ និងហិរញ្ញវត្ថុពីសាកលវិទ្យាល័យន័រតុន ប្រទេសកម្ពុជា និងពីសាកលវិទ្យាល័យ Ateneo De Zambuaga ប្រទេសហ្វីលីពីន នៅក្នុងឆ្នាំ២០០៣។ នៅក្នុងឆ្នាំ១៩៩៥ លោកបណ្ឌិត អន ប៊ុនហាក់ បានទទួលបរិញ្ញាបត្រគ្រប់គ្រងធុរកិច្ច(BBA) ពីមហាវិទ្យាល័យពាណិជ្ជសាស្ត្រ នៅក្នុងប្រទេស កម្ពុជា។ លោកបណ្ឌិត អន ប៊ុនហាក់ អាចប្រើប្រាស់ ភាសាអង់គ្លេស ភាសាថៃ និងភាសាខ្មែរ បានយ៉ាងស្ទាត់ជំនាញ។



Ms. Sreng Sivechheng

**លោក ស្រី ស្រេង ស៊ីវឆេង** បានចូលរួមជាភាគទុនិកជាមួយម៉ាក់ស៊ីម៉ាដែលបានចាប់ផ្តើមដំណើរការនៅក្នុងឆ្នាំ២០០០។លោកស្រី បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់លើជំនាញគ្រប់គ្រងហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅរាជធានីភ្នំពេញ នាឆ្នាំ២០១៦។ នៅឆ្នាំ២០០១ លោកស្រី ទទួលបាន បរិញ្ញាបត្រពាណិជ្ជសាស្ត្រ ផ្នែកគ្រប់គ្រង ពីវិទ្យាស្ថានជាតិគ្រប់គ្រង។ លោកស្រី ស៊ីវឆេង អាចប្រើប្រាស់ ភាសាខ្មែរ ភាសាអង់គ្លេស និងភាសាថៃ បានយ៉ាងល្អ។



Mr. Chet Chanprasoeur

**លោក ជេត ច័ន្ទប្រសើរ** បានចូលរួមជាភាគទុនិកជាមួយ ម៉ាក់ស៊ីម៉ា នៅក្នុងខែធ្នូ ឆ្នាំ ២០០០។ លោក ប្រសើរ បានទទួលបរិញ្ញាបត្រ ជាន់ខ្ពស់ផ្នែកច្បាប់នៅសាកលវិទ្យាល័យ បៀលប្រាយនៅក្នុងឆ្នាំ២០១០។ នៅក្នុងឆ្នាំ១៩៩៥ លោក ប្រសើរ ទទួលបានបរិញ្ញាបត្រ គ្រប់គ្រងពាណិជ្ជកម្មពីមហាវិទ្យាល័យពាណិជ្ជសាស្ត្រ នៅក្នុងប្រទេសកម្ពុជា។



Mr.Pa Ponnak Rithy

**លោក ប៉ា ប៉ុណ្ណរិទ្ធី** បានចូលរួមជាភាគទុនិកជាមួយម៉ាក់ស៊ីម៉ានៅក្នុងខែធ្នូឆ្នាំ២០០០។ លោក ប៉ុណ្ណរិទ្ធី ទទួលបានបរិញ្ញាបត្រគណនេយ្យ-ហិរញ្ញវត្ថុ និងធនាគារនៅក្នុងឆ្នាំ១៩៨៦ នៅក្នុង ប្រទេសកម្ពុជា។ លោក ប៉ា ប៉ុណ្ណរិទ្ធី អាចប្រើប្រាស់ភាសាខ្មែរ និងភាសាអង់គ្លេស បានយ៉ាងល្អ។



Ms. Sarun Vithourat

**លោកស្រី សារុន វិធុរ័ត្ន** បានចូលរួមវិនិយោគជាមួយ ម៉ាក់ស៊ីម៉ា នៅក្នុងឆ្នាំ២០១២។ លោកស្រី វិធុរ័ត្ន បានទទួលសញ្ញាបត្រលើជំនាញ ទីផ្សារ និងធនាគារ ពី សាកលវិទ្យាល័យ Rene Descartes នៅទីក្រុងប៉ារីស ប្រទេសបារាំង ក្នុងឆ្នាំ២០០៧។ លោកស្រី វិធុរ័ត្ន មានបទពិសោធន៍ការងារ ក្នុងវិស័យធនាគារ ទាំងនៅក្នុងប្រទេសបារាំង និងនៅក្នុងប្រទេស កម្ពុជា។ លោកស្រីបានធ្វើការបណ្តាក់ទុនជាច្រើនក្នុងវិស័យពាណិជ្ជកម្មនៅប្រទេសកម្ពុជា ជាពិសេសខាងផ្នែក គ្រឿងសំអាង និងការថែរក្សាសម្ផស្ស វិស័យសុខាភិបាល និងវិស័យ ម៉ាស៊ីនកិនស្រូវ ចាប់តាំងពីឆ្នាំ២០០៩។

# ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា មានសមាជិកចំនួន ៨រូប។ ក្រុមប្រឹក្សាភិបាល មានចំណេះដឹង និងជំនាញទាក់ ទ ង នឹង ការវិភាគឥណទាន សវនកម្ម ហិរញ្ញវត្ថុ ប្រតិបត្តិការ និងការគ្រប់គ្រង ធនធានមនុស្ស។ ជាពិសេស ក្រុមប្រឹក្សាភិបាលមាន ប ទ ពិសោធន៍ ទាក់ទងនឹងវិស័យមីក្រូហិរញ្ញវត្ថុ និងធនាគារ ដែលជាធនធាន ដ៏សំខាន់សម្រាប់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី។ នាថ្ងៃ ៣១ ខែ ធ្នូ ឆ្នាំ២០១៩ ក្រុមប្រឹក្សាភិបាលរួមមាន៖

### លោកបណ្ឌិត អន ប៊ុនហាក់
### ប្រធានក្រុមប្រឹក្សាភិបាល

លោក បណ្ឌិត អន ប៊ុនហាក់ ជាប្រធានក្រុមប្រឹក្សាភិបាល និងជាសមាជិក ស្ថាបនិកនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី។ លោក ត្រូវបានតែងតាំងជា ប្រធានក្រុមប្រឹក្សាភិបាលនាបំណាច់ឆ្នាំ២០១១។ មុនពេលបម្រើការងារនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា លោកបណ្ឌិត ប៊ុនហាក់ បម្រើការងារជានាយកប្រតិបត្តិហិរញ្ញវត្ថុ នៅធនាគារពាណិជ្ជ ប៉ាស៊ីហ្វិក (1995-2000)។ លោកបណ្ឌិត អន ប៊ុនហាក់ ទទួលបាន សញ្ញាបត្របណ្ឌិតគ្រប់គ្រងធុរកិច្ច (DBA) ផ្នែកគ្រប់គ្រង ពីសាកលវិទ្យាល័យ Preston University នៅសហរដ្ឋអាមេរិក ក្នុងឆ្នាំ២០០៩។ លោកបណ្ឌិត ប៊ុនហាក់ បានទទួល បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ ន័រតុន ប្រទេសកម្ពុជា និងពីសាកលវិទ្យាល័យ Ateneo De Zambuaga ប្រទេស ហ្វីលីពីន នៅក្នុងឆ្នាំ២០០៣។ នៅក្នុងឆ្នាំ១៩៩៥ លោកបណ្ឌិត អន ប៊ុនហាក់បានទទួលប រិញ្ញាបត្រគ្រប់គ្រង ធុរកិច្ច(BBA) ពីមហាវិទ្យាល័យពាណិជ្ជសាស្រ្ត នៅក្នុងប្រទេសកម្ពុជា។



**លោកបណ្ឌិត អន ប៊ុនហាក់**
ប្រធានក្រុមប្រឹក្សាភិបាល

---

### លោក Taejun Shin, តំណាងក្រុមហ៊ុន Gojo & Company, Inc.
### អភិបាល

លោក Taejun Shin ជាស្ថាបនិក និងជាអគ្គ នាយកនៃក្រុមហ៊ុន Gojo & Company, Inc., ដែលជាភាគទុនិ កចម្បងរបស់ ម៉ាក់ស៊ីម៉ា។ បន្ទាប់ពីបញ្ចប់ការសិក្សាពី សាកលវិទ្យាល័យ Korea និងសាកលវិទ្យាល័យ Waseda លើជំនាញ គ្រប់គ្រងហិរញ្ញវត្ថុ លោក Taejun បានចាប់ផ្ដើមអាជីពរបស់ខ្លួននៅក្រុមហ៊ុន Morgan Stanley បន្ទាប់មកបម្រើការងារនៅក្រុមហ៊ុន Unison Capital។ ខណៈពេលបម្រើការងារ ក្នុងវិស័យហិរញ្ញវត្ថុ លោក Taejun បានបង្កើតអង្គការ Living in Peace ក្នុងឆ្នាំ២០០៧ និងបង្កើតមូលនិធិវិនិយោគ លើវិស័យមីក្រូហិរញ្ញវត្ថុជាលើកដំបូង ក្នុងប្រវត្តិសាស្រ្តវិនិយោគរបស់ប្រទេស ជប៉ុន នាឆ្នាំ២០០៩។ លោក Taejun បានសហការបង្កើត ក្រុមហ៊ុន Gojo នៅឆ្នាំ២០១៤ ហើយបានដឹកនាំក្រុមហ៊ុនទទួលបានការរីកចម្រើន ជាបន្តបន្ទាប់ ហេតុបច្ចុប្បន្ន លោក បានក្លាយជាអគ្គនាយកក្រុមហ៊ុន។ លោកគឺជា Young Global Leader នៃវេទិកាសេដ្ឋកិច្ចពិភពលោក និងជាសមាជិកស្ថាបនិកវ័យក្មេងនៃ Endeavor Japan។ លោក ត្រូវបាន ទស្សនាវដ្ដី Harvard Business Review របស់ប្រទេសជប៉ុន ជ្រើសរើសជាអគ្គនាយកផ្ដើមទាំង ២០ ដែលមានអាយុតិចជាង ៤០ឆ្នាំ។ លោកបានអ្នកនិពន្ធសៀវភៅ ចំនួន ៩ក្បាល លោកក៏ជាកីឡាករអត្តពលិករត់ចម្ងាយ ដែលបានបញ្ចប់ ចម្ងាយផ្លូវ ១.៦៤៨ គីឡូម៉ែត និងជាកីឡាករ ការ៉ាតេខ្សែក្រវាត់ខ្មៅផងដែរ។ លោក Taejun អាចប្រើប្រាស់ភាសា ជប៉ុន កូរ៉េ និងអង់គ្លេស បានយ៉ាងស្ទាត់ជំនាញ។



**លោក Taejun Shin**
អភិបាល

## លោក Sanjay Gandhi
### អភិបាល



**លោក Sanjay Gandhi**
អភិបាល

លោក Sanjay Gandhi ជាសហស្ថាបនិក និងជានាយកប្រតិបត្តិវិនិយោគ នៃ ក្រុមហ៊ុន Gojo & Company, Inc.,។ ដោយមានលក្ខខណ្ឌគ្រប់គ្រាន់ក្លាយជា គណនេយ្យករជំនាញនៅប្រទេសឥណ្ឌា លោក Sanjay បានចាប់ផ្តើម អាជីពរបស់គាត់ក្នុងឆ្នាំ១៩៩១ ជាមួយ AF Ferguson ជាក្រុមហ៊ុនសវនកម្ម ដែលមានអាយុកាលចំណាស់ជាងគេនៅក្នុងប្រទេសឥណ្ឌា ( ជាដៃគូរបស់ Deloitte ប្រទេសឥណ្ឌា)។ បន្ទា ប់ មក លោក បានចូលប្រ ឡូកក្នុងវិស័យហិរញ្ញវត្ថុ និងធនាគារជាមួយ ក្រុមហ៊ុនដ៏ធំមួយ នៅក្នុងប្រទេសឥណ្ឌា អស់រយៈពេល ៨ឆ្នាំ។ ចាប់តាំងឆ្នាំ២០០៣ មក លោក Sanjay បានធ្វើការនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុហើយក្លាយជាអ្នកជំនាញខាងវិស័យ នេះ។លោក S anjay មា ន ប ទពិ សោធន៍លើការ ធ្វើចំណាត់ថ្នាក់ស្ថាប័ន មីក្រូហិរញ្ញវត្ថុជិត ១៥០ គ្រឹះស្ថាន នៅក្នុង ២៥ ប្រទេស ទូទាំងអាស៊ី អាហ្វ្រិក និង អឺរ៉ុបខាងកើត ជាមួយក្រុមហ៊ុន Planet Rating និងM-CRIL។ នៅ M-CRIL លោកដឹកនាំក្រុមការងារចំណាត់ ថ្នាក់ ក្នុងមុខតំណែងជានាយក។ លោក ជាវាគ្មិនបង្រៀនខាងផ្នែកវិភាគលើឥណទាន និងការធ្វើចំណាត់ថ្នាក់ ជាច្រើនកន្លែងជុំវិញពិភពលោក។ លោក ក៏ធ្លាប់បង្កើតសិក្ខាសាលាជាច្រើន ខាងផ្នែកគ្រប់គ្រងហានិភ័យ ដល់បុគ្គលិក នៅក្នុងគ្រឹះស្ថានមួយចំនួននៅក្នុងប្រទេសកម្ពុជា។ ជាមួយនិង បទពិសោធន៍ជាង ២៦ឆ្នាំ ក្នុងផ្នែកសវនកម្មសាជីវកម្មធនាគារ និងការធ្វើការជាមួយស្ថាប័នមីក្រូហរិញ្ញវត្ថុ បានជួយឱ្យ លោក Sanjay រៀបចំនូវការងាររបស់លោកយ៉ាងប្រសើរ។ លោក Sanjay ដឹកនាំក្នុងការវាយតម្លៃ គ្រឹះស្ថាន និងផ្តួចផ្តើមកែលម្អប្រតិបត្តិការសម្រាប់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលជាដៃគូ។ ក្នុងតួនាទីជាសមាជិកក្រុមប្រឹក្សាភិ បា ល គ្រឹះ ស្ថា ន មីក្រូហិ រញ្ញវត្ថុ ម៉ាក់ស៊ីម៉ា លោកជា សមាជិកនៃ គណៈ កម្មការហានិភ័យ និងគណៈកម្មការសវនកម្មផ្ទៃក្នុង។

## លោកស្រី Praachi Gandhi
### អភិបាល



**លោកស្រី Praachi Gandhi**
អភិបាល

លោកស្រី Praachi Gandhi គឺជាអ្នកជំនាញខាងសង្គមវិទ្យា ជាអតីត សាស្ត្រាចារ្យ និងជាគ្រូបណ្តុះបណ្តាលជំនាញមកពីសាលាសេដ្ឋកិច្ចដេលី នៃសាកលវិទ្យាល័យដេលីប្រទេសឥណ្ឌា។ លោកស្រីក៏ជា "សវនករឯករាជ្យផ្នែក SPI4 ដែលទទួលស្គាល់ដោយស្ថាប័ន CERISE ដោយបម្រើការងារផ្នែកគ្រប់គ្រងការងារសង្គម (SPM) និងគោលការណ៍ការពារអតិថិជន (CPP) ក្នុង ស្ថា ប័ នមីក្រូហិរញ្ញវត្ថុ (MFI) នៅជុំវិញពិភពលោក។ ក្នុងនាមជាអ្នកជំនាញសង្គមវិទ្យានិងជាស្ត្រីម្នាក់ ដែលបានធ្វើការនៅកម្រិតមូលដ្ឋានអស់រយៈពេលជាច្រើនឆ្នាំ លោកស្រីយល់ច្បាស់ពីតម្រូវការរបស់អតិថិជន មីក្រូហិរញ្ញវត្ថុ ជាពិសេសអតិថិជនជាស្ត្រី ដើម្បីរក្សាការគោរព សេចក្តីថ្លៃថ្នូរ និងព័ត៌មានសម្ងាត់របស់អតិថិជន តាមរយៈទំនាក់ទំនង ប្រកបដោយតម្លាភាព ទំនុកចិត្ត និងការទទួលខុសត្រូវ។ លោកស្រី ធ្លាប់ជាអ្នកជំនាញស្រាវជ្រាវ ជាមួយអង្គការក្រៅ រដ្ឋាភិបាលជាច្រើន ហើយបានធ្វើការលើ គម្រោងអន្តរជាតិជាច្រើនដូចជា សាកលវិទ្យាល័យ John´s Hopkins សហរដ្ឋអាមេរិក, មូលនិធិ MacArthur និងផ្សេងៗទៀត។ លោកស្រី គឺជាមនុស្សមានសមត្ថភាពពិសេស ក្នុងការផ្សារភ្ជាប់យ៉ាងរលូនជាមួយមនុស្សមកពីគ្រប់មជ្ឈដ្ឋាន និងគ្រប់វ័យ។ លោកស្រី ជាប្រធានផ្នែកគ្រប់គ្រងការងារសង្គម ដោយប្រើបទពិសោធន៍របស់លោកស្រី ដើម្បីធ្វើឱ្យប្រាកដថា គ្រឹះស្ថានហិរញ្ញវត្ថុ ដែលជាដៃគូរបស់ Gojo មានការទទួលខុសត្រូវលើការងារសង្គម។ ដោយមានការណែនាំ និងការគាំទ្រយ៉ាងពេញទំហឹងរបស់លោកស្រី ម៉ាក់ស៊ីម៉ា បានទទួលវិញ្ញាបនបត្រការពារអតិថិជនពី Smart Campaign ក្នុងឆ្នាំ២០១៩ ។ ម៉ាក់ស៊ីម៉ា មានមោទនភាពដែលមានលោកស្រីជាប្រធានគណៈកម្មការគាំពារសង្គមរបស់ក្រុមប្រឹក្សាភិបាល។ ដោយមានក្តី ស្រឡាញ់ ការគោរព ភាពសប្បាយរីករាយ និងតន្ត្រី ទើបធ្វើឲ្យលោកស្រី ចង់ឱ្យពិភពលោកក្លាយជាទីកន្លែងដ៏ស្រស់បំព្រង។

## លោក ជេត ច័ន្ទប្រសើរ
### អភិបាល

លោក ជេត ច័ន្ទប្រសើរ បានចូលរួមជាមួយម៉ាក់ស៊ីម៉ានៅក្នុងខែធ្នូ ឆ្នាំ២០០០ ។ លោក ប្រសើរ បច្ចុប្បន្នជាសមាជិកក្នុងគណៈកម្មការហានិភ័យ និងជាសមាជិក ក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី។ លោក ប្រសើរ បានទទួល បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់ នៅសាកលវិទ្យាល័យបៀលប្រាយ នាឆ្នាំ ២០១០។ នៅក្នុងឆ្នាំ១៩៩៥ លោក ប្រសើរទទួលបានបរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្មពីមហាវិទ្យាល័យពាណិជ្ជសាស្ត្រ នៅកម្ពុជា។



**លោក ជេត ច័ន្ទប្រសើរ**
អភិបាល

---

## លោកបណ្ឌិត អៅ វ៉េង
### អភិបាលឯករាជ្យ

លោកបណ្ឌិត អៅ វ៉េង ជាសមាជិកឯករាជ្យក្រុមប្រឹក្សាភិបាល បានចូលរួមជាមួយក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានម៉ាក់ស៊ីម៉ា នាខែកញ្ញា ឆ្នាំ២០១៣ និងបច្ចុប្បន្ន លោក ជាប្រធានគណៈកម្មការសវនកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា។ លោកបណ្ឌិត អៅ វ៉េង បានបម្រើការងារជាសាស្ត្រាចារ្យនៅ សាកលវិទ្យាល័យ ន័រតុន និងជាសាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យ Western ពីឆ្នាំ២០០៦-២០១២។ លោក បានបម្រើការងារជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច វិទ្យាស្ថានហិរញ្ញវត្ថុកម្ពុជា និងសាកល វិទ្យាល័យ Western ចាប់តាំងពីឆ្នាំ២០១០។ លោកបណ្ឌិត អៅ វ៉េង បានទទួលសញ្ញាប័ត្របណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម (DBA) ពី សាកលវិទ្យាល័យ Western នៅក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ២០១០។ ក្នុងឆ្នាំ២០០២ លោក បានទទួលសញ្ញាបត្រអនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម ផ្នែកហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យន័រតុន និងសាកលវិទ្យាល័យ Ateneo de Zamboangan។ ក្នុងឆ្នាំ១៩៩៩ លោក បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររង ផ្នែកធនាគារពី វិទ្យាស្ថានសម្រាប់ការសិក្សាធនាគាររបស់ធនាគារជាតិ នៃកម្ពុជា ។ នៅឆ្នាំ១៩៩៦ លោកបានបញ្ចប់ដោយជោគជ័យបរិញ្ញាបត្រ ផ្នែកវិទ្យាសាស្ត្រ គណិតវិទ្យាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នៅក្នុងប្រទេសកម្ពុជា។



**លោកបណ្ឌិត អៅ វ៉េង**
អភិបាលឯករាជ្យ

## លោកបណ្ឌិត យាន ឫទ្ធី

### អភិបាលឯករាជ្យ



លោកបណ្ឌិត យាន ឫទ្ធី
អភិបាលឯករាជ្យ

លោកបណ្ឌិត យាន ឫទ្ធី បានចូលរួមជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ ជាមួយម៉ាក់ស៊ីម៉ានៅក្នុងខែមេសា ឆ្នាំ២០១២ ហើយក៏ជាប្រធាន គណៈកម្មការហានិភ័យ របស់ម៉ាក់ស៊ីម៉ា។ លោកបណ្ឌិត ធ្លាប់បានបម្រើការងារជាគណនេយ្យករជាន់ខ្ពស់ ក្រុមហ៊ុនសែលកម្ពុជាពីឆ្នាំ ១៩៩៣-២០០២។ លោកបណ្ឌិត បាន និងកំពុងបម្រើ ការងារជានាយកផ្នែកហិរញ្ញវត្ថុនៅក្រុមហ៊ុន ឌូហ្វ្រី តាំងពីឆ្នាំ ២០០២ រហូត ដល់ បច្ចុប្បន្ន។ លោកបណ្ឌិត ជាសមាជិកគណនេយ្យករគ្រប់គ្រង និងសមាជិកភាពនៃ វិទ្យាស្ថានគណនេយ្យករសាធារណៈ នៃប្រទេសអូស្ត្រាលី។ លោកបណ្ឌិតជា សមាជិកសកម្មនៃវិទ្យាស្ថាន គណនេយ្យ ករជំនាញកម្ពុជា។ ពីឆ្នាំ ២០០៣ រហូតដល់បច្ចុប្ប ន្ន លោកបណ្ឌិត ជាគ្រូបង្រៀនក្រៅម៉ោងនៅសាកលវិទ្យាល័យបៀលប្រាយ និងសាកលវិទ្យាល័យ វេស្ទើន។ លោកបណ្ឌិត ឫទ្ធី ទទួលបានសញ្ញាបត្របណ្ឌិតផ្នែកទីផ្សារ ពីសាកលវិទ្យាល័យ Preston នៅសហរដ្ឋអាមេរិកក្នុងឆ្នាំ២០០៧និងសញ្ញាបត្របណ្ឌិតទស្សនៈវិជ្ជាពីសាកលវិទ្យាល័យ European នៅប្រទេសស្វីសក្នុងឆ្នាំ២០១៣។ នៅក្នុងឆ្នាំ២០០៥ លោកបណ្ឌិតបានទទួលសញ្ញាបត្រអនុបណ្ឌិតគ្រប់គ្រងធុរកិច្ច (MBA) ជំនាញហិរញ្ញវត្ថុ និងគណនេយ្យ ពី សាកលវិទ្យាល័យ Preston នៅសហរដ្ឋអាមេរិក។ នៅក្នុងឆ្នាំ១៩៩៨ លោកបណ្ឌិត បានទទួលបរិញ្ញាបត្រគ្រប់គ្រងធុរកិច្ច ជំនាញធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ Irish ប្រទេសអៀរឡង់។

## លោក ប៉ា ប៉ុណ្ណរិទ្ធី

### អភិបាល



លោក ប៉ា ប៉ុណ្ណរិទ្ធី
អភិបាល

លោក ប៉ា ប៉ុណ្ណរិទ្ធី ជាសមាជិកក្រុមប្រឹក្សាភិ បាល និងជាអគ្គនាយក បានចូលរួមជាមួយម៉ាក់ស៊ីម៉ា នៅក្នុងខែធ្នូ ឆ្នាំ ២០០០។ មុនពេលលោ កចូលរួមជាមួយ ម៉ាក់ស៊ីម៉ា លោក ប៉ុណ្ណរិទ្ធី បានបម្រើការងារជាជំនួយការគណនេយ្យ និងរដ្ឋបាលនៅ អង្គការ LWS នៅខេត្តកំពង់ស្ពឺ (១៩៩៨-២ ០០០) ប្រធានគ ណនេយ្យនៅធនាគារពាណិជ្ជ P acific Commercial Bank (១៩៩៥- ១៩៩៨) អនុ ប្រធានការិយាល័យឥណ ទា ន នៃធនាគារជាតិ នៃកម្ពុជា នៅខេត្តកំពត (១៩៨០-១៩៩៥)។ លោក ប៉ុណ្ណរិទ្ធី ទទួលបានបរិញ្ញាបត្រគណនេយ្យហិរញ្ញវត្ថុ និងធនាគារ នៅក្នុង ឆ្នាំ១៩៨៦ នៅក្នុង ប្រទេសកម្ពុជា។ លោក ប៉ុណ្ណរិទ្ធី អាចប្រើប្រាស់ភាសាខ្មែរ និងភាសាអង់គ្លេសបានយ៉ាងល្អ។ លោក ប៉ុណ្ណរិទ្ធី ដឹកនាំក្រុមការងារជាមួយនឹងការស្រលាញ់ និងតម្លាភាព។

# គណៈកម្មការរបស់ក្រុមប្រឹក្សាភិបាល

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី មានគណៈកម្មការរបស់ក្រុមប្រឹក្សាភិបាលចំនួន បី ដែលបានណែនាំ និងផ្តល់នូវអភិបាលកិច្ចរួមមាន គណៈកម្មការសវនកម្ម គណៈកម្មការហានិភ័យ និងគណៈកម្មការគាំពារសង្គម។ គណៈកម្មការនីមួយៗ បានបំពេញមុខងារសំខាន់ៗ ក្នុងដំណើរការប្រតិបត្តិរបស់ គ្រឹះស្ថានមីក្រូ ហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី ដោយបានរក្សាប្រយោជន៍អតិថិជនសម្រាប់រាល់ការសម្រេចចិត្តនានា។

## គណៈកម្មការសវនកម្ម

### គណៈកម្មការសវនកម្មទទួលខុសត្រូវដូចខាងក្រោម៖

- បង្កើត និងត្រួតពិនិត្យអនុលោមភាពជាមួយក្រមសីលធម៌សាជីវកម្ម
- ត្រួតពិនិត្យនីតិវិធីអនុលោមតាមបទបញ្ញារដ្ឋាភិបាល
- ពិនិត្យឡើងវិញនូវការរកឃើញរបស់សវនកម្ម ឬការត្រួតពិនិត្យដែលបានធ្វើឡើងដោយភ្នាក់ងារផ្សេងទៀត។
- ពិនិត្យមើលលើមតិយោបល់របស់សវនករខាងក្រៅលើអំណាចតួនាទីបុគ្គលិកគណនេយ្យនិងហិរញ្ញវត្ថុ និងសវនករផ្ទៃក្នុងរបស់ គ្រឹះស្ថាន
- ពិនិត្យឡើងវិញនូវភាពគ្រប់គ្រាន់នៃរចនាសម្ព័ន្ធការត្រួតពិនិត្យផ្ទៃក្នុងលើរបាយការណ៍ហិរញ្ញវត្ថុ
- ត្រួតពិនិត្យលើការត្រួតពិនិត្យផ្ទៃក្នុង របស់ក្រុមហ៊ុន សម្រាប់ការពារទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន វាយតម្លៃគោលបំណងសវនករផ្ទៃក្នុង
- ពិនិត្យការងាររបស់សវនករផ្ទៃក្នុង និងវាយតម្លៃការអនុវត្តន៍ និងការកសាងសមត្ថភាព
- ធានាថាការចូលរួមរបស់សវនករផ្ទៃក្នុងនៅក្នុងដំណើរការសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់សវនករខាងក្រៅដំណើរការដោយ មានការសហការគ្នាល្អជាមួយសវនករខាងក្រៅ។

### សកម្មភាព និងសមិទ្ធផលសម្រាប់ឆ្នាំ២០២០៖

គណៈកម្មការសវនកម្មបានជួបប្រជុំគ្នាចំនួន ២ដងក្នុងឆ្នាំ២០២០

- នៅក្នុងកិច្ចប្រជុំនៅក្នុងឆ្នាំ២០២០ គណៈកម្មការបានអនុម័ត
  - -គម្រោងផែនការ ការអនុវត្តការងារសវនកម្មផ្ទៃក្នុង កាលវិភាគ សម្រាប់ឆ្នាំ ២០២០
  - -វិធីជ្រើសរើសគំរូ និងគោលបំណងការងារ
  - -នីតិវិធីថ្មីនៃការធ្វើសវនកម្ម
  - -របាយការណ៍ប្រចាំឆ្នាំរបស់សវនកម្មផ្ទៃក្នុង
  - -របាយការណ៍ត្រួតពិនិត្យ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រចាំឆ្នាំជូនធនាគារជាតិ
- បានផ្តល់យោបល់លើគំរូនៃការធ្វើសវនកម្មផ្ទៃក្នុង
- ត្រួតពិនិត្យឡើងវិញនូវរាល់សកម្មភាពប្រតិបត្តិការ អាជីវកម្ម និងដើរការគ្រប់គ្រងសំខាន់ៗ ត្រូវបានធ្វើសវនកម្ម ដោយយោងតាមវិធីសាស្ត្រដោយផ្អែកលើហានិភ័យ។
- សវនកម្មផ្ទៃក្នុងបានពិភាក្សាពីលទ្ធផលនៃការវាយតម្លៃទាំងអស់ ជាមួយថ្នាក់គ្រប់គ្រង និងរាយការណ៍ អំពីការសង្កេត/ការរកឃើញ អនុសាសន៍និងយោបល់នានា តាមរយៈរចនាសម្ព័ន្ធដែលមានស្រាប់។

## គណៈកម្មការហានិភ័យ

គណៈកម្មាធិការហានិភ័យ បានចាប់ផ្តើមអនុវត្តកិច្ចការ ប្រកដដោយប្រសិទ្ធភាពពីខែកុម្ភៈឆ្នាំ២០១៤ដោយមានការចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យ។ គណៈកម្មការនេះ ទទួលខុសត្រូវចំពោះមុខ ក្រុមប្រឹក្សាភិបាល និងតម្រូវឲ្យអនុវត្តការងារដូចខាងក្រោម៖

- ត្រួតពិនិត្យ និងតាមដាននូវទិដ្ឋភាពផ្សេងៗនៃការគ្រប់គ្រងហានិភ័យដោយឈរលើមូលដ្ឋានរួម និងត្រួតពិនិត្យឡើងវិញជាប្រចាំនូវហានិភ័យសំខាន់ធំៗ របស់ម៉ាក់ស៊ីម៉ា រួមមាន ហានិភ័យឥណទាន ហានិភ័យទីផ្សារ ហានិភ័យប្រតិបត្តិការ ហានិភ័យអត្រាការប្រាក់ហានិភ័យសន្ទនីយភាព ហានិភ័យច្បាប់បទប្បញ្ញត្តិ និងប្រតិបត្តិតាម ហានិភ័យនៃការអនុវត្តន៍ យុទ្ធសាស្ត្រ ហានិភ័យកេរ្តិ៍ឈ្មោះ ហានិភ័យបច្ចេកវិជ្ជាព័ត៌មាននិងសន្តិសុខប្រព័ន្ធនិងហានិភ័យផ្សេងៗទៀតដែលម៉ាក់ស៊ីម៉ាអាចនឹងធ្វើការត្រួតពិនិត្យតាមដានជាប្រចាំ។
- ពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍សម្រាប់ការអនុម័ត របស់ក្រុមប្រឹក្សាភិបាល លើក្របខ័ណ្ឌ គ្រប់គ្រងហានិភ័យ និងយុទ្ធសាស្ត្រការកំណត់កម្រិតហានិភ័យ និងការទទួលយក (រួមទាំងរបាយការណ៍នៃកម្រិតហានិភ័យ និងការទទួលយក) របស់ម៉ាក់ស៊ីម៉ា ។
- ពិនិត្យ និងអនុម័តចំពោះអតិថិជនដែលមានកម្រិតហានិភ័យខ្ពស់ពាក់ព័ន្ធនឹងការសម្អាតប្រាក់ និងការយកចិត្តទុកដាក់ ស្គាល់អតិថិជន ។
- ធានាឲ្យមាននូវ ហេដ្ឋារចនាសម្ព័ន្ធ ធនធាន និងប្រព័ន្ធ សមស្របមួយ សម្រាប់គ្រប់គ្រងហានិភ័យ ។
- ពិនិត្យឡើងវិញ និងសិក្សាលើលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិ និង/ឬយោបល់របស់និយ័តករ លើបញ្ហាទាក់ទងនឹងការគ្រប់គ្រងហានិភ័យ របស់ម៉ាក់ស៊ីម៉ា និងធានាតាមដានដោយសមស្របមួយ លើផែនការសកម្មភាព ដែលបានដាក់ចេញឲ្យបានទាន់ពេលវេលាដើម្បីកម្រិតលក្ខខណ្ឌតម្រូវ និង/ឬ ភាពកង្វះខាតនៃត្រួតពិនិត្យដូចដែលបានកំណត់ដោយនិយ័តករ ។
- ពិនិត្យឡើងវិញនូវលទ្ធផលនៃការធ្វើតេស្តស្រ្តេសចំពោះហានិភ័យសំខាន់ធំៗ របស់ ម៉ាក់ស៊ីម៉ា និងការវាយតម្លៃលើសមត្ថភាពក្នុងការទប់ទល់ នឹងស្ថានភាពស្រ្តេសចំពោះប្រាក់ចំណេញ ភាពគ្រប់គ្រាន់ដើមទុន និងសាច់ប្រាក់ស្រួល និងក្នុងករណីចាំបាច់ធ្វើការផ្តួចផ្តើម/បង្កើតសកម្មភាពសមស្របដែលនឹងត្រូវដាក់ចេញដោយថ្នាក់គ្រប់គ្រង ដើម្បីកាត់បន្ថយផលប៉ះពាល់ដែលមានសក្តានុពល។
- ទទួល និងពិនិត្យឡើងវិញនូវរបាយការណ៍ប្រចាំត្រា អំពីហានិភ័យវប្បធម៌ ការប៉ះពាល់ និងការគ្រប់គ្រងហានិភ័យផលប័ត្រ របស់ ម៉ាក់ស៊ីម៉ា ។
- ពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍លើរបាយការណ៍ត្រួតពិនិត្យឥណទានដោយឯករាជ្យ របស់ ម៉ាក់ស៊ីម៉ា ។
- ពិចារណាលើបញ្ហាផ្សេងៗ តាមតួនាទី ដែលបានកំណត់ និងប្រគល់ជូនដោយក្រុមប្រឹក្សាភិបាល ។
- ពិនិត្យឡើងវិញ និងផ្តល់អនុសាសន៍លើផែនការរបស់នាយកដ្ឋានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម របស់ ម៉ាក់ស៊ីម៉ា ។
- ពិនិត្យមើលប្រតិបត្តិការទាំងអស់ដែលពាក់ព័ន្ធនឹងគោលនយោបាយវិស្សលប្តូរឹង ។

## គណៈកម្មការគាំពារសង្គម

### គណៈកម្មការនេះ តម្រូវឱ្យអនុវត្ត ការងារដូចខាងក្រោម៖

- អភិវឌ្ឍ និងត្រួតពិនិត្យដំណើរការកិច្ចគាំពារសង្គមនៅ ម៉ាក់ស៊ីម៉ា
- បង្កើនការយល់ដឹងទាក់ទងនឹងកិច្ចគាំពារសង្គម សម្រាប់បុគ្គលិកគ្រប់កម្រិតនៅ ម៉ាក់ស៊ីម៉ា
- តាមដានដំណើរការរបស់អង្គភាព ចំពោះការទទួលខុសត្រូវចំពោះអតិថិជន
- តាមដានដំណើរការរបស់អង្គភាព ចំពោះការទទួលខុសត្រូវចំពោះបុគ្គលិក
- រៀបចំគម្រោង និងរៀបចំកម្មវិធីសង្គម សកម្មភាពផ្សេងៗ និងកម្មវិធីសម្រាប់អតិថិជន
- រៀបចំវគ្គបណ្តុះបណ្តាល ដើម្បីបង្កើនការយល់ដឹងរបស់ស្ថាប័នពី កិច្ចគាំពារសង្គមនិងគោលការណ៍ គាំពារអតិថិជន

### សកម្មភាពនិងសមិទ្ធផលសម្រាប់ឆ្នាំ២០២០៖

- ដើម្បីការពារជំងឺរាតត្បាត កូវីដ១៩ ម៉ាក់ស៊ីម៉ា បានផ្តល់ជូននូវសម្ភារៈដូចជា ម៉ាស របាំងការពារមុខ ទឹកអាកុល ដល់បុគ្គលិករបស់ខ្លួន ដើ ម្បីសុវត្ថិភាព ហើយបុគ្គលិកត្រូវលាងដៃ និងត្រូវត្រួតពិនិត្យសីតុណ្ហភាពរបស់ពួកគេមុនពេលចូលធ្វើការ។ បុគ្គលិកគ្រប់រូបចាំបាច់ត្រូវពាក់ម៉ាស់ និងរបាំងការពារមុខការពារមុខហើយក៏ត្រូវរក្សាការគម្លាតសង្គមក្នុងម៉ោងធ្វើការផងដែរ។
- រៀបចំឱ្យមានការលេងកីឡាផ្សេងដូចជា បាល់ទាត់ ពីងប៉ុង ដើម្បីលើកកម្ពស់សុខភាពបុគ្គលិក

សហការជាមួយនឹងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាដែលមានដៃគូរជាមួយ នឹង ADA និង Good Return ដែលមានគោលបំណងជួយសម្រួលដល់ ការផ្តល់ការអប់រំចំណេះដឹងហិរញ្ញវត្ថុដោយ ផ្តល់គុណតម្លៃបន្ថែមដល់អតិថិជនរបស់យើងដើម្បីធានាបាននូវការរីកចម្រើនប្រកបដោយចីរភាព។

- បានសម្របសម្រួលលើការផ្តល់ឥណទានទឹកស្អាត និងអនាម័យ ដល់អតិថិជនចំនួនជាង ៦០០ គ្រួសារ ផលបត្រចំនួន ២.៤ លានដុល្លារអាមេរិក។
- បានសហការជាមួយ Smart Campaign ដើម្បីអនុវត្តគម្រោងសម្លេងអតិថិជន(VoC) ដើម្បីឆ្លុះបញ្ចាំងពីការអនុវត្តគោលការណ៍ការពារអតិថិជន។
- ក្រោមយុទ្ធនាការបៃតងកម្ពុជា នៅឆ្នាំនេះយើងផ្តោតទៅលើការថែទាំក្រោយការដាំដើមឈើកាលពីឆ្នាំមុន។ យើងទទួលបាននូវបទពិសោធន៍ដ៏គួរឱ្យចាប់អារម្មណ៍មួយចំនួនដែលបានមកពីគម្រោងនេះ។
- សម្របសម្រួល និងតាមដានការអនុវត្តន៍" គោលនយោបាយបណ្តឹងតវ៉ាអតិថិជន" ដើម្បីរំលឹកដល់បុគ្គលិកអំពីការអនុវត្តន៍គោលការណ៍អោយមានប្រសិទ្ធភាព។

# គណៈគ្រប់គ្រង

គណៈគ្រប់គ្រង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី រួមមានៈ អគ្គនាយក នាយិកាប្រតិបត្តិ ហិរញ្ញវត្ថុ ជំនួយការអគ្គនាយក និងប្រធាននាយកដ្ឋានទាំងអស់។ អគ្គនាយក នាយិកាប្រតិបត្តិហិរញ្ញវត្ថុ និងជំនួយការអគ្គនាយក សហការការងារយ៉ាងជិតស្និទ ជាមួយ ប្រធាននាយកដ្ឋានឥណទានប្រធាននាយកដ្ឋានព័ត៌មានវិទ្យាប្រធាននាយកដ្ឋានម៉ាឃីតធីងនិងគាំពារសង្គមប្រធាននាយកដ្ឋានធនធានមនុស្ស ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានឌីជីថល។



**លោក ប៉ា ប៉ុណ្ណរិទ្ធី**
អគ្គនាយក

**លោក ប៉ា ប៉ុណ្ណរិទ្ធី** ជាអគ្គនាយក បានចូលរួមជាមួយម៉ាក់ស៊ីម៉ា នៅក្នុងខែធ្នូ ឆ្នាំ២០០០។ មុនពេលលោកចូលរួមជាមួយម៉ាក់ស៊ីម៉ា លោក ប៉ុណ្ណរិទ្ធី បានបម្រើការងារជាជំនួយការគណនេយ្យ និង រដ្ឋបាលនៅអង្គការLWSនៅខេត្តកំពង់ស្ពឺ(១៩៩៨-២០០០) ប្រធានគណនេយ្យ នៅធនាគារពាណិជ្ជ Pacific Commercial Bank (១៩៩៥-១៩៩៨) អនុប្រធានការិយាល័យឥណទាននៃ ធ នាគារជាតិ នៃកម្ពុជា នៅខេត្តកំពត (១៩៨០-១៩៩៥)។ លោក ប៉ុណ្ណរិទ្ធី ទទួលបានបរិញ្ញ ញាបត្រគណនេយ្យហិរញ្ញវត្ថុ និងធនាគារ នៅ ក្នុ ង ឆ្នាំ១៩៨៦ នៅក្នុងប្រទេសកម្ពុជា។ លោក ប៉ុណ្ណរិទ្ធី អាចប្រើប្រាស់ភាសាខ្មែរ និងភាសាអង់គ្លេសបានយ៉ាងល្អ។ លោក រិទ្ធី ដឹកនាំក្រុមការងារជាមួយនឹងការស្រលាញ់និងតម្លាភាព។សម្រាប់បុគ្គលិកដែលស្គាល់ លោក រិទ្ធី ជាច្រើនឆ្នាំបានហៅថាលោកជាពូដែលមានន័យដូច ឪពុក។



**លោកស្រី ស្រេង ស៊ីវឆេង**
នាយិកាប្រតិបត្តិហិរញ្ញវត្ថុ

**លោកស្រី ស្រេង ស៊ីវឆេង** ជានាយិកាប្រតិបត្តិហិរញ្ញវត្ថុ និងបានចូលរួមបង្កើត ម៉ាក់ស៊ីម៉ា ដែលបានចាប់ផ្តើមដំណើរការ នៅក្នុងឆ្នាំ២០០០។ លោកស្រី ស៊ីវឆេង ធ្លាប់បានបម្រើការងារជាប្រធានផ្នែកផ្ទេរប្រាក់នៅ ធនាគារសន្តិភាពពាណិជ្ជ Pacific Commercial Bank ពីឆ្នាំ១៩៩៥-២០០០។ លោកស្រី ស៊ីវឆេង បានបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ លើជំនាញគ្រប់គ្រងហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅភ្នំពេញ ក្នុងខែកញ្ញាឆ្នាំ២០១៦។ នៅឆ្នាំ២០ ០ ១ លោកស្រី ស៊ីវឆេង ទទួលបានបរិញ្ញា ប ត្រគ្រប់គ្រងពាណិជ្ជ កម្មពី វិទ្យាស្ថានជា តិគ្រ ប់គ្រង។ លោកស្រី ស៊ីវឆេង អាច ប្រើប្រាស់ភាសា ខ្មែរ អង់គ្លេស និងថៃ បានយ៉ាងស្ទាត់ជំនាញ។ បុគ្គលិកគ្រប់គ្នាចូលចិត្តហៅថា បង ឆេង ជាបង្គោលរឹងមាំសម្រាប់ ម៉ាក់ស៊ីម៉ា និងតែងតែយកចិត្តទុកដាក់សម្រាប់បុគ្គលិកទាំងអស់។



**លោក Tomohiro Isozaki**
ជំនួយការអគ្គនាយក

**លោក Tomohiro Isozaki** ជាតំណាងប្រចាំប្រទេសកម្ពុជានៃក្រុមហ៊ុន Gojo & Company, Inc. នៅឆ្នាំ២០១៨ និងបា នក្លាយជាជំនួយការអគ្គនាយក របស់ ម៉ាក់ស៊ីម៉ា ក្នុងឆ្នាំ២០១៩។ កាលពី មុន លោក បាន ធ្វើ ការនៅក្រុមហ៊ុន Mitsui & CO, LTD និង McKinsey។ លោកបានទ ទួល បរិញ្ញាប ត្រសង្គមវិទ្យា ពីសាកលវិទ្យាល័យតូក្យូ។ គាត់អាចប្រើប្រាស់ភាសាអង់គ្លេស និងភាសាជប៉ុន បានយ៉ាងស្ទាត់ជំនាញ។

**លោក ច៉យ ស៊ិន** ជាប្រធាននាយកដ្ឋានឥណទាន នៅម៉ាក់ស៊ីម៉ា។ លោក បានចូលបម្រើការងារនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា នៅឆ្នាំ២០១៥ ជាអនុប្រធាននាយកដ្ឋាន និងត្រូវតែងតាំងជាប្រធាននាយកដ្ឋានឥណទាន នៅឆ្នាំ២០១៧។ មុនពេលចូលបម្រើការងារនៅ ម៉ាក់ស៊ីម៉ា លោក បានបម្រើការងារជាច្រើនមុខតំណែងដូចជា គ្រូបង្រៀនភាសាអង់គ្លេស និងជានាយកសាខា នៅមជ្ឈមណ្ឌលបណ្ដុះបណ្ដាល។ លោក បានបម្រើការងារ ជាមន្ត្រីឥណទាន ជាគ្រូបណ្ដុះបណ្ដាលផ្នែកផលិតផលឥណទាន និងសេវាកម្មហិរញ្ញវត្ថុ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត។ លោក ស៊ិន បានទទួលបរិញ្ញាបត្រផ្នែក ធនាគារ និងហរិញ្ញវត្ថុ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង និងទទួលបាន សញ្ញាបត្រអនុបណ្ឌិតពាណិជ្ជកម្ម ពីសាកលវិទ្យាល័យន័រតុន នៅភ្នំពេញ។ ក្រៅពីនេះ លោកបានចូលរួម វគ្គបណ្ដុះបណ្ដាល ជាមួយគ្រូបណ្ដុះបណ្ដាលទាំង ជាតិ និងអន្តរជាតិ។ លោក ស៊ិន អាចប្រើប្រាស់ភាសាអង់គ្លេស និងខ្មែរ បានយ៉ាងស្ទាត់ជំនាញ។ លោក ស៊ិន បានគាំទ្រក្រុមការងារ ដើម្បីឱ្យពួកគេទទួលបានលទ្ធផលការងារល្អ សម្រាប់ខ្លួនឯង សម្រាប់ស្ថាប័ន និងភាគច្រើនសម្រាប់អតិថិជន របស់ពួកគេ។



**លោក ច៉យ ស៊ិន**
ប្រធាននាយកដ្ឋានឥណទាន

**លោកហោមុន្នីដារិទ្ធ**ជាសហប្រធាននាយកដ្ឋានឥណទាន។គាត់បានធ្វើការនៅម៉ាក់ស៊ីម៉ាតាំងពីឆ្នាំ២០០៨។គាត់បានចាប់ផ្ដើមធ្វើការនៅក្នុងមុខតំណែងដំបូងជាមន្ត្រីឥណទានបន្ទាប់មកត្រូវបានតំឡើងឋានៈ ជាប្រធានមន្ត្រីឥណទានអនុប្រធានសាខាបន្ទាប់មកត្រូវបានតំឡើងឋានៈ ជាអនុប្រធាននាយកដ្ឋានឥណទាន ក្នុងឆ្នាំ២០១៧។ ក្រោយមកក្លាយ ជាប្រធាននាយកដ្ឋានឥណទានស្ដីទីនៅឆ្នាំ២០១៩។មុនពេលចូលរួមជាមួយម៉ាក់ស៊ីម៉ា លោកមុន្នីដារិទ្ធ ធ្លាប់ធ្វើជាជំនួយការចុះឈ្មោះបោះឆ្នោតជាតិ និងជាសមាជិករៀបចំការបោះឆ្នោតជាតិ។ គាត់បានចូលរួមវគ្គបណ្ដុះបណ្ដាលជាច្រើន ជាមួយនឹងគ្រូបណ្ដុះបណ្ដាលជាតិ និងអន្តរជាតិ។ លោក មុនីដារិទ្ធ បានទទួល បរិញ្ញាបត្រផ្នែកគ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច ពីសាកលវិទ្យាល័យបៀលប្រាយ និងសញ្ញាបត្រភាសាអង់គ្លេសជាន់ខ្ពស់ ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា។គាត់ជាមនុស្សពិសេសម្នាក់ដែលតែងតែបង្កើតបរិយាកាសរីករាយ និងជាធនធានប្រតិ បត្តិការដ៏ល្អមួយ នៅម៉ាក់ស៊ីម៉ា ហើយគាត់បានប្ដេជ្ញាដឹកនាំប្រតិបត្តិការតាមរបៀបដ៏ល្អផងដែរ។



**លោក ហោ មុន្នីដារិទ**
សហប្រធាននាយកដ្ឋានឥណទាន

**លោក យ៉ន រ៉ា** ជាសហ ប្រធាននាយកដ្ឋានឥណទាននៅម៉ាស៊ីម៉ា។ គាត់បានធ្វើការនៅម៉ា ក់ ស៊ី ម៉ា ចាប់ តាំងពីឆ្នាំ២០០៨។ គាត់បានចាប់ផ្ដើមធ្វើការនៅក្នុងមុខតំណែង ដំបូងជាម ន្ត្រី ឥ ណ ទានបន្ទាប់មកគាត់ត្រូវបានតំឡើងឋានៈជាជំនួយការនាយកឥណទានចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១២។ បន្ទាប់មកគា ត់ត្រូវបានតំឡើងឋានៈជាប្រធានសាខាកៀនស្វាយ។ ជាថ្មីម្ដងទៀតនៅឆ្នាំ២០១៨គាត់ត្រូវបានតំឡើងឋានៈជាអនុប្រធាននាយកដ្ឋានឥណទាននិងបានក្លាយជាប្រធាននាយក ដ្ឋានឥណទានស្ដីទី នៅឆ្នាំ២០១៩ មុនពេលចូលកាន់តំណែងបច្ចុប្បន្ន។ មុនពេលចូលបម្រើ ការងារជាមួយម៉ាក់ស៊ីម៉ា លោកធ្លាប់ធ្វើការជាអ្នកលក់ឱ្យក្រុមហ៊ុន ៨៨៨ សាជីវកម្ម ខូអិលធីឌី ចាប់ពីឆ្នាំ២០០៦-២០០៧។ លោក រ៉ា បានទទួលបរិញ្ញាបត្រទីផ្សារ ពី សាកលវិទ្យាល័យអាស៊ីអឺរ៉ុប និងបានទទួលសញ្ញាបត្រអនុបណ្ឌិតគ្រប់គ្រងហិរញ្ញវត្ថុពីសាកលវិទ្យាល័យភូ មិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ក្រៅពីមុខវិជ្ជាទាំងនេះគាត់បានចូលរួមវគ្គបណ្ដុះបណ្ដាលខ្លីៗជាច្រើន ជាមួយគ្រូបណ្ដុះបណ្ដាលជាតិ និងអន្តរជាតិ។ គាត់អាចប្រើប្រាស់ភាសាអង់គ្លេស និងភាសាខ្មែរបានយ៉ាងល្អ។ គាត់ជាធនធានពិសេសមួយក្នុងប្រតិបត្តិការហើយគាត់មានមហិច្ឆិតាខ្ពស់បំផុត ដើម្បីជំរុញម៉ាក់ស៊ីម៉ា តាមមាគ៌ាប្រកបដោយចីរភាព។



**លោក យ៉ន រ៉ា**
សហប្រធាននាយកដ្ឋានឥណទាន

**លោក សុខ កុសល** ជាប្រធាននាយកដ្ឋានឌីជីថល។ មុនមុខតំណែងនេះ គាត់ជាអនុប្រធាននាយកដ្ឋានឥណទានទទួលបន្ទុកការងារគ្រប់គ្រងតំបន់។ គាត់បានធ្វើការនៅម៉ាក់ស៊ីម៉ា តាំងពីឆ្នាំ២០១១។ ការងារដំបូងគាត់គឺធ្វើជាមន្ត្រីឥណទានបន្ទាប់ មកត្រូវបានតំឡើងឋានៈ ជាប្រធានការិយាល័យទំនាក់ទំនង ចោមចៅក្នុងឆ្នាំ២០១៥។ គាត់បានដឹកនាំនៅទីនោះអស់រយៈពេល២ឆ្នាំ បន្ទាប់មកបានតំឡើងឋានៈ ជាអនុប្រធាននាយកដ្ឋានឥណទាន ទទួលខុសត្រូវលើ ការគ្រាំទ្រការផ្តល់ប្រាក់កម្ចី។ គាត់ធ្លាប់ជាគ្រូបង្រៀនភាសាអង់គ្លេស និងទទួលបានការបណ្តុះបណ្តាលជាច្រើន ពីគ្រូបណ្តុះបណ្តាលជាតិ និងអន្តរជាតិ ដូចជា "ការផ្តល់ប្រាក់កម្ចីខ្នាតតូច និងមធ្យម" ដោយវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុកម្ពុជា និង Advance Excel & Google slide សម្រាប់ការធ្វើអាជីវកម្ម ដោយក្រុមហ៊ុន Gojo។ គាត់ទទួលបានបរិញ្ញាបត្រគ្រប់គ្រងពីសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ លោក កុសល អាចប្រើប្រាស់ ភាសាអង់គ្លេស និងភាសាខ្មែរ បានយ៉ាងល្អ។ អ្វីដែលគាត់ចូលចិត្តបំផុតការគឺខិតខំប្រឹងប្រែងដើម្បីឧត្តមភាព។



**លោក សុខ កុសល**
ប្រធាននាយកដ្ឋានឌីជីថល

---

**លោកស្រី ស៊ឹម សោភណា** ជាប្រធាននាយកដ្ឋានធនធានមនុស្ស។ លោកស្រីបាន ចូល បម្រើការងារនៅម៉ាក់ស៊ីម៉ាក្នុងខែតុលាឆ្នាំ២០១៥។ មុនពេលចូលបម្រើការងារ នៅ ម៉ាក់ស៊ីម៉ាលោកស្រីធ្លាប់បម្រើការងារជាមន្ត្រីអភិវឌ្ឍន៍ សមត្ថភាព បុគ្គលិកនៅគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ អម្រឹត និងជានាយកការិយាល័យនៅ ក្រុមហ៊ុន AZISAFE Co., Ltd. ។ លោកស្រី បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែក គ្រប់គ្រងពីសាកលវិទ្យាល័យបញ្ញាសាស្ត្រ បានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកហិរញ្ញវត្ថុ និងធនាគារ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកភាសាអង់គ្លេសសម្រាប់ពាណិជ្ជកម្ម ពីសាកលវិទ្យាល័យមេគង្គកម្ពុជា។ លោកស្រី សោភណា អាចប្រើប្រាស់ភាសាខ្មែរ និងភាសាអង់គ្លេសបានយ៉ាងល្អ។ ជាប្រធាននាយកដ្ឋានធនធានមនុស្សលោកស្រី សោភណា បានធ្វើការយ៉ាងហ្មត់ចត់ ដើ ម្បីរក្សាបាននូវសេចក្តីទុកចិត្ត និងការគោរពពីបុគ្គលិក។ លោកស្រី យកចិត្តទុកដាក់ក្នុងការរៀនសូត្រ និងអភិវឌ្ឍន៍ជំនាញជាប្រចាំ។ លោកស្រី យកចិត្តទុកដាក់ជាមួយបុគ្គលិក និងផ្តល់ឱកាសសម្រាប់ការរៀនសូត្រ និងរីកចម្រើនជាមួយ ម៉ាក់ស៊ីម៉ា។



**លោកស្រី ស៊ឹម សោភណា**
ប្រធាននាយកដ្ឋានធនធានមនុស្ស

---

**លោកស្រី ឡាយ ស៊ីនាថ** ជាប្រធាននាយកដ្ឋានរដ្ឋបាល នៅម៉ាក់ស៊ីម៉ា។ លោកស្រីគឺជាបុគ្គលិកដំបូងគេបង្អស់របស់ ម៉ាក់ស៊ីម៉ា ។ លោកស្រី ស៊ីនាថ បានចូល បម្រើការងារនៅ ម៉ាក់ស៊ីម៉ា ក្នុងឆ្នាំ២០០១។ លោកស្រី ស៊ីនាថ បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ឯកទេស ផ្នែកគណនេយ្យ នៅវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ ប្រទេសកម្ពុជាក្នុងឆ្នាំ២០០៦។ លោកស្រី ស៊ីនាថ អាចប្រើប្រាស់ភាសាខ្មែរ និងភាសាអង់គ្លេស បានយ៉ាងល្អ។ លោកស្រី ស៊ីនាថ មានថាមពលក្នុងការបំពេញការងារសម្រាប់ម៉ាក់ស៊ីម៉ា និងទទួលបានការស្រលាញ់ រាប់អានពីអ្នកគ្រប់គ្នាសម្រាប់ការជួយសម្របសម្រួលក្នុងការងាររបស់លោកស្រី។



**លោកស្រី ឡាយ ស៊ីនាថ**
ប្រធាននាយកដ្ឋានរដ្ឋបាល

**លោក យាន ដារិទ្ធ** ជាប្រធាននាយកដ្ឋានព័ត៌មានវិទ្យា នៅម៉ាក់ស៊ីម៉ា។ លោក ដារិទ្ធ បាន ចូលបម្រើការងារនៅម៉ាក់ស៊ីម៉ាក្នុងឆ្នាំ២០០៩។លោក ដារិទ្ធ បានទទួល បរិញ្ញាបត្រ វិទ្យាសាស្ត្រកុំព្យូទ័រ ពីសាកលវិទ្យាល័យឯកទេសនៃកម្ពុជា និងបរិញ្ញាបត្ររងផ្នែកអេឡិចត្រូនិចពី វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ។ ក្នុងឆ្នាំ ២០១៥ លោក ដារិទ្ធ បានបញ្ចប់វគ្គសិក្សាស្តីពី IT Assurance and Security Audit នៅវិទ្យាស្ថាន Sunrise ។ លោក ដារិទ្ធ អា ចប្រើប្រាស់ ភាសាខ្មែរ និងភាសាអង់គ្លេសបានយ៉ាងល្អ។ លោក ដារិទ្ធ បានខិត ខំ បំ ពេ ញការងារក្នុងការរៀបចំទិន្នន័យរបស់ម៉ាក់ស៊ីម៉ា និងទិន្នន័យរបស់អតិថិជនឱ្យមា នរបៀ បរៀបរយ និងមានសុវត្ថិភាព និងជាពិ សេ សលោកតែងតែមានទឹកមុខញញឹមជានិច្ច។ លោកជាធនធានដ៏សំខាន់ និងតែងតែជួយមិត្តរួមការងារ។



**លោក យាន ដារិទ្ធ**
ប្រធាននាយកដ្ឋានព័ត៌មានវិទ្យា

---

**លោក ខៀវ សេងឌី** បានចូលបម្រើការងារនៅម៉ាក់ស៊ីម៉ា ក្នុងខែមិថុនា ឆ្នាំ២០០៦ បច្ចុប្បន្ននេះលោកជា ប្រធាននាយកដ្ឋាន ម៉ាឃីតធីង និងគាំពារសង្គម។ លោក សេងឌី ធ្លាប់ជានាយករងនាយកដ្ឋានឥណទាន នៅក្នុងឆ្នាំ២០១៤ និងជាប្រធានសាខា (២០១១-២០១៣) នៅម៉ាក់ស៊ីម៉ា។ លោក សេងឌី ទទួលបានសញ្ញាបត្រអនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្មពី សាកលវិទ្យាល័យន័រតុននៅឆ្នាំ២០១៧។ លោក បានទទួលបរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគ្រប់គ្រង ពីសាកលវិទ្យាល័យធនធានមនុស្ស នៅក្នុងឆ្នាំ២០០៩។ លោ ក សេងឌី អាចប្រើប្រាស់ភាសាខ្មែរ និងភាសាអង់គ្លេស បានយ៉ាងល្អ ហើយក្នុងរយៈពេលក្រោយមក លោក តែងតែអភិវឌ្ឍជំនាញ រួមទាំងភាសាអង់គ្លេស និងការគ្រប់គ្រងការងារសង្គមផងដែរ។



**លោក ខៀវ សេងឌី**
ប្រធាននាយកដ្ឋានម៉ាឃីតធីង និងគាំពារសង្គម

---

**លោកស្រី ខេង សុម៉ាលី** ជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ម៉ាក់ស៊ីម៉ា ហើយលោកស្រីបានចូលរួមជាមួយម៉ាក់ស៊ីម៉ានៅថ្ងៃទី២២ខែមករា ឆ្នាំ២០១៨។មុនពេលចូលរួមជាមួយម៉ាក់ស៊ីម៉ា លោកស្រីបានបម្រើការងារឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ចំរើន ជាអ្នកគ្រប់គ្រងប្រព័ន្ធ និងសវនករផ្ទៃក្នុងនៅឆ្នាំ២០១៧។នៅ ឆ្នាំ ២០០៨លោកស្រីបា នក្លាយជាប្រធានផ្នែកព័ត៌មានវិទ្យា ហើយបានផ្លាស់ប្តូរតំណែងទៅជា នា យ កដ្ឋាន សវនកម្មផ្ទៃក្នុងក្នុងឆ្នាំ២០១០ ហើយលោកស្រី ត្រូវបានតែងតាំងជានាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុងក្នុងឆ្នាំ២០១១ ហើយលោកស្រីបានចាកចេញពី គ្រឹះស្ថានមី ក្រូ ហិរញ្ញវត្ថុ ចម្រើន នៅខែកញ្ញា ឆ្នាំ២០១៧ ហើយលោកស្រីក៏ធ្លាប់ធ្វើ ការនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ធនាគារភូមិ ក្នុងមុខផ្នែកផ្សេងៗ ដូចជារដ្ឋបាលឥណទាន ព័ ត៌មាន វិទ្យា ពីឆ្នាំ១៩៩១ ដល់ឆ្នាំ២០០៧។ បច្ចុប្បន្ននេះ លោកស្រីទទួលបានអនុបណ្ឌិត ផ្នែកធនាគារ និងហិរ ញ្ញវ ត្ថុ និងទទួលបានបរិ ញ្ញាបត្រវិទ្យាសាស្ត្រកុំព្យូទ័រនៅសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ។



**លោកស្រី ខេង សុម៉ាលី**
ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង

**លោក ស្រី ទូ ច ពិសី** គឺជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ា ក់ ស៊ី ម៉ា ភីអិលស៊ី ។ មុនពេលចូលរួមជាមួយ ម៉ាក់ស៊ីម៉ា លោកស្រី បានបម្រើការងារជា ប្រ ធា ន សវនេ ក រផ្ទៃក្នុងជាន់ខ្ពស់នៅឯធនាគារឯកទេសAeonសវនេករជាន់ខ្ពស់នៅ Price Waterhouse Cooper ( PwC ) និងសវនេករនៅក្រុមហ៊ុន PCG & Partner។ លោកស្រីបានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកធនាគារ និងហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យបញ្ញាសាស្ត្រនៃកម្ពុជា (PUC) បរិញ្ញាបត្រគ្រប់គ្រងនៅសកលវិទ្យាល័យជាតិគ្រប់គ្រង (NUM) និង សិក្សា ACCA នៅសាលា CamEd Business School។ លោកស្រី អាចប្រើប្រាស់ភាសាខ្មែរ និង ភាសា អង់គ្លេសបានយ៉ាងល្អ។



**លោកស្រី ទូច ពិស**
ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ

---

**លោកសុវណ្ណចាន់ដា**ជាប្រធាននាយកដ្ឋានហានិភ័យនិងប្រតិបត្តិតាមនៅម៉ាក់ស៊ីម៉ា។ លោកបានចូលបម្រើការងារនៅម៉ាក់ស៊ីម៉ានៅខែកញ្ញា ឆ្នាំ២០១៩។មុនពេលចូលរួមជាមួយម៉ាក់ស៊ីម៉ា លោក បានបម្រើការឱ្យធនាគារអេស៊ីលីដា ភីអិលស៊ី។ ក្នុងឆ្នាំ ២០១៨-២០១៩ លោក បានបម្រើការជាអនុប្រធានផ្នែកប្រតិបត្តិតាមច្បាប់ នៅការិយាល័យកណ្តាល នៃធនាគារអេស៊ីលីដាភីអិលស៊ី ។ហើយនៅឆ្នាំ២០១៤-២០១៧ លោកបានបម្រើការជាប្រធានភ្នាក់ងារ រដ្ឋបាលសាខានៅសាខាក្រុងភ្នំពេញ នៃធនាគារអេស៊ីលីដាភីអិលស៊ី។ លោក បានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតហិរញ្ញវត្ថុ និងធនាគារ ពីសាកលវិទ្យាល័យ បៀលប្រាយនៅឆ្នាំ២០១៥ ។



**លោក សុវណ្ណ ចាន់ដា**
ប្រធាននាយកដ្ឋានហានិភ័យ និងប្រតិបត្តិតាម

# ការគ្រប់គ្រងកិច្ចការគាំពារសង្គម

## គោលដៅសង្គម

### ផ្តល់ឥណទានទឹកស្អាត និងអនាម័យ

បញ្ហានៃការបំពុលបរិស្ថាន អត្រានៃជំងឺផ្សេងៗគឺជាក្តីបារម្ភដ៏ចម្បងរបស់យើងចំពោះអតិថិជនបរិស្ថាននិងសហគមន៍។ ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម ម៉ាក់ស៊ីម៉ា បានបង្កើតផលិតផលឥណទានទឹកស្អាត និងអនាម័យ ដើម្បីផ្តល់ប្រាក់កម្ចីដល់អតិថិជនកែលំអស្តង់ដារនៃការរស់នៅ ដែលស្របតាមបេសកកម្មថ្មី របស់ម៉ាក់ស៊ីម៉ា ដោយមានគោលបំណង ធ្វើឲ្យប្រសើរឡើង នៃស្តង់ដារសេដ្ឋកិច្ចសង្គម។ អត្ថប្រយោជន៍ នៃផលិតផលឥណទានទឹកស្អាត និងអនាម័យចំពោះអតិថិជន ទី១) អតិថិជនមានសុខភាពល្អ ២) កាត់បន្ថយចំណាយគ្រួសារក្នុងការព្យាបាលជំងឺ ទី៣) ចំណេញពេលវេលាក្នុងការប្រកបមុខរបរ ទី៤) ជៀសវាងគ្រោះថ្នាក់ផ្សេងៗសម្រាប់ប្រជាជនកម្ពុជា ជាពិសេសកុមារដែលរស់នៅតំបន់ជនបទ។

### ផ្តល់ឥណទានតិចជាងឬស្មើ១.៥០០ដុល្លារដល់អតិថិជនជនបទ

ម៉ាក់ស៊ីម៉ាមានគោលបំណងផ្តល់ប្រាក់កម្ចីខ្នាតតូចដល់អតិថិជនដែលមានចំណូលទាបរាប់បញ្ចូលទាំងអតិថិជនងាយរងគ្រោះ និងអតិថិជនដែលមិនមានលទ្ធភាពទទួលសេវាពីធនាគារ ដើម្បីដោះស្រាយបញ្ហាផ្នែកហិរញ្ញវត្ថុរបស់ប្រជាជនក្រីក្រនៅតាមជនបទ ក្នុងគោលបំណងធ្វើឲ្យជីវភាពរបស់ពួកគេ កាន់តែប្រសើរឡើង ដែលស្របទៅនឹងបេសកកម្មរបស់ម៉ាក់ស៊ីម៉ា។ ដើម្បីធ្វើឲ្យអតិថិជនមានបទពិសោធន៍កាន់តែ ប្រ សើ រក្នុងការទទួលបានប្រាក់កម្ចី ម៉ាក់ស៊ីម៉ា បាន និងកំពុងរៀបចំផ្តល់ឥណទានឌីជីថល ជាផលិផលឥណទានថ្មី ដែលមានទំហំប្រាក់កម្ចីតូច មានលក្ខណៈងាយស្រួល និងរហ័សទាន់ចិត្ត។

### ផ្តល់ឥណទានដល់ស្ត្រីដែលមានមុខរបរផ្ទាល់ខ្លួន

ជាទូទៅស្ត្រីច្រើនតែជាអ្នកទទួលខុសត្រូវចាត់ចែងលុយកាក់ក្នុងគ្រួសារ ហើយមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ។ នៅក្នុងសេដ្ឋកិច្ចទំនើបដែលមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស សហគ្រិនត្រូវការដើមទុនសម្រាប់ពង្រីក ឬបង្កើតអាជីវកម្មថ្មី។ ម៉ាក់ស៊ីម៉ាផ្តល់នូវដំណោះស្រាយហិរញ្ញវត្ថុដើម្បីគាំទ្រដល់អាជីវកម្មរបស់អតិថិជនជា ស្ត្រី និងបង្កើតឱកាសការងារសម្រាប់សហគមន៍ដើម្បីលើកកម្ពស់កម្រិតជីវភាពរស់នៅឲ្យកាន់តែប្រសើរ។ ទន្ទឹមនឹងនេះយើងក៏បានផ្តល់ការអប់រំផ្នែកហិរញ្ញវត្ថុដល់អតិថិជនជាស្ត្រី ទាំងអតិថិជនចាស់ និងអតិថិជនថ្មីដើម្បីបង្កើនការអភិវឌ្ឍន៍ផ្នត់គំនិតរបស់ពួកគេលើការចាត់ចែងសាច់ប្រាក់។

# ការទទួលខុសត្រូវចំពោះអតិថិជន

ម៉ាក់ស៊ីម៉ា នៅតែបន្តជំរុញសកម្មភាពសង្គម និងជឿជាក់យ៉ាងមុតមាំថាអតិថិជនគឺជាបេះដូងនៃអាជីវកម្ម របស់ខ្លួន ហើយចាត់ទុកការការពារអតិថិជនជារឿងសំខាន់។ ម៉ាក់ស៊ីម៉ា នៅតែប្រកាន់ខ្ជាប់អនុវត្តគោលការណ៍ការពារអតិថិជនទាំង៧ ដែលមានដូចជាទី(១) ការបង្កើត និងចែកចាយផលិតផលសមស្រប ទី(២) ការការពារបំណុលវណ្ឌក ទី(៣) តម្លាភាព ទី(៤) ការកំណត់តម្លៃដែលមានការទទួលខុសត្រូវ (៥) ការគោរព និងឲ្យតម្លៃអតិថិជនស្មើៗគ្នា ទី(៦) រក្សាព័ត៌មានអតិថិជនជាការសម្ងាត់ ទី(៧) យន្តការដោះស្រាយបណ្ដឹងតវ៉ា។ លើស ពីនេះទៀត ម៉ាក់ស៊ីម៉ា មិនត្រឹមតែផ្ដល់សេវាហិរញ្ញវត្ថុដ៏ល្អ ដល់អតិថិជនប៉ុណ្ណោះទេ ថែមទាំងផ្ដល់សេវាមិនមែនហិរញ្ញវត្ថុ គឺជាការផ្ដល់ការអប់រំហិរញ្ញវត្ថុដល់អតិថិជន ដែលជាយុទ្ធសាស្ត្រមួយរបស់ ម៉ាក់ស៊ីម៉ា ដើម្បីនិរន្តរភាពយូរអង្វែង។ ម៉ាក់ស៊ីម៉ា ក៏លើកកម្ពស់សកម្មភាពសង្គម (SPM) និ ងគោលការណ៍ការពារអតិថិជន (CPP) ដោយធ្វើការបណ្ដុះបណ្ដាលទាំងបុគ្គលិកចាស់ និងបុគ្គលិកថ្មីទាំងអស់ ដើម្បីឲ្យពួកគេយល់ដឹងកាន់តែច្បាស់ពីការទទួលខុសត្រូវលើការងារសង្គម ក៏ដូចជាការថែរក្សាអតិថិជនឲ្យបានល្អ។



លោកស្រី ធីយ សាយ នៅចំការបន្លែរបស់គាត់

# ការស្ទង់មតិការពេញចិត្ត និងការចាកចេញរបស់អតិថិជន

ក្នុងឆ្នាំ២០២០ ម៉ាក់ស៊ីម៉ា បានធ្វើការស្ទាបស្ទង់ការចាកចេញ ជាមួយអតិថិជនដែលធ្វើឡើង ដោយបុគ្គលិកសាខាដើម្បីស្វែងយល់ពីមូលហេតុនៃការចាកចេញរបស់អតិថិជន។ នាយកដ្ឋានម៉ាឃីតធីង និងគាំពារសង្គម បានរកឃើញថា អតិថិជនភាគច្រើនពេញចិត្តនឹងសេវាកម្មម៉ាក់ស៊ីម៉ា ប៉ុន្តែអ្នកខ្លះត្អូញត្អែរអំពី អត្រាការប្រាក់ និងថ្លៃប្រតិបត្តិការខ្ពស់ ហើយទំហំប្រាក់កម្ចីទាប។ មូលហេតុចំបងដែលអតិថិជនចាកចេញគឺដោយសារតែមិនមានតម្រូវការ ឬត្រូវការប្រាក់កម្ចីថ្មី ហើយពួកគេមានដើមទុនគ្រប់គ្រាន់សម្រាប់អាជីវកម្មរបស់ពួកគេហើយ។

ក្នុងឆ្នាំនេះដែរ ម៉ាក់ស៊ីម៉ា ក៏បានធ្វើការស្ទង់មតិ អំពីការពេញចិត្តរបស់អតិថិជនផងដែរ ដើម្បីស្វែងយល់ថាតើមានចំនុចណាខ្លះដែលម៉ាក់ស៊ីម៉ាគួរតែកែលម្អលើផលិតផលនិងសេវាកម្ម។លទ្ធផលបានបង្ហាញថាអតិថិជនភាគច្រើនបង្ហាញនូវបទពិសោធន៍ពេញចិត្តនឹងផលិតផលសេ វា កម្មល្អ ដែលផ្តល់ជូនដោយបុគ្គលិករួសរាយរាក់ទាក់របស់ម៉ាស៊ីម៉ា។ មិនមានការប្រព្រឹត្តទង្វើមិនគប្បី ឬអាកប្បកិរិយាមិនល្អចំពោះអតិថិជនរបស់ម៉ាក់ស៊ីម៉ានោះទេ។ ទោះយ៉ាងណាក៏ដោយមានអតិថិជនចំនួន ៩៧% ពេញចិត្តនឹងម៉ាក់ស៊ីម៉ា មាន១.៦% មិនមានមតិយោបល់ និង មិនពេញចិត្តមាន១%។ ការស្ទង់មតិនេះក៏បានបង្ហាញថា អតិថិជនមួយចំនួនមិនពេញចិត្តនឹងអត្រាការប្រាក់ និងដំណើរការវាយតម្លៃប្រា ក់កម្ចី។ ដោយសារតែមានមតិយោបល់ ឬការរិះគន់របស់អតិថិជន ម៉ាក់ស៊ីម៉ា បានខិតខំប្រឹងប្រែង បន្ថែមទៀតដើម្បីកែលម្អការអភិវឌ្ឍន៍ផលិតផលដើម្បីបំពេញតាមតម្រូវការរបស់អតិថិជន។



ម៉ាក់ស៊ីម៉ា បានកំណត់ និងវិភាគបទពិសោធន៍អតិថិជន តាមរយៈការស្ទង់មតិការពេញចិត្ត និងការចាកចេញរបស់អតិថិជន។ ព័ត៌មាន និងទិន្នន័យដែលប្រមូលបានអាចឱ្យ ម៉ាក់ស៊ីម៉ា វាស់ស្ទង់តម្រូវការទីផ្សារដើម្បី កែលម្អការអភិវឌ្ឍន៍ផលិតផល ត្រួតពិនិត្យការផ្លាស់ប្តូរតម្រូវការអតិថិជន និងដោះស្រាយបណ្តឹងទូទៅហើយកំណត់មូលហេតុដែលអតិថិជនចាកចេញ។ ការយល់ដឹងកាន់តែច្បាស់អំពីឥរិយាបទ និងចំណង់ចំណូលចិត្តរបស់អតិថិជនគឺមានសារៈសំខាន់ខ្លាំងណាស់ដើម្បីទាក់ទាញអតិថិជនថ្មី និងរក្សាបាននូវអតិថិជនដែលមានភក្តីភាពចំពោះស្ថាប័ន។

# ប្រវត្តិជោគជ័យរបស់អតិថិជន



លោកស្រី យ៉ាន ស៊ីណា (អ្នកត្បាញសំពត់សូត្រ)

លោកស្រី យ៉ាន ស៊ីណា អាយុ ៣៤ ឆ្នាំ ជាម្តាយមានកូនប្រុស១នាក់ រស់នៅក្នុង ភូមិព្រៃកល្វង ឃុំព្រៃកល្វង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។ លោកស្រីមានមុខរបរត្បាញសំពត់សូត្រនៅផ្ទះ។ លោកស្រីប្រកបមុខរបរនេះ៦ឆ្នាំហើយ។ ប្តីរបស់លោកស្រី មានមុខរបរជាអ្នកម៉ៅការសំណង់នៅក្នុងភូមិ។ គាត់មានបទពិសោធន៍ក្នុងការងាររបស់គាត់អស់រយៈពេល ៥ឆ្នាំមកហើយ។

លោកស្រី យ៉ាន ស៊ីណា ចេះជំនាញតម្បាញពីម្តាយរបស់គាត់ដែលធ្លាប់ប្រកបមុខរបរបែបប្រពៃណីនេះ។ លោកស្រីបានចាប់ផ្តើមប្រកបមុខរបរត្បាញសំពត់សូត្រតាំងពីឆ្នាំ២០១៤។ បន្ទាប់មកលោកស្រី ត្រូវបានមន្ត្រីឥណទានម្នាក់របស់ ម៉ាក់ស៊ីម៉ា ចូលទៅផ្សព្វផ្សាយផលិតផលឥណទានក្នុងភូមិរបស់លោកស្រី។ លោកស្រី និងប្តីរបស់គាត់បានពិភាក្សាគ្នា ហើយសំរេចចិត្តស្នើសុំប្រាក់កម្ចីពី ម៉ាក់ស៊ីម៉ា ក្នុងទឹកប្រាក់ចំនួន ២.០០០ ដុល្លារ អាមេរិក ដើម្បីទិញសំភារៈសំរាប់ត្បាញ ដូចជាទិញសូត្រ ថ្លៃឈ្នួលប៉ាក់ផ្កា ថ្លៃឈ្នួលជ្រលក់ថ្នាំពណ៌ជាដើម និងប្រាក់កម្ចីមួយចំនួនប្រើលើការជួសជុលផ្ទះរបស់លោកស្រី។

ដោយសារតែការខិតខំប្រឹងប្រែង និងមានចំណង់ចំណូលចិត្តលើផ្នែកសិប្បកម្ម មុខរបររបស់លោកស្រីទទួលបានការរីកចម្រើនគួរឱ្យកត់សម្គាល់។ មុខរបរលោកស្រីមានការបញ្ជាទិញជាច្រើនពីអតិថិជន។ លោកស្រីបានមានប្រសាសន៍ថា ផលិតផលនីមួយៗដែលយើងផលិតគឺមានលក្ខណៈល្អប្រណិត និងត្រូវបានបង្កើតឡើងដោយទឹកចិត្តស្រលាញ់លើមុខរបរមួយនេះ។ យើងផ្តល់ជូននូវសំពត់សូត្រដែលមានគុណភាពល្អបំផុតដល់អតិថិជនរបស់យើង។ ការប្រកបមុខរបរដែលយើងស្រលាញ់ចូលចិត្ត នឹងធ្វើមុខរបររបស់យើងរីកលូតលាស់យ៉ាងល្អ។

សមិទ្ធិផលទាំងអស់នេះ គឺបានមកពីការប្រើប្រាស់ប្រាក់កម្ចី របស់ម៉ាក់ស៊ីម៉ាចំគោលដៅ។ ខ្ញុំពិតជាអរគុណដល់ ម៉ាក់ស៊ីម៉ា ដែលបានគាំទ្រផ្នែកហិរញ្ញវត្ថុដល់អាជីវកម្មរបស់យើង។ មិនត្រឹមតែជាអាជីវកម្មប៉ុណ្ណោះទេប៉ុន្តែវាក៏ជាប្រពៃណីដ៏មានតម្លៃរបស់ខ្មែរយើងផងដែរ។ ដោយសារតែម៉ាក់ស៊ីម៉ា ទើបជីវភាពរបស់យើងបានផ្លាស់ប្តូរបានល្អប្រសើរ។ យើងអាចមានលទ្ធភាពបង់ថ្លៃសាលាឱ្យកូន និងបានកែលម្អគេហដ្ឋានរបស់យើង។



## លោកស្រី វង្ស ចន្ថា
(អ្នកលក់ហ្គាស)

លោកស្រី វង្ស ចន្ថា ជាមួយនឹងស្នាមញញឹមពោរពេញដោយក្តីសង្ឃឹម លោកស្រីមានអាយុ ៣៦ឆ្នាំ មានកូន ២នាក់ ស្រីម្នាក់ និងកូនប្រុសម្នាក់ រស់នៅក្នុងភូមិ ឃ្លាំងមឿងជើង ឃុំព្រែកអំពិល ស្រុកខ្សាច់កណ្តាលខេត្តកណ្តាល។ លោកស្រី ប្រកបមុខរបរជាអ្នកបញ្ចូលហ្គាសលក់នៅក្នុងភូមិ។ លោកស្រីមានបទពិសោធន៍លើមុខរបរនេះ៦ឆ្នាំហើយ។ ប្តីរបស់លោកស្រី លោក ថើ វិថី អាយុ ៣០ឆ្នាំ គាត់មានមុខរបរដូចលោកស្រីដែរ ដោយគាត់ជាអ្នកដឹកហ្គាសលក់ទៅឲ្យអ្នកភូមិរបស់គាត់។ គាត់មានបទពិសោធជាមួយ ការងាររបស់ គាត់៦ឆ្នាំមកហើយ។

លោកស្រី ស្គាល់ ម៉ាក់ស៊ីម៉ា ជាលើកដំបូងក្នុងឆ្នាំ២០១៨ ដោយមន្រ្តីឥណទានរបស់ម៉ាក់ស៊ីម៉ាជាអ្នកណែនាំ។ អ្នកនាងចន្ថានិងស្វាមីបានពិភាក្សាគ្នាហើយសំរេចចិត្តស្នើសុំប្រាក់កម្ចីដំបូងពី ម៉ាក់ស៊ីម៉ា ក្នុងចំនួនទឹកប្រាក់ ៦.០០០ ដុល្លារដើម្បីសាងសង់ផ្ទះ។ លោកស្រី និងប្តីគាត់បានខិតខំប្រកបមុខរបរដើម្បីរកប្រាក់ចំណូលសម្រាប់គ្រួសារ និងសម្រាប់ការបង់ប្រាក់ទៅឱ្យម៉ាក់ស៊ីម៉ាទាន់ពេលវេលា។ ដោយសារតែកិច្ចខិតខំប្រឹងប្រែងក្នុងអាជីវកម្ម ទើបធ្វើឱ្យជីវភាពរបស់ពួកគាត់របានល្អប្រសើរឡើង។ ឥឡូវនេះពួកគាត់មានផ្ទះសមរម្យ ហើយមានការបញ្ជាទិញជាច្រើនពីការបញ្ចូលហ្គាសពីអតិថិជននៅក្នុងភូមិ។

ដោយមើលឃើញពីភាពប្រសើរឡើងនៃជីវភាពរបស់ពួកគាត់ ក្រោយមកពួកគាត់បានស្នើសុំប្រាក់កម្ចីបន្ថែមពីម៉ាក់ស៊ីម៉ា។ ឥឡូវនេះពួកគាត់យកប្រាក់កម្ចីថ្មីដែលមានទឹកប្រាក់ចំនួន ១៤.០០០ ដុល្លារអាមេរិក ដើម្បីទិញហ្គាស(LPG) សម្រាប់លក់ និងទិញដីចំនួន ២ ឡូត៍សម្រាប់លក់ដើម្បីធ្វើការវិនិយោគលើអចលនទ្រព្យរយៈពេលវែង ។លោកស្រី បានមានប្រសាសន៍ថា ជាចុងក្រោយខ្ញុំសូមថ្លែងអំណរគុណដល់ម៉ាក់ស៊ីម៉ា ដែលបានផ្តល់ប្រាក់កម្ចីដើម្បីធ្វើឱ្យជីវភាពរបស់យើងកាន់តែប្រសើរឡើង។




# ការទទួលខុសត្រូវចំពោះបុគ្គលិក

ម៉ាក់ស៊ីម៉ា តែងតែយកចិត្តទុកដាក់ដល់បុគ្គលិករបស់ខ្លួនដោយផ្តល់បរិយាកាសការងារល្អ និងលើកទឹកចិត្តបុគ្គលិកឱ្យលេងកីឡា។

ដើម្បីលើកកម្ពស់សុខភាពរបស់បុគ្គលិក និងដើម្បីរឹតចំណងមិត្តភាព ម៉ាក់ស៊ីម៉ាតែងតែរៀបចំកម្មវិធីលេងកីឡាបាល់ទាត់ជាប្រចាំ និងមានការចូលរួមលេងកីឡាពីសមាជិកនៃក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់លេងជាមួយគ្នា។ គំនិតផ្តួចផ្តើមនេះបង្កើតសាមគ្គីភាព និងទំនាក់ទំនងល្អក្នុងចំណោមបុគ្គលិក និងគណៈគ្រប់គ្រងរបស់ម៉ាក់ស៊ីម៉ា។

ឆ្នាំនេះ ម៉ាក់ស៊ីម៉ា បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការកសាងវប្បធម៌ល្អតាមរយៈក្រុមការងារដែលម៉ាក់ស៊ីម៉ា ជឿជាក់ថាធនធានមនុស្ស និងសាមគ្គីភាពល្អ វិញជាឆ្អឹងមួយ នឹងជួយដល់ការរីកចម្រើនដល់ស្ថាប័ន។

# បុគ្គលិក និងការអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក



គណៈគ្រប់គ្រងចូលរួមវគ្គបណ្តុះបណ្តាល **CIFRS**

ក្នុងឆ្នាំ២០២០ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី មានតំបន់ប្រតិបត្តិការគ្របដណ្តប់ រួមមាន៖ ភ្នំពេញ ខេត្តកណ្តាល តាកែវ កំពង់ស្ពឺ កំពត ព្រៃវែង ត្បូងឃ្មុំ និងកំពង់ចាម និងមានសាខាចំនួន១៣ដែលកំពុងធ្វើប្រតិបត្តិការនៅបណ្តាខេត្តទាំងនោះ។ ជាបន្តបន្ទាប់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី បានបន្តការជ្រើសរើសបុគ្គលិកដែលមានសមត្ថភាពមកបំពេញការងារ។ នាឆ្នាំ ២០២០ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា មានបុគ្គលិកសរុបចំនួន ១៩០ នាក់ ដែលក្នុងនោះ បុគ្គលិក ជាស្ត្រីមានចំនួន ៣៩នាក់ ត្រូវជា ២១,៦% នៃ ចំនួនបុគ្គលិកសរុប។

ម៉ាក់ស៊ីម៉ា បានផ្តល់ការបណ្តុះបណ្តាលទាំងក្នុង និងក្រៅដល់បុគ្គលិកដើម្បីគាំទ្រ ពួកគេលើជំនាញ និងសេវាកម្មដែលទាក់ទង។ ខាងក្រោមនេះគឺជាចំនួនបុគ្គលិកចូលរួម និងវគ្គបណ្តុះបណ្តាលដែលបានផ្តល់ជូនក្នុងឆ្នាំ២០២០ ។




គណៈគ្រប់គ្រងចូលរួមវគ្គបណ្តុះបណ្តាល **CIFRS**

## ការបណ្តុះបណ្តាលខាងក្នុង

| វគ្គបណ្តុះបណ្តាល | អ្នកចូលរួម |
|---|---|
| គោលនយោបាយរដ្ឋបាល | ៤ |
| មូលដ្ឋានគ្រឹះនៃការដោះស្រាយបញ្ហា | ១០ |
| Cambodian International Financial Reporting Standard for Small and Medium-sized entities | ២១ |
| គោលនយោបាយនិងនីតិវិធីបណ្តឹងតវ៉ាអតិថិជន | ២៤ |
| គោលការណ៍ឥណទាន | ៤ |
| គោលនយោបាយហិរញ្ញវត្ថុ | ៤ |
| ការបណ្តុះបណ្តាលមូលដ្ឋានដល់បុគ្គលិកថ្មី | ៤២ |
| គោលការណ៍គ្រប់គ្រងធនធានមនុស្ស | ៤ |
| Issue Ticket Management | ៧៤ |
| គោលនយោបាយព័ត៌មានវិទ្យា | ៤ |
| ការត្រួតពិនិត្យតាមដានឥណទានក្នុងប្រព័ន្ធ | ១៩ |
| ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម | ១៥០ |
| ការដោះស្រាយបញ្ហា- Hypothesis | ១០ |
| ឥណទានអនាម័យ និងទឹកស្អាត | ១០៧ |
| ការដោះស្រាយបញ្ហា | ១០ |
| សរុប | ៤៨៧ |

## ការបណ្តុះបណ្តាលខាងក្រៅ

| វគ្គបណ្តុះបណ្តាល | អ្នកចូលរួម |
|---|---|
| Practical Loan Delinquency Management | ១ |
| Anti-Money Laundering Compliance Practice in Financial Institutions | ១ |
| E-Filing base on level of users | ១ |
| Desktop Application base on level of users | ១ |
| E-Filing | ១ |
| Desktop Application | ១ |
| Certification for tax agent | ១ |
| Regulatory Compliance | ១ |
| Credit Risk Management | ១ |
| Corporate Governance Master Program | ១ |
| Financial / Market Risk Management in Financial Institution | ១ |
| សរុប | ១២ |

## ផលិតភាព និងទំហំការងាររបស់បុគ្គលិក

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា បានផ្តោតការយកចិត្តទុកដាក់ទាំងផ្នែកហិរញ្ញវត្ថុ និងសង្គម។ ដូចនេះ នៅពេលដែល ត្រូវពង្រីកអាជីវកម្ម និងតំបន់ប្រតិបត្តិការ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ក៏ផ្តោតការយកចិត្តទុកដាក់លើបំណុលវណ្ណែក និងអត្រានៃការជៀតចូល។ គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា អាចបន្តរក្សាបាននូវក្នុងកម្រិតដែលអាចគ្រប់គ្រងបាន។ តារាងផលិតភាពបានបង្ហាញដូចខាងក្រោម៖

| ផលិតភាព | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|---|
| ចំនួនអតិថិជន/ភ្នាក់ងារឥណទាន | ៧៦ | ៨៤ | ៩០ | ៨៦ | ៧២ |
| សំពាធឥណទាន/ ភ្នាក់ងារឥណទានម្នាក់ (គិតជាដុល្លារអាមេរិក) | ១៦៣.៧៥៥ | ២១៩.២៩៧ | ២៧៦.៤៣៥ | ៣១៥.០៦៧ | ២៦៩.២០០ |
| សំពាធឥណទាន/បុគ្គលិកទាំងអស់ (គិតជាដុល្លារអាមេរិក) | ៧៦.៧៦០ | ៩៣.៩៨៤ | ១០២.៨៩៥ | ១២៥.២៩០ | ១១០.៥១៤ |

# ការទទួលខុសត្រូវចំពោះបរិស្ថាន និងសហគមន៍



ដើមកោងកាងនៅតាមឆ្នេរសមុទ្រ

ម៉ាក់ស៊ីម៉ា មានគោលនយោបាយ និងនីតិវិធីផ្ទៃក្នុងជាផ្លូវការដែលត្រូវបានប្រើដើម្បីកំណត់ហានិភ័យសង្គម ឬ បរិស្ថាន ឬផលប៉ះពាល់ដែលទាក់ទងនឹងប្រតិបត្តិការ និងសកម្មភាពអាជីវកម្មរបស់អតិថិជន។ គោលនយោបាយ និងនីតិវិធីមានគោលបំណងផ្តល់នូវគោលការណ៍ណែនាំ និងការបណ្តុះបណ្តាលបុគ្គលិកដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើនិរន្តរភាពសង្គម និងបរិស្ថាន។

គោលនយោបាយ និងនីតិវិធី ក៏កំណត់អំពីបញ្ជីនៃសកម្មភាព ឬអាជីវកម្មត្រូវហាមឃាត់ ផងដែរ។ បញ្ជីនេះត្រូវអនុលោមតាមច្បាប់ជាតិ និងអន្តរជាតិ។ ម៉ាក់ស៊ីម៉ាមិនអនុញ្ញាត ឲ្យផ្តល់ប្រាក់កម្ចីដល់អតិថិជន ដែលមានបំណងប្រើប្រាស់ប្រាក់កម្ចី សម្រាប់អាជីវកម្មឬ សកម្មភាពដែលត្រូវបានហាមឃាត់ដោយច្បាប់នៃប្រទេសកម្ពុជា ឬច្បាប់អន្តរជាតិដូចខាងក្រោម៖

- ផលិតកម្ម ឬសកម្មភាព ដែលប្រើប្រាស់កម្លាំងពលកម្មដោយបង្ខំ និងពលកម្មកុមារ
- ផលិតកម្ម ឬជំនួញ ឬសកម្មភាពដែលចាត់ទុកជាការខុសច្បាប់ដោយប្រទេសជាម្ចាស់ផ្ទះ ឬបទប្បញ្ញត្តិ ឬអនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ។
- ផលិតកម្ម ឬ ជំនួញអាវុធជាតិផ្ទុះ និង ផលិតគ្រាប់រំសេវ ។
- ផលិតកម្ម ឬ ជំនួញភេសជ្ជៈមានជាតិអាល់កុល (លើកលែង ស្រាបៀរ និង ស្រា)
- ផលិតកម្ម ឬ ជំនួញថ្នាំជក់ ។
- សកម្មភាពអាជីវកម្មដែលពាក់ព័ន្ធនឹងល្បែងស៊ីសង និងកាស៊ីណូ ។
- ជំនួញសត្វព្រៃ ឬផលិតផលមកពីសត្វព្រៃដែលបានហាមឃាត់ក្រោមបញ្ញត្តិ CITES (អនុសញ្ញាស្តីពី ពាណិជ្ជកម្មអន្តរជាតិសត្វព្រៃជិតផុតពូជនៃសត្វព្រៃ) ។
- ផលិតកម្ម ឬជំនួញវត្ថុធាតុដើមសារធាតុវិទ្យុសកម្មជាដើម ។
- ផលិតកម្ម ឬជំនួញ ឬការប្រើប្រាស់នូវរូបធាតុសរសៃដែលមិនឆេះ ។
- ផលិតកម្ម ឬជំនួញឈើ ឬផលិតផលព្រៃឈើផ្សេងទៀត មកពីតំបន់ដែលមិនអាចគ្រប់គ្រងព្រៃឈើបាន។
- ផលិតកម្ម ឬជំនួញផលិតផលដែលមានសារធាតុPCBs



# កម្មវិធីឥណទានទឹកស្អាត និងអនាម័យ

កង្វះទឹកស្អាត និងអនាម័យ គឺជាហានិភ័យសុខភាព ដែលជះឥទ្ធិពលដល់ប្រជាជនកម្ពុជា ជាពិសេសកុមារនៅទូទាំងប្រទេសកម្ពុជា ព្រមទាំងអ្នកដែលរស់នៅតំបន់ជនបទ។ មានកុមារជាច្រើននៅតែ មិនទាន់យល់ដឹង អំពីទឹកស្អាត សុជីវធម៌ នៃការប្រើប្រាស់បង្គន់អនាម័យ និងការអនុវត្តសាមញ្ញៗក្នុងការលាងដៃជាមួយសាប៊ូ។ ផលប៉ះពាល់ចំពោះកុមារ គឺធ្ងន់ធ្ងរណាស់ ដូចជាជំងឺរាគរូស ជំងឺស្បែក ជំងឺផ្លូវដង្ហើម ជំងឺរលាកសួត ពោះវៀន និងជំងឺដទៃទៀត។

ម៉ាក់ស៊ីម៉ា បានសហការជាមួយអង្គការ Water.org ដែលជាអង្គការ មិនរកប្រាក់ចំណេញដើម្បីលើកកម្ពស់សុខុមាលភាពសង្គម។ ម៉ាក់ស៊ីម៉ា បានផ្តល់ឥណទានអនាម័យ និងទឹកស្អាតដល់អតិថិជនដែលចង់សាងសង់ រឺជួសជុលបង្គន់ ធ្វើអណ្តូងទឹក អាងស្តុកទឹក ឬទិញសម្ភារៈទឹកស្អាត និងអនាម័យផ្សេងៗដើម្បីកែលម្អជីវភាពរស់នៅរបស់ពួកគេ និងរួមចំណែកដល់ស្តង់ដារសេដ្ឋកិច្ចសង្គម។ គិតត្រឹមខែ ធ្នូ ឆ្នាំ ២០២០ យើងបានផ្តល់ឥណទានអនាម័យ និងទឹកស្អាតចំនួនជាង ៦០០គ្រួសារ។



លោកស្រី ខន សាមឿន ជាម្តាយអាយុ៤១ឆ្នាំមានកូនប្រុស២នាក់។ លោកស្រី និងក្រុមគ្រួសាររស់នៅភូមិកណ្តាលឃុំព្រៃកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល។ លោកស្រី ជាកសិករចិញ្ចឹមគោយកទៅលក់ រីឯប្តីឈ្មោះ ឆោម សំបូរ ជាសន្តិសុខ។ លោកស្រី សាមឿន ស្គាល់ម៉ាក់ស៊ីម៉ា ដំបូងពីមន្រ្តីឥណទានដែលបានណែនាំផលិតផល និងសេវាកម្មរបស់ ម៉ាក់ស៊ីម៉ានៅក្នុងភូមិ។ ជាមួយនឹងប្រាក់កម្ចី ដែលបានផ្តល់សម្រាប់វគ្គមុន លោកស្រីបានយកទៅទិញគោសម្រាប់ចិញ្ចឹមជាមួយចំនួនប្រាក់កម្ចីចំនួន ៣.០០០ ដុល្លារអាមេរិក។ បច្ចុប្បន្ននេះ លោកស្រី បានខ្ចីប្រាក់លើកទី៦ ដែលមានទឹកប្រាក់ចំនួន ៤.០០០ដុល្លារអាមេរិកដើម្បីសាងសង់ផ្ទះសម្រាប់គ្រួសារ និងសាងសង់ បង្គន់អនាម័យ។ មុនពេលខ្ចីប្រាក់នេះគ្រួសារលោកស្រីគ្មានបង្គន់នោះទេ ដូច្នេះលោកស្រីត្រូវដើរទៅឆ្ងាយពីផ្ទះទៅបន្ទោរបង់ក្នុងព្រៃ។ វាពិតជាលំបាកណាស់សម្រាប់គ្រួសាររបស់លោកស្រីជា ពិសេសលោកស្រីតែងតែព្រួយបារម្ភអំពី គ្រួសាររបស់នាងជាមួយនឹងសត្វអសិរពិស និងបញ្ហាសុខភាព។ លោកស្រីបានចំណាយប្រាក់យ៉ាងច្រើនទៅលើការថែទាំសុខភាព។ ដោយមើលឃើញពីការលំបាកក្នុងការបន្ទោរបង់សម្រាប់គ្រួសារ លោកស្រី និងប្តី បានពិភាក្សាគ្នាយកប្រាក់កម្ចីនេះទៅសង់បង្គន់សម្រាប់គ្រួសារលោកស្រី។ លោកស្រី បានមានប្រសាសន៍ថា ខ្ញុំសូមថ្លែងអំណរគុណដល់ម៉ាក់ស៊ីម៉ាដែលបានផ្តល់ប្រាក់កម្ចីដល់ខ្ញុំសម្រាប់សាងសង់ផ្ទះ ហើយឥឡូវនេះខ្ញុំក៏មានបង្គន់អនាម័យល្អសម្រាប់គ្រួសារខ្ញុំដែរ។

# របាយការណ៍ហិរញ្ញវត្ថុ និង របាយការណ៍របស់សវនករឯករាជ្យ

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
## របាយការណ៍របស់សវនករឯករាជ្យ
## របាយការណ៍ហិរញ្ញវត្ថុ

តារាងតុល្យការ
របាយការណ៍លទ្ធផល
របាយការណ៍ស្ដីពីបម្រែបម្រួលមូលធន
របាយការណ៍លំហូរសាច់ប្រាក់

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមដាក់ជូននូវរបាយការណ៍របស់ខ្លួន ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើ សវនកម្មរួចរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០។

### ក្រុមហ៊ុន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី ដែលមានឈ្មោះដើមថាអង្គការ ម៉ាក់ស៊ីម៉ា ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ បានបង្កើតឡើងនៅក្នុង ព្រះរាជាណាចក្រកម្ពុជា និង ចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៥ ក្រោមបញ្ជីពាណិជ្ជកម្មលេខ ០០០០៥៩៩៦ (ពីមុន Co. ៧៨៩៧E/២០០៥)។ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៥ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណអាជីវកម្មលេខ ០១៣ ពីធនាគារជាតិនៃកម្ពុជាក្នុងការផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុឱ្យប្រជាជនក្រីក្រក្នុងប្រទេសកម្ពុជា។ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១២ ធនាគារជាតិនៃកម្ពុជាបានផ្តល់អាជ្ញាប័ណ្ណអាជីវកម្មអចិន្ត្រៃយ៍ លេខ M.F ០១៣ ជាមួយនឹងឈ្មោះថ្មី ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុភីអិលស៊ី។ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៥ ធនាគារជាតិនៃកម្ពុជាបានអនុម័តលើការកែសម្រួលឈ្មោះថ្មីរបស់ក្រុមហ៊ុនជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី។

ទីស្នាក់ការដែលបានចុះបញ្ជីរបស់ក្រុមហ៊ុនស្ថិតនៅ ផ្ទះលេខ២១AB ផ្លូវលេខ២៧១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ សាខានៅតាមបណ្តាខេត្តនានារបស់ក្រុមហ៊ុន មានទីតាំងស្ថិតនៅខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និង ខេត្តតាកែវ។
នាកាលបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ក្រុមហ៊ុនមានបុគ្គលិកចំនួន ១៩០នាក់ (ឆ្នាំ២០១៩៖ ១៧១នាក់)។

### សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន រួមមាន ការធ្វើប្រតិបត្តិការលើរាល់សកម្មភាពមីក្រូហិរញ្ញវត្ថុ។ សេវាកម្មទាំងនោះរួមមានការផ្តល់ឥណទានទៅដល់គ្រួសារក្រីក្រ និងចំណូលទាប និងសហគ្រាសតូចដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
ពុំមានការផ្លាស់ប្តូរជាសារវន្តណាមួយសម្រាប់សកម្មភាពចម្បងរបស់ក្រុមហ៊ុនក្នុងអំឡុងការិយបរិច្ឆេទនេះទេ។

### លទ្ធផលប្រតិបត្តិការ និងភាគលាភ

លទ្ធផលនៃប្រតិបត្តិអាជីវកម្មរបស់ក្រុមហ៊ុនសម្រាប់ចុងបញ្ចប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងស្ថានភាពអាជីវកម្មរបស់ក្រុមហ៊ុននាការិយបរិច្ឆេទនោះ គឺត្រូវបានបង្ហាញដែលអមនូវរបាយការណ៍ហិរញ្ញវត្ថុ។

នាការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ក្រុមប្រឹក្សាភិបាលមិនបានប្រកាស ឬទូទាត់ភាគលាភដែលទាក់ទងនឹងប្រាក់ចំណេញឡើយ (ឆ្នាំ២០១៩៖ ក្រុមហ៊ុនបានប្រកាស និងទូទាត់ភាគលាភចំនួន ៧៤.៥៥១ ដុល្លារអាមេ រិក)។

## ក្រុមប្រឹក្សាភិបាល

សមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននៅក្នុងឆ្នាំ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះមានដូចខាងក្រោម៖

| ឈ្មោះ | មុខតំណែង | កាលបរិច្ឆេទតែងតាំង |
|---|---|---|
| លោក អន ប៊ុនហាក់ | ប្រធានក្រុមប្រឹក្សាភិបាល | ថ្ងៃទី៨ ខែមីនា ឆ្នាំ២០០០ |
| លោក ជេត ច័ន្ទប្រសើរ | សមាជិកក្រុមប្រឹក្សាភិបាល | ក្នុងខែធ្នូ ឆ្នាំ២០០០ |
| លោក Taejun Shin | សមាជិកក្រុមប្រឹក្សាភិបាល | ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៥ |
| លោក Sanjay Gandhi | សមាជិកក្រុមប្រឹក្សាភិបាល | ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៥ |
| លោក អៅ វេង | សមាជិកអភិបាលឯករាជ្យ | ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ |
| លោក ឃាន ឫទ្ធី | សមាជិកអភិបាលឯករាជ្យ | ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ |
| លោកស្រី Praachi Gandhi | សមាជិកក្រុមប្រឹក្សាភិបាល | ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៩ |
| លោក ប៉ា ប៊ុណ្ណរិទ្ធី | សមាជិកក្រុមប្រឹក្សាភិបាល | ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៩ |

### គណៈគ្រប់គ្រង

សមាជិកនៃក្រុមគណៈគ្រប់គ្រងរបស់ក្រុមហ៊ុននៅក្នុងឆ្នាំ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះមានដូចខាងក្រោម៖

| ឈ្មោះ | មុខតំណែង | កាលបរិច្ឆេទតែងតាំង |
|---|---|---|
| លោក ប៉ា ប៊ុណ្ណរិទ្ធី | អគ្គនាយកប្រតិបត្តិ | ថ្ងៃទី៨ ខែមីនា ឆ្នាំ២០០០ |
| លោកស្រី ស្រេង ស៊ីវធេង | នាយិកាប្រតិបត្តិហិរញ្ញវត្ថុ | ថ្ងៃទី៨ ខែមីនា ឆ្នាំ២០០០ |
| លោក ង៉យ ស៊ន | ប្រធាននាយកដ្ឋានឥណទាន | ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៥ |
| លោក ឃាន ដារិទ្ធ | ប្រធាននាយកដ្ឋានពត៌មានវិទ្យា | ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០៩ |
| លោកស្រី វង្ស សុម៉ាលី | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨ |
| លោកស្រី ទូច ពិសី | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ | ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨ |
| លោក ខៀវ សេងឌី | ប្រធាននាយកដ្ឋានទីផ្សារ | ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៦ |
| លោកស្រី ស៊ឹម សោភណា | ប្រធាននាយកដ្ឋានធនធានមនុស្ស | ថ្ងៃទី១ ខែតុលា ឆ្នាំ២០១៥ |
| លោកស្រី ឡាយ ស៊ីនាថ | ប្រធាននាយកដ្ឋានរដ្ឋបាល | ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០១ |
| លោក សុខ កុសល | ប្រធានគំពេង | ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១០ |
| លោក សុវណ្ណ ចាន់ដា | ប្រធាននាយកដ្ឋានអនុវត្តន៍ច្បាប់ | ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៩ |
| លោក យ៉ង រ៉ា | សហប្រធាននាយកដ្ឋានឥណទាន | ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ |

## អត្ថប្រយោជន៍របស់អភិបាល

អភិបាលដែលបន្តកាន់តំណែងរហូតដល់ចុងឆ្នាំហិរញ្ញវត្ថុ ហើយទទួលបានអត្ថប្រយោជន៍ពីភាគហ៊ុនរបស់ពួកគេនៅក្នុងក្រុមហ៊ុនមានដូចខាងក្រោម៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងឆ្នាំ២០១៩ | |
|---|---|---|
| | ភាគហ៊ុនកាន់កាប់ % | ចំនួនភាគហ៊ុនមានតម្លៃស្មើនឹង ១០ដុល្លារអាមេរិក |
| លោក អន ប៊ុនហាក់ | ១៩,៦៣% | ១០០.០០០ |
| លោក ជេត ច័ន្ទប្រសើរ | ១,០៨% | ៥.៥០០ |

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងការិយបរិច្ឆេទ និងចុងបញ្ចប់ការិយបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានការរៀបចំណាមួយ ដែលមានក្រុមហ៊ុនជាគូភាគីមួយក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាល ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយមធ្យោបាយទិញយកភាគហ៊ុនពីក្រុមហ៊ុនទេ។

ចាប់តាំងពីចុងបញ្ចប់ការិយបរិច្ឆេទមុន ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន លើកលែងតែមានការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## សវនករ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ចុងការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុន ហ្គ្រេន សនថុន (ខេមបូឌា) លីមីតធីត។

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុក្រុមប្រឹក្សាភិបាល មានការទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះដើម្បីបង្ហាញពីទិដ្ឋភាពពិតនិងត្រឹមត្រូវ សម្រាប់ការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២០ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់ របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទនេះ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលតម្រូវឱ្យ៖

(ក) ជ្រើសរើសគោលនយោបាយគណនេយ្យ ឱ្យដោយអនុលោមតាមគោលការណ៍ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាព ខ្នាតតូចនិងមធ្យមដោយផ្អែកលើការវិនិច្ឆ័យនិងការប៉ាន់ស្មានសមហេតុផល និងប្រុងប្រយ័ត្នហើយបន្ទាប់មកធ្វើការអនុវត្តគោលនយោបាយទាំងនេះឱ្យមានសង្គតិភាព

(ខ) អនុលោមតាមគោលការណ៍ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពខ្នាតតូចនិងមធ្យម ឬប្រសិនបើមានការប្រាសចាកណាមួយ ក្នុងការបង្ហាញនូវភាពពិត និងត្រឹមត្រូវក្រុមប្រឹក្សាភិបាលត្រូវប្រាកដថាការប្រាសចាកទាំងនេះត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ

(គ) រក្សាទុកកំណត់ត្រាគណនេយ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធិភាព

(ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តភាពនៃដំណើរការអាជីវកម្ម លើកលែងតែមានការសន្មតថាក្រុមហ៊ុន មិនមានលក្ខណៈសមស្របក្នុងការបន្តធ្វើប្រតិបត្តិការអាជីវកម្ម របស់ខ្លួននាពេល អនាគត។ និង

(ង) គ្រប់គ្រង និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធិភាព លើរាល់សេចក្តីសម្រេចចិត្តសំខាន់ៗទាំងអស់ដែលប៉ះពាល់ដល់លើប្រតិបត្តិការ និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធិភាពហើយត្រូវប្រាកដថាការសម្រេចចិត្តលើកិច្ចការទាំងនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល ក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ហើយក៏ត្រូវចាត់វិធានការឱ្យសមស្រប ដើម្បីទប់ស្កាត់ និងរកឱ្យឃើញការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលសូមបញ្ជាក់ថា ក្រុមហ៊ុនបានអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់នានា ដូចដែលបានបញ្ជាក់ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ។

## សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ អមដោយ របាយការណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់ រួមជាមួយនឹងកំណត់សម្គាល់នានា ត្រូវបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាការិយបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និង ស្ថានភាពលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ត្រូវបានរៀប ចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម។

ជំនួសអោយក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រង




**លោក អន ប៊ុនហាក់**
ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១

# របាយការណ៍របស់សវនករឯករាជ្យ

## ជូនចំពោះភាគហ៊ុនិករបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី

### មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី(“ក្រុមហ៊ុន”) ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុកាលបរិច្ឆេទគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ របាយការណ៍ចំណូលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមមានសេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ និងសេចក្តីពន្យល់ផ្សេងៗទៀត។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់អង្គភាពអាជីវកម្មខ្នាតតូច និងខ្នាតមធ្យម។

### មូលដ្ឋាននៃការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា (“CISAs”)។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ ដារទាំងនោះហើយគឺត្រូវបានរៀបរាប់បន្ថែមនៅក្នុងផ្នែកការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ។ យើងខ្ញុំមានឯករាជ្យភាពពីក្រុមហ៊ុនដោយ អនុលោមតាមក្រុមប្រឹក្សា ស្តង់ដារវិជ្ជាជីវៈគណនេយ្យអន្តរជាតិ ក្រមសីលធម៌ របស់គណនេ យ្យ ករជំនាញ (រួមទាំងស្តង់ដារឯករាជ្យអន្តរជាតិ) (“IESBA Code”) រួមជា មួ យនឹ ង តម្រូវការក្រមសីលធម៌ ដែលពាក់ព័ន្ធទៅនឹងការ ធ្វើ សវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុក្នុងប្រទេស ក ម្ពុ ជាហើយយើងខ្ញុំបានបំពេញការទទួលខុសត្រូវទៅតាមតម្រូវការក្រមសីលធម៌ទាំងនោះ និង IESBA Code ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្ម ដែលយើងខ្ញុំទទួលបាន គឺគ្រប់គ្រាន់ និងសមស្របដើម្បីផ្តល់មូលដ្ឋានសម្រាប់មតិយោបល់របស់យើងខ្ញុំ។

### ព័ត៌មានផ្សេងៗ

ក្រុ មប្រឹក្សាភិបាលមានទំនួលខុសត្រូវទាំងស្រុងទៅលើព័ត៌មានផ្សេងទៀត។ ព័ត៌មានផ្សេងៗទាំងនោះរួមមានព័ត៌មាននៅក្នុងរបាយការណ៍រប ស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ដែលយើងទទួលបាន មុ នការិយបរិច្ឆេទនៃរបាយការណ៍នេះ និងរបាយការណ៍ប្រចាំឆ្នាំដែលរំពឹងទុកថានឹងរៀមចំរួចរាល់សម្រាប់យើងខ្ញុំបន្ទាប់ពីការិយបរិច្ឆេទនៃរបាយការណ៍នេះ។

មតិ យោបល់របស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗទេ។ ហើយយើងខ្ញុំមិនផ្តល់ការធានាក្នុងទម្រង់បែបណាមួយឡើយ។

ភ្ជាប់ជាមួយការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន យើងខ្ញុំមានទំនួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗហើយយ ពិចារណាថាតើពត៌មានផ្សេងៗនោះ មានវិសមភាពជាសារវន្តជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុឬទេ ឬចំណេះដឹងរបស់យើងខ្ញុំដែលទទួលបានពីការធ្វើសវនកម្ម ថាតើពត៌មានទាំងនោះអាចមានកំហុសឆ្គងជាសារវន្តឬទេ។

ប្រសិនបើផ្អែកតាមការងារដែលយើងខ្ញុំបានអនុវត្តលើព័ត៌មានផ្សេងៗ ដែលយើងខ្ញុំទទួលបានមុនរបាយការណ៍សវនកម្មនេះ យើងខ្ញុំ សន្មតថាមានកំហុសជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗ ទាំងនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍នៅក្នុងករណីនេះឡើយ។ នៅពេលយើងខ្ញុំអានរបាយការណ៍ប្រចាំឆ្នាំ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា មានការរាយការណ៍ខុសជាសារវន្ត យើងខ្ញុំតម្រូវឱ្យរាយការណ៍បញ្ហាទាំងនោះ ទៅក្រុមប្រឹក្សាភិបាល និងឆ្លើយតបបញ្ហាទាំងនេះ ដោមអនុលោមតាមតម្រូវការ CISA ៧២០ (បានកែប្រែ)។

## ការទទួលខុសត្រូវរបស់ក្រុមគណៈគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងរបស់ក្រុមហ៊ុនទទួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះឱ្យបានត្រឹមត្រូវដោយ អនុលោមទៅតាម ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ("CIFRSs for SMEs") និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាវាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មិនឱ្យមានការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាល មកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងមានទំនួលខុសត្រូវចំពោះការវាយតម្លៃទៅលើ សមត្ថភាពក្រុមហ៊ុន ក្នុងការបន្តប្រតិបត្តិដោយផ្អែកលើមូលដ្ឋាននិរន្តភាព ការលាតត្រដាង ប្រសិនជាមានបញ្ហាទាក់ទងនឹងនិរន្តភាព និងការប្រើប្រាស់និរន្តភាពជាមូលដ្ឋានគណនេយ្យ លុះត្រាតែគណៈគ្រប់គ្រងមានគោលបំណងរំសាយក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬក៏គ្មានជម្រើសផ្សេង ប៉ុន្តែចាំបាច់ត្រូវធ្វើ។

## ការទទួលខុសត្រូវរបស់សវនករនៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផល ទៅលើរបាយការណ៍ហិរញ្ញវត្ថុដោយពុំមានលក្ខណៈខុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង និងការធ្វើរបាយការណ៍សវនកម្មដែលរួមមានមតិយោបល់របស់យើងខ្ញុំផងដែរ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាមួយដ៏ខ្ពស់ ប៉ុន្តែវាមិនបានធានាថាការធ្វើសវនកម្មដោយផ្អែកទៅលើស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា នឹងតែងតែរកឃើញនូវការរាយការណ៍ខុសជាសារវន្តដែលមានឡើយ។ ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែលអាចចាត់ទុកថាជាសារវន្ត នៅពេលដែលកំហុសមួយ ឬកំហុសរួមគ្នាបានធ្វើអោយប៉ះពាល់ដល់សេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

ផ្នែកមួយនៃជាការធ្វើសវនកម្មដោយយោងទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងអនុវត្តនូវវិជ្ជាជីវៈ
វិនិច្ឆ័យ និងមជ្ឈធាតុនិយមដោយមានវិជ្ជាជីវៈទៅលើការធ្វើសវនកម្ម។ យើងខ្ញុំក៏៖

- កំណត់អត្តសញ្ញាណនិងវាយតម្លៃនូវហានិភ័យនៃការរាយការណ៍ខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុថាតើវាកើតឡើងដោយការក្លែងបន្លំ ឬកំហុសឆ្គង រៀបចំនិងអនុវត្តនីតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្មឱ្យបានគ្រប់គ្រាន់និងសមស្របដើម្បីជាមូលដ្ឋាន សម្រាប់បញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញដោយការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងកំហុសឆ្គងដោយអចេតនាដោយសារ តែការក្លែងបន្លំរួមបញ្ចូលទាំងការរួមគំនិតការក្លែងបន្លំ ដោយចេតនាការលុបចោលដោយចេតនា ការបង្ហាញខុស ឬការល្មើសទៅលើការត្រួតពិនិត្យផ្ទៃក្នុង។

- ធ្វើការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុងដែលទាក់ទងទៅនឹង ការធ្វើសវនកម្មដើម្បីបង្កើតនូវនីតិវិធីសវនកម្មដែល សមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់លើប្រសិទ្ធិភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុននោះទេ។

- ធ្វើការវាយតម្លៃភាពសមស្រប លើគោលនយោបាយគណនេយ្យ ដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មាន ក៏ដូចជាការបង្ហាញនានាដែលធ្វើឡើងដោយមគណៈគ្រប់គ្រង។
- សន្និដ្ឋានដ៏សមស្របមួយទៅលើការប្រើប្រាស់របស់ក្រុមគណៈគ្រប់គ្រង លើមូលដ្ឋាននិរន្តភាពគណនេយ្យផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនប្រាកដប្រជា ជាសារវន្តបានកើតឡើងទាក់ទិននឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលធ្វើឱ្យមានមន្ទិលសង្ស័យខ្លាំង ទៅលើលទ្ធភាពការបន្តនិរន្តភាពរបស់ក្រុមហ៊ុន។ ប្រសិនបើយើងសន្និដ្ឋានថា ភាពមិនប្រាកដប្រជាជាសារវន្តនឹងកើតមានឡើង យើងតម្រូវឱ្យធ្វើការលាតត្រដាងព័ត៌មានចាំបាច់ ដើម្បីទាញការយកចិត្តទុកដាក់នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំទៅនឹងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬក៏ប្រសិនបើការលាតត្រដាងនោះមិនគ្រប់គ្រាន់ នោះមតិយោបល់មិនត្រឹមត្រូវនឹងត្រូវបានផ្តល់។ ការ សន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានគិតត្រឹមថ្ងៃនៃការចេញរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះបីយ៉ាងណាក៏ដោយ ស្ថានភាព ឬក៏ព្រឹត្តិការណ៍នាពេលអនាគតអាច បណ្តាលឱ្យក្រុមហ៊ុនមិនអាចបន្តប្រតិបត្តិការជានិរន្តភាពបាន។

- វាយ តម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងមាតិការបស់របាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងការលាតត្រដាងនានា ថាតើ របាយការណ៍ហិរញ្ញវត្ថុបង្ហាញនូវប្រតិបត្តិការ និងព្រឹត្តិការណ៍នានាដើម្បីបង្ហាញនូវភាពត្រឹមត្រូវសមស្របរបស់វា។

• យើ ងខ្ញុំប្រាស្រ័យទាក់ទងជាមួយនឹងគណៈគ្រប់គ្របទៅលើបញ្ហាផ្សេងៗ ការរៀបចំដែនកំណត់ និងពេលវេលាក្នុងការធ្វើសវនកម្ម និងរបបគំហើញ សវនកម្មសំខាន់ៗ រួមបញ្ចូលទាំងកង្វះខាតសំខាន់ៗមួយចំនួនទៅលើការគ្រប់គ្រងផ្ទៃក្នុងដែលពួកយើងខ្ញុំរកឃើញកំឡុងពេលធ្វើសវនកម្ម។

យើង ខ្ញុំក៏ផ្តល់ជូន គណៈគ្រប់គ្រងនូវសេចក្តីថ្លែងការណ៍មួយ ដែលយើងខ្ញុំបានអនុវត្តទៅតាមតម្រូវការ ក្រមសីលធម៌ដែលទាក់ទងនឹងឯករាជ្យភាព ហើយយើងខ្ញុំធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងគណៈក្រប់គ្រងនូវបញ្ហាទាំងអស់ ដែលនឹងគិតថាសមហេតុផលទៅលើឯករាជ្យភាព របស់យើងខ្ញុំ និង ការការពារដែលអាចមាន។

Grant Thornton

ហ្គ្រេន សនថុន ខេមបូឌា លីមីតធីត
គណនេយ្យករជំនាញ
សវនករប្រតិស្រុតចុះបញ្ជី

**Ronald C. Almera**
នាយកសវនករជំនាញ

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២១

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

| | កំណត់សម្គាល់ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (កំណត់សម្គាល់ ៣.២) | | (កំណត់សម្គាល់ ៣.២) |
| | | | | | (កំណត់ឡើងវិញ) |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៥ | ១៥.៣២២ | ៦១.៩៧៧ | ២៨.៨៩៦ | ១១៧.៧៥១ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ៦ | ២.៨៧៩.៩៦៨ | ១១.៦៤៩.៤៧១ | ១.១៧៥.៣៦៩ | ៤.៧៨៩.៦២៩ |
| សមតុល្យនៅធនាគារផ្សេងៗ | ៧ | ៨៥២.៩៥៩ | ៣.៤៥០.២១៩ | ១.២២៧.៨៧៨ | ៥.០០៣.៦០៣ |
| ឥណទានទៅអតិថិជន-សុទ្ធ | ៩ | ២០.៧៦២.៨៣១ | ៨៣.៩៨៥.៦៥១ | ២១.១៨៩.៨២០ | ៨៦.៣៤៨.៥១៧ |
| មូលធនវិនិយោគ | ១០ | ១០.០០០ | ៤០.៤៥០ | ១០.០០០ | ៤០.៧៥០ |
| ទ្រព្យសកម្មផ្សេងៗ | ១១ | ១០៦.០៧១ | ៤២៩.០៥៧ | ១២២.០៥៤ | ៤៩៧.៣៧០ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ១២ | ៦៤.៨៤៩ | ២៦២.៣១៤ | ៩៣.១០៧ | ៣៧៩.៤១១ |
| ទ្រព្យសកម្មអរូបិយ | ១៣ | ២៤.៣០៦ | ៩៨.៣១៨ | ៣២.៩១០ | ១៣៤.១០៨ |
| ទ្រព្យពន្ធពន្យារ | ២៨.៣ | ៦២.៧៦៤ | ២៥៣.៨៨០ | ៣៤.៥៦៤ | ១៤០.៨៤៨ |
| **ទ្រព្យសរុប** | | ២៤.៧៧៩.០៧០ | ១០០.២៣១.៣៣៧ | ២៣.៩១៤.៥៩៨ | ៩៧.៤៥១.៩៨៧ |
| **មូលធន និងបំណុល** | | | | | |
| មូលធន | | | | | |
| ដើមទុន | ១៤ | ៥.០៩៥.២៩០ | ២០.៥៦៩.៦៨៦ | ៥.០៩៥.២៩០ | ២០.៥៦៩.៦៨៦ |
| បុព្វលាភភាគហ៊ុន | ១៥ | ១.៥៣៨.១៧៤ | ៦.២០៩.៦០៨ | ១.៥៣៨.១៧៤ | ៦.២០៩.៦០៨ |
| ចំណូលរក្សាទុក | | ២.២២២.២២២ | ៨.៩៩១.០៣៣ | ១.៧០២.៤៨៨ | ៦.៨៧២.១៦៨ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ១៦ | ១៨៣.១៨២ | ៧៤០.០៦៤ | ១៨៦.០៦១ | ៧៥១.៧១០ |
| ប្រាក់ចំណូលបម្រុងទុក | | ១៣៣.៤២៤ | ៥៣៨.៤២៨ | ១៣៣.៤២៤ | ៥៣៨.៤២៨ |
| ប្តូរបម្រុងទុករូបិយប័ណ្ណ | | - | ៥៣.១០៣ | - | ៣២៩.៣០៥ |
| **មូលធនសរុប** | | ៩.១៧២.២៩២ | ៣៧.១០១.៩២២ | ៨.៦៥៥.៤៣៧ | ៣៥.២៧០.៩០៥ |
| **បំណុល** | | | | | |
| ទឹកប្រាក់ដំពាក់ភាគទុនិក | ១៧ | ១០.០០០.០០០ | ៤០.៤៥០.០០០ | ៦.៩២០.០២៥ | ២៨.១៩៩.១០២ |
| ប្រាក់កម្ចី | ១៨ | ៥.០២៧.៥៧២ | ២០.៣៣៦.៥២៩ | ៧.៧៩៥.៣៦៧ | ៣១.៧៦៦.១២១ |
| អត្ថប្រយោជន៍របស់នយោជិត | ១៩ | ៤៩.៤០០ | ១៩៩.៨២៣ | ៥២.៤៩៩ | ២១៣.៩៣៣ |
| បំណុលផ្សេងៗ | ២០ | ៤២៨.២៨៨ | ១.៧៣២.៤២៣ | ៤១១.៦៦៣ | ១.៦៧៧.៥២៧ |
| បំណុលពន្ធលើប្រាក់ចំណូល | ២៨.២ | ១០១.៥១៨ | ៤១០.៦៤០ | ៧៩.៦០៧ | ៣២៤.៣៩៩ |
| **បំណុលសរុប** | | ១៥.៦០៦.៧៧៨ | ៦៣.១២៩.៤១៥ | ១៥.២៥៩.១៦១ | ៦២.១៨១.០៨២ |
| **មូលធន និងបំណុលសរុប** | | ២៤.៧៧៩.០៧០ | ១០០.២៣១.៣៣៧ | ២៣.៩១៤.៥៩៨ | ៩៧.៤៥១.៩៨៧ |

# របាយការណ៍ចំណូលលម្អិត

| | កំណត់សម្គាល់ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (កំណត់សម្គាល់ ៣.២) | | (កំណត់សម្គាល់ ៣.២) (កំណត់ឡើងវិញ) |
| ចំណូលការប្រាក់ | ២១ | ៣.៩១៤.៤៣០ | ១៥.៩៥៩.១៣១ | ៣.៧៥៩.១៧០ | ១៥.២៣២.១៥៧ |
| ចំណាយការប្រាក់ | ២២ | (១.២៧៨.០៥៣) | (៥.២១០.៦២២) | (១.១៨៩.៥៦១) | (៤.៨២០.១០១) |
| **ចំណូលពីការប្រាក់សុទ្ធ** | | ២.៦៣៦.៣៧៧ | ១០.៧៤៨.៥០៩ | ២.៥៦៩.៦០៩ | ១០.៤១២.០៥៦ |
| ចំណូលពីសេវា និងកម្រៃជើងសារ | ២៣.១ | ១៨.៧៨៤ | ៧៦.៥៨២ | ២៣.៣៩៤ | ៩៤.៧៩២ |
| ចំណាយលើសេវា និងកម្រៃជើងសារ | ២៣.២ | (៧៣.៤៦៧) | (២៩៩.៥២៥) | - | - |
| ចំណូលពីសេវា និងកម្រៃជើងសារសុទ្ធ | | (៥៤.៦៨៣) | (២២២.៩៤៣) | ២៣.៣៩៤ | ៩៤.៧៩២ |
| ចំណូលផ្សេងៗ | ២៤ | ១៥១.១៨៥ | ៦១៦.៣៨១ | ២១០.៨៣៤ | ៨៥៤.២៩៩ |
| **ចំណូលប្រតិបត្តិការ** | | ២.៧៣២.៨៧៩ | ១១.១៤១.៩៤៧ | ២.៨០៣.៨៣៧ | ១១.៣៦១.១៤៧ |
| ចំណាយលើបុគ្គលិក | ២៥ | (១.៣០៧.៤៤៤) | (៥.៣៣០.៤៤៩) | (១.២៨៥.៧៣៨) | (៥.២០៩.៨១០) |
| ចំណាយប្រតិបត្តិការ | ២៦ | (៥៩៨.៤៩៩) | (២.៤៤០.០៨០) | (៧៧៤.៧៩១) | (៣.១៣៩.៤៥៣) |
| រំលស់ និងរំលស់លើទ្រព្យសកម្មអរូបី | ១២ & ១៣ | (៥០.០៨៦) | (២០៤.២០០) | (២០.៤២៣) | (៨២.៧៥៤) |
| សំវិធានធនលើគណនីជាប់សង្ស័យ៖ | | | | | |
| គណនីធនាគារ | ២៧ | (៦.៤២៤) | (២៦.១៩០) | ៦.៤២៦ | ២៦.០៣៨ |
| គណនីឥណទាន | ២៧ | (១០០.៣០៨) | (៤០៨.៩៥៦) | (២៧.៨៤៩) | (១២.៨៤៤) |
| **ប្រាក់ចំណេញមុនដកពន្ធលើប្រាក់ចំណូល** | | ៦៧០.១១៨ | ២.៧៣២.០៧២ | ៧០១.៤៦២ | ២.៨៤២.៣២៤ |
| ចំណាយពន្ធលើប្រាក់ចំណូល | ២៨.១ | (១៥៣.២៦៣) | (៦២៤.៨៥៣) | (១៨៦.៣១៣) | (៧៥៤.៩៤០) |
| **ចំណេញសុទ្ធក្នុងឆ្នាំ** | | ៥១៦.៨៥៥ | ២.១០៧.២១៩ | ៥១៥.១៤៩ | ២.០៨៧.៣៨៤ |
| (ខាត)/ចំណូលលម្អិតផ្សេងៗ | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (២៧៦.២០២) | - | ៤៨០.២១៥ |
| **ចំណូលលម្អិតក្នុងឆ្នាំសរុប** | | ៥១៦.៨៥៥ | ១.៨៣១.០១៧ | ៥១៥.១៤៩ | ២.៥៦៧.៥៩៩ |

# របាយការណ៍បម្រែបម្រួលមូលធន

| | ដើមទុន | | បុព្វលាភដើមទុន | | ចំណេញរក្សាទុក | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ចំណូលបម្រុង | | ទុនបម្រុងប្តូររូបិយប័ណ្ណ | មូលធនសរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ខ្មែររៀល | ដុល្លាអាមេរិក | ខ្មែររៀល | ដុល្លាអាមេរិក | ខ្មែររៀល | ដុល្លាអាមេរិក | ខ្មែររៀល | ដុល្លាអាមេរិក | ខ្មែររៀល | ខ្មែររៀល | ដុល្លាអាមេរិក | ខ្មែររៀល |
| សមតុល្យថ្ងៃទី១ ខែមករា ឆ្នាំ២០២០ | ៥.០៩៥.២៩០ | ២០.៥៦៩.៦៨៦ | ១.៥៣៨.១៧៤ | ៦.២០៩.៦០៨ | ១.៧០២.៤៨៨ | ៦.៨៧២.១៦៨ | ១៨៦.០៦១ | ៧៥១.៧១០ | ១៣៣.៤២៤ | ៥៣៨.៤២៨ | ៣២៩.៣០៥ | ៨.៦៥៥.៤៣៧ | ៣៥.២៧០.៩០៥ |
| ចំណេញសុទ្ធក្នុងឆ្នាំ | - | - | - | - | ៥១៦.៨៥៥ | ២.១០៧.២១៩ | - | - | - | - | - | ៥១៦.៨៥៥ | ២.១០៧.២១៩ |
| ផ្ទេរទៅជាទុនបម្រុងប្បញ្ញត្តិ | - | - | - | - | ២.៨៧៩ | ១១.៦៤៦ | (២.៨៧៩) | (១១.៦៤៦) | - | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | - | (២៧៦.២០២) | - | (២៧៦.២០២) |
| សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | ៥.០៩៥.២៩០ | ២០.៥៦៩.៦៨៦ | ១.៥៣៨.១៧៤ | ៦.២០៩.៦០៨ | ២.២២២.២២២ | ៨.៩៩១.០៣៣ | ១៨៣.១៨២ | ៧៤០.០៦៤ | ១៣៣.៤២៤ | ៥៣៨.៤២៨ | ៥៣.១០៣ | ៩.១៧២.២៩២ | ៣៧.១០១.៩២២ |
| | | | | | | | | | | | | | |
| សមតុល្យថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ | ៥.០៩៥.២៩០ | ២០.៥៦៩.៦៨៦ | ១.៥៣៨.១៧៤ | ៦.២០៩.៦០៨ | ១.៣១៣.៣២០ | ៥.២៩៦.៩៧៣ | ១៥៧.៨៣៥ | ៦៣៧.៣៣៨ | ១១៣.៨០៥ | ៤៥៨.៩៣២ | (១៥០.៩១០) | ៨.២១៨.៤២៤ | ៣៣.០២១.៦២៧ |
| ចំណេញសុទ្ធក្នុងឆ្នាំ | - | - | - | - | ៥១៥.១៤៩ | ២.០៨៧.៣៨៤ | - | - | - | - | - | ៥១៥.១៤៩ | ២.០៨៧.៣៨៤ |
| ភាគលាភដែលបានបង់ | - | - | - | - | (៧៤.៥៥១) | (៣០៣.៧៩៥) | - | - | - | - | - | (៧៤.៥៥១) | (៣០៣.៧៩៥) |
| ផ្ទេរទៅជាទុនបម្រុង | - | - | - | - | (១៩.៦១៩) | (៧៩.៤៩៦) | - | - | ១៩.៦១៩ | ៧៩.៤៩៦ | - | - | - |
| ផ្ទេរទៅជាទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | (២៨.២២៦) | (១១៤.៣៧២) | ២៨.២២៦ | ១១៤.៣៧២ | - | - | - | - | - |
| ផលប៉ះពាល់សុទ្ធលើនិយ័តកម្មឆ្នាំចាស់ | - | - | - | - | (៣.៥៨៥) | (១៤.៥២៦) | - | - | - | - | - | (៣.៥៨៥) | (១៤.៥២៦) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | - | ៤៨០.២១៥ | - | ៤៨០.២១៥ |
| សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | ៥.០៩៥.២៩០ | ២០.៥៦៩.៦៨៦ | ១.៥៣៨.១៧៤ | ៦.២០៩.៦០៨ | ១.៧០២.៤៨៨ | ៦.៨៧២.១៦៨ | ១៨៦.០៦១ | ៧៥១.៧១០ | ១៣៣.៤២៤ | ៥៣៨.៤២៨ | ៣២៩.៣០៥ | ៨.៦៥៥.៤៣៧ | ៣៥.២៧០.៩០៥ |

# របាយការណ៍លំហូរសាច់ប្រាក់

| | កំណត់សម្គាល់ | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ | | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | (កំណត់សម្គាល់ ៣.២) | | (កំណត់សម្គាល់ ៣.២) (កំណត់ឡើងវិញ) |
| សកម្មភាពប្រតិបត្តិការ | | | | | |
| ចំណេញមុនបង់ពន្ធលើប្រាក់ចំណូល | | ៦៧០.១១៨ | ២.៧៣២.០៧២ | ៧០១.៤៦២ | ២.៨៤២.៣២៤ |
| និយ័តកម្មសម្រាប់៖ | | | | | |
| ចំណូលការប្រាក់សុទ្ធ | | (២.៦៣៦.៣៧៧) | (១០.៧៤៨.៥០៩) | (២.៥៦៩.៦០៩) | (១០.៤១២.០៥៦) |
| សំវិធានធនលើឥណទាន និងសមតុល្យជាមួយធនាគារផ្សេង | ២៧ | ១០៦.៧៣២ | (៤៣៥.១៤៦) | ២១.៤២៣ | ៨៦.៨០៦ |
| រំលស់លើទ្រព្យសម្បត្តិ និងបរិក្ខារ និងផលប៉ះពាល់សុទ្ធ លើបម្រែបម្រួលការប៉ាន់ស្មានគណនេយ្យ | ១២ | ៤១.៤៨២ | ១៦៩.១២២ | ៣១.៨៨៣ | ១២៩.១៩០ |
| រំលស់លើទ្រព្យសកម្មអរូបិយ និងផលប៉ះពាល់សុទ្ធលើបម្រែបម្រួលការប៉ាន់ស្មានគណនេយ្យ | ១៣ | ៨.៦០៤ | ៣៥.០៧៨ | (១១.៤៦០) | (៤៦.៤៣៦) |
| ខាតពីការលុបទ្រព្យសម្បត្តិ និងបរិក្ខារ | | - | - | ៥៤៩ | ២.២២៥ |
| ខាតពីការលុបនៃប្រាក់តម្កល់របស់ភាគហ៊ុនដែលបានចុះបញ្ជីនៃ Consorcio Estimos S.C. | | ៦.៥៥៣ | ២៦.៧១៧ | - | - |
| ការថយចុះនៃកាតព្វកិច្ចអត្ថប្រយោជន៍បុគ្គលិក | | (៣.០៩៩) | (១២.៦៣៥) | (៥.៥៨០) | (២២.៦១០) |
| ចំណេញប្រតិបត្តិការ | | (១.៨០៥.៩៨៧) | (៨.២៣៣.៣០១) | (១.៨៣១.៣៣២) | (៧.៤២០.៥៥៧) |
| បម្រែបម្រួលសុទ្ធក្នុង | | | | | |
| ឥណទានផ្តល់ដល់អតិថិជន-ដុល | | ៣៧១.៣០៩ | ១.៥១៣.៨២៧ | (២.៩០៣.៤២៨) | (១១.៧៦៤.៦៩០) |
| ទ្រព្យសកម្មផ្សេងៗ | | ៩.៤៣០ | ៣៨.៤៤៦ | ១៤៣.២៦៣ | ៥៨០.៥០២ |
| បំណុលផ្សេងៗ | | (៨១.៦៨៤) | (៣៣៣.០២៦) | ១៩៨.៨៣៨ | ៨០៥.៦៩២ |
| លំហូរសាច់ប្រាក់ដែលបានប្រើក្នុងសកម្មភាពប្រតិបត្តិការ | | (១.៥០៦.៩៣២) | (៧.០១៤.០៥៤) | (៤.៣៩២.៦៥៩) | (១៧.៧៩៩.០៥៣) |
| ការប្រាក់ដែលបានទទួល | | ៣.៨៦៩.៨០២ | ១៥.៧៧៧.១៨៣ | ៣.៧៧០.៣៦២ | ១៥.២៧៧.៥០៧ |
| ការប្រាក់ដែលបានទូទាត់ | | (១.២២៨.៣៤៣) | (៥.០០៧.៩៥៤) | (១.២៤៩.០៤៣) | (៥.០៦១.១២២) |
| ពន្ធលើប្រាក់ចំណូលដែលបានបង់ | ២៨.២ | (១៥៩.៥៥២) | (៦៥០.៤៩៤) | (១៩៩.៥៣៤) | (៨០៨.៥១២) |
| សាច់ប្រាក់សុទ្ធពី/(បានប្រើ) ក្នុងសកម្មភាពប្រតិបត្តិការ | | ៩៧៤.៩៧៥ | ៣.១០៤.៦៨១ | (២.០៧០.៨៧៤) | (៨.៣៩១.១៨០) |
| សកម្មភាពវិនិយោគ | | | | | |
| ទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ១២ | (១៣.២២៤) | (៥៣.៩១៤) | (៣២.១២៩) | (១៣០.១៨៧) |
| សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ | | (១៣.២២៤) | (៥៣.៩១៤) | (៣២.១២៩) | (១៣០.១៨៧) |
| សកម្មភាពហិរញ្ញប្បទាន | | | | | |
| ប្រាក់កម្ចីដែលបានបង់ | | ១៣.០០០.០០០ | ៥៣.០០១.០០០ | ៨.១០៥.៥៤៥ | ៣២.៨៤៣.៦៦៨ |
| ការទូទាត់ប្រាក់កម្ចី | | (១២.៦៣៩.១៩) | (៥១.៥២៩.៩៩៨) | (៥.១៥៥.៣៦០) | (២០.៨៨៩.៥១៩) |
| ភាគលាភបានបង់ | | - | - | (៧៤.៥៥១) | (៣០២.០៨១) |
| សាច់ប្រាក់សុទ្ធពីសកម្មហិរញ្ញប្បទាន | | ៣៦០.៨០៥ | ១.៤៧១.០០២ | ២.៨៧៥.៦៣៤ | ១១.៦៥២.០៦៨ |
| បម្រែបម្រួលសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ | | ១.៣២២.៥៥៦ | ៤.៥២១.៧៦៩ | ៧៧២.៦៣១ | ៣.១៣០.៧០១ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលថ្ងៃទី១ ខែមករា | | ២.១៧០.៩២៨ | ៨.៨៤៦.៥៣២ | ១.៣៩៨.២៩៧ | ៥.៦១៨.៣៥៧ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ៧៦២.៨៤៣ | - | ៩៧.៤៧៤ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលថ្ងៃទី៣១ ខែធ្នូ | ៨ | ៣.៤៩៣.៤៨៤ | ១៤.១៣១.១៤៤ | ២.១៧០.៩២៨ | ៨.៨៤៦.៥៣២ |


BM
MAMA
INSTANT NOODLES
MINCED PORK FLAVOUR
Phka Romdoul Rice



# សកម្មភាពសំខាន់ៗប្រចាំឆ្នាំ

ជារៀងរាល់ឆ្នាំគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី តែងតែប្រារព្ធពិធីជប់លៀងប្រចាំឆ្នាំដើម្បីលើកទឹកចិត្ត ដល់និយោជិតដែលបានខិតខំបំពេញការងារ ដើម្បីទទួលបានលទ្ធផលល្អសម្រាប់ស្ថាប័ន។ ដោយឡែកនៅក្នុងឆ្នាំ២០២០នេះ ដើម្បីចូលរួមទប់ស្កាត់ និងការពារជំងឺកូវីដ១៩ដែលកំពុងរាតត្បាតនៅក្នុងប្រទេសកម្ពុជាក៏ដូចជានៅលើពិភពលោក គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី បានសម្រេចចិត្តមិនមានពិធីជប់លៀងប្រចាំឆ្នាំដូចរាល់ឆ្នាំនោះទេ។ ទោះបីជាម៉ាក់ស៊ីម៉ា ស្ថិតក្នុងស្ថានភាពដ៏លំបាកនៃជំងឺរាតត្បាតជំងឺកូវីដ១៩ ក៏ដោយក៏ម៉ាក់ស៊ីម៉ា នៅតែយកចិត្តទុកដាក់ចំពោះសុខុមាលភាព របស់ បុគ្គលិក តាមរយៈការផ្តល់នូវស្បៀងអាហារដល់បុគ្គលិកនិយោជិត ដើម្បីជួយសម្រួលដល់ជីវភាពរស់នៅរបស់និយោជិតក្នុង ស្ថានភាពលំបាកនេះ។

# ការការពារមេរោគកូវីដ១៩

ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ គ្រឹះស្ថានម៉ាក់ស៊ីម៉ា បានអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ជាពិសេសបានអនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ ម៉ាក់ស៊ីម៉ា បានចាត់វិធានការដើម្បីការពារដូចខាងក្រោម៖

## ការលាងសម្អាតដៃ

បុគ្គលិកត្រូវលាងដៃជាមួយអាល់កុល ឬសាប៊ូរៀងរាល់ព្រឹកមុនពេលចូលធ្វើការ។ សាប៊ូ និងអាល់កុលត្រូវបានដាក់ឱ្យប្រើនៅតាមកន្លែងធ្វើការដើម្បីឱ្យបុគ្គលិកលាងដៃ ហើយបុគ្គលិកទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យមាន អាល់កុល កន្សែងដៃបាំង និងម៉ាស់ ផ្ទាល់ខ្លួនដើម្បីការពារជម្ងឺកូវីដ១៩។

## ការគ្រប់គ្រងសីតុណ្ហភាព

នៅតាមការិយាល័យបុគ្គលិកទាំងអស់ ត្រូវតែវាស់កម្តៅ និងកត់ត្រាទុកនៅក្នុងសៀវភៅកំណត់ហេតុប្រចាំថ្ងៃ។ ក្នុងករណីដែលនិយោជិតមានសីតុណ្ហភាពលើសពី ៣៧.៥ អង្សាសេ និយោជិត ត្រូវត្រឡប់ទៅផ្ទះវិញដើម្បីសម្រាក។ ប្រធានសាខាទទួលខុសត្រូវក្នុងការវាស់កម្តៅ និងកត់ត្រាវានៅ ក្នុងសៀវភៅកំណត់ហេតុ។ សម្រាប់ទីស្នាក់ការកណ្តាលបុគ្គលិករដ្ឋបាលទទួលខុសត្រូវក្នុងការវាស់កម្តៅ និងកត់ត្រានៅក្នុងសៀវភៅកំណត់ហេតុ។

## សម្រាប់បុគ្គលិកប្រតិបត្តិការ និងបុគ្គលិកគាំទ្រ

សម្រាប់មន្ត្រីឥណទាន និងបុគ្គលិកដែលត្រូវបានចាត់ឱ្យទៅតំបន់ប្រតិបត្តិការដើម្បីទៅជួបអតិថិជន មេភូមិឬអាជ្ញាធរ ត្រូវ ទី១) ពាក់ម៉ាសជានិច្ច ទី២) លាងដៃឱ្យបានញឹកញាប់ជាមួយសាប៊ូ ឬទឹកអាល់កុលនៅពេលត្រឡប់មកការិយាល័យវិញ។ អ្នកដែលក្អក ឬកណ្តាស់ត្រូវតែបិទមាត់និងច្រមុះដោយប្រើកន្សែងដៃ រឺយ៉ាងហោចណាស់កែងដៃជំនួសឱ្យបាតដៃ ហើយលាងដៃឱ្យបានត្រឹមត្រូវ។




សកម្មភាពបុគ្គលិកលាងសម្អាតដៃមុនចូលការិយាល័យ




ការវាស់កម្ដៅបុគ្គលិកមុនចូលបំពេញការងារ

មុនពេលចូលទៅបម្រើការងារនៅក្នុងការិយាល័យ បុគ្គលិកគ្រប់រូប ត្រូវវាស់សីតុណ្ហភាពដោយបុគ្គលិកដែលទទួលខុសត្រូវវាស់ និងកត់ត្រាសីតុណ្ហភាពនៅក្នុងសៀវភៅតាមដាន។ ប្រសិនបើសីតុណ្ហភាពរបស់បុគ្គលិកមានដល់ ៣៧.៥ ដឺក្រេនោះ ត្រូវបានអនុញ្ញាតឱ្យចាកចេញពីការិយាល័យ ដើម្បីព្យាបាល។



ម៉ាក់ស៊ីម៉ា តម្រូវឱ្យបុគ្គលិកទាំងអស់ត្រូវពាក់ម៉ាស់ របាំងការពារមុខ និងរក្សាគម្លាត ក្នុងពេលបំពេញការងារ។ ទន្ទឹមនឹងនោះ ម៉ាក់ស៊ីម៉ាក៏បានផ្ដល់ជាទឹកអាកុលដើម្បីឱ្យបុគ្គលិកលាងសំអាតដៃជាប្រចាំ។

# តំបន់ប្រតិបត្តិការ

## អាសយដ្ឋានការិយាល័យម៉ាក់ស៊ីម៉ា

### ការិយាល័យកណ្តាល

អាគារលេខ ២១AB ផ្លូវលេខ ២៧១ សង្កាត់ ផ្សារដើមថ្កូវ ខណ្ឌ ចំការមន រាជធានីភ្នំពេញ
ទូរសព្ទទំនាក់ទំនង: (៨៥៥) ២៣ ២១៤ ២៤០
អ៊ីមែល: info@maxima.com.kh

### សាខា

**សាខាខេត្តកណ្តាល (សាខាកៀនស្វាយ)**
ផ្ទះលេខ ៨២ ផ្លូវជាតិលេខ ១ ភូមិ កោះបៀ ឃុំ គគីរ ស្រុក កៀនស្វាយ ខេត្តកណ្តាល
ទូរសព្ទទំនាក់ទំនង: (៨៥៥) ៨៩ ៨១ ៥៦ ៥៧
អ៊ីមែល: ksv@maxima.com.kh

**សាខាព្រែកអញ្ចាញ(ខេត្តកណ្តាល)**
ផ្លូវជាតិលេខ ៦ ភូមិក្រោម ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល
ទូរសព្ទទំនាក់ទំនង: (៨៥៥) ៨៩ ៩៩៨ ៩៤៤
អ៊ីមែល: pac@maxima.com.kh

**សាខាព្រែកព្នៅ (ភ្នំពេញ)**
ផ្លូវជាតិលេខ ៥ ភូមិ កណ្តាល សង្កាត់ ព្រែកព្នៅ ខណ្ឌ ព្រែកព្នៅ រាជធានីភ្នំពេញ
ទូរសព្ទទំនាក់ទំនង: (៨៥៥) ៨៩ ៤៧៧ ៣០៦
អ៊ីមែល: prp@maxima.com.kh

**សាខាតាក្តុល (ខេត្តកណ្តាល)**
ផ្ទះលេខ៤១៥ ផ្លូវលេខ ១១៥ ភូមិតាក្តុល សង្កាត់តាក្តុល ក្រុងតាខ្មៅ ខេត្តកណ្តាល
ទូរសព្ទទំនាក់ទំនង: (៨៥៥) ៨៩ ៨៨៤ ៥៧១
អ៊ីមែល: ktd@maxima.com.kh

**សាខាបន្ទាយមាស (ខេត្តកំពត)**
ផ្លូវជាតិលេខ ៣ ភូមិព្រៃក្រឡាខាងលិច ឃុំទូកមាស ស្រុកបន្ទាយមាស ខេត្តកំពត
ទូរសព្ទទំនាក់ទំនង: (៨៥៥) ៨៩ ៨៩៩ ៤៦៦
អ៊ីមែល: btm@maxima.com.kh

**សាខាកោះឧកញ៉ាតី (ខេត្តកណ្តាល)**
ភូមិ ខ្ពប ឃុំ កោះឧកញ៉ាតី ស្រុក ខ្សាច់កណ្តាល ខេត្តកណ្តាល
ទូរសព្ទទំនាក់ទំនង: (៨៥៥) ៨៩ ៩៩៨ ៩៤៩
អ៊ីមែល: kot@maxima.com.kh

**សាខាចោមចៅ (ភ្នំពេញ)**
ផ្ទះលេខ ១៨អា ផ្លូវជាតិលេខ៤ ភូមិអង្គ សង្កាត់ ចោមចៅ ខណ្ឌ ពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ទូរសព្ទទំនាក់ទំនង: (៨៥៥) ៨៩ ៤៧៧ ៣០៥
អ៊ីមែល: chc@maxima.com.kh

**សាខាអរិយក្សត្រ (ខេត្តកណ្តាល)**
ភូមិ អរិយក្សត្រ ឃុំ អរិយក្សត្រ ស្រុក ល្វាឯម ខេត្តកណ្តាល
ទូរសព្ទទំនាក់ទំនង: (៨៥៥) ៨៩ ៣៣៣ ៥៧១
អ៊ីមែល: ark@maxima.com.kh

**សាខាថ្នល់ទទឹង (ខេត្តកណ្តាល)**
ភូមិ ថ្នល់ទទឹង ឃុំ ដំណាក់អំពិល ស្រុក អង្គស្នួល ខេត្តកណ្តាល
ទូរសព្ទទំនាក់ទំនង: (៨៥៥) ៨៩ ៩២៦ ៣៧៤
អ៊ីមែល: ttt@maxima.com.kh

**សាខាអង្គតាសោម (ខេត្តតាកែវ)**
ភូមិ ព្រៃរំដេង ឃុំ អង្គតាសោម ស្រុក ត្រាំកក់ ខេត្តតាកែវ
ទូរសព្ទទំនាក់ទំនង: (៨៥៥) ៨៩ ៣៣៣ ៤៧៩ អ៊ីមែល: ats@maxima.com.kh

**សាខាពារាំង (ខេត្តព្រៃវែង)**
ផ្លូវជាតិលេច ៨ ភូមិស្នាយពល ឃុំរការ ស្រុកពារាំង ខេត្តព្រៃវែង
ទូរសព្ទទំនាក់ទំនង: (៨៥៥) ៨៩ ២៥៩ ៨០១
អ៊ីមែល: per@maxima.com.kh

**សាខាអូររាំងឪ (ខេត្តត្បូងឃ្មុំ)**
ផ្លូវជាតិលេខ ១១ ភូមិលេខ ៤កើត ឃុំអំពិលតាពក ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ
ទូរសព្ទទំនាក់ទំនង: (៨៥៥) ៨៩ ២៥៩ ៧៩៥
អ៊ីមែល: oro@maxima.com.kh

**សាខាកងមាស (ខេត្តកំពង់ចាម)**
ភូមិពាមជីកង ឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម
ទូរសព្ទទំនាក់ទំនង: (៨៥៥) ៨៩ ២៥៩ ៧៩៩
អ៊ីមែល: kom@maxima.com.kh

# ផែនទីបង្ហាញទីតាំង




Legend:

Distance from Head Office

| | |
|---|---|
| 1-PNH | : 0km |
| 2-ARK | : 8km |
| 3-KOT | : 15km |
| 4-PAC | : 27km |
| 5-KOM | : 84km |
| 6-PER | : 63km |
| 7-ORO | : 132km |
| 8-KSV | : 15km |
| 9-TKD | : 11km |
| 10-CHC | : 13km |
| 11-PRP | : 18km |
| 12-TTT | : 32km |
| 13-ATS | : 72km |
| 14-BTM | : 116km |

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី

អគារលេខ ២១ AB ផ្លូវលេខ ២៧១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ។
ទូរស័ព្ទលេខ:+855(0)23 214 240
អ៊ីមែល: info@maxima.com.kh
គេហទំព័រ: http:/www.maxima.com.kh/

